ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jan-2012, 14:44
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី២១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ណាតាចា វីស៊ែល រីសឺ *(Ms. Natacha WEXELS-RISER)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

លោក ថារីក អាប់ឌុលឡាក់ *(Mr. Tarik ABDULHAK)*

លោកស្រី សារ៉ាស អេនឌ្រូ *(Ms.Sarah ANDREWS)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក ហ្សាក់ វែកហ្សេស

*(Mr. Jacques VERGES)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោក សំ សុគង់

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ហ្សាក់ វែកហ្សេស | បារាំង |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក វ៉ាន់ថាន់ ដាវ៉ាពៅ | ខ្មែរ |
| លោកស្រី ប្រាក់ យុត | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅលោក វ៉ាន់ថាន់ ដារ៉ាពៅ** (TCW-766)

សួរដោយលោក ម៉ៃខល កាណាវាស ផ្ដើមពី ........ ទំព័រ ០១

សួរដោយលោក គង់ សំអុន ផ្ដើមពី ........ ទំព័រ ២៦

សួរដោយលោក ហ្សាក់ វែកហ្សេស ផ្ដើមពី ........ ទំព័រ ៤៦

**ការសួរសំណួរទៅលោកស្រី ថ្វាក់ យុត** (TCW-542)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៥៤

សួរដោយលោក សេង ប៊ុនឃាង ផ្ដើមពី ........ ទំព័រ ៥៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កាលពីម្សិលមិញរសៀលចុងម៉ោង គឺដល់វេទិការបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ក្នុងការមានឱកាសក្នុងការសួរដល់សាក្សីរូប នេះ ហើយពេលវេលានៅមានមួយម៉ោងទៀត។ ដូច្នេះនៅពេលនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុម មេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះបន្ត។

សូមអញ្ជើញ!

[០៩:០៣:២៥]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម និងអស់លោក លោកស្រីនៅក្នុងនេះ និង នៅក្រៅបន្ទប់សវនាការ និងអរុណសួស្តីលោកសាក្សី។

**ស៖** មុនពេលដែលយើងតពីអ្វីដែលយើងបានសម្រាកកាលពីម្សិលមិញ ខ្ញុំសូមរំឭកសំណួរដែល សួរពីខាងលោក នួន ជា និងខ្លួនខ្ញុំផ្ទាល់ថាតើ ឌី.ស៊ី.ខេម មានសំណុំរឿងម្តុំៗជាក់លាក់សម្រាប់ជនជាប់ ចោទនីមួយៗដែរឬទេ? កាលពីម្សិលមិញលោកបានលើកឡើងថា ឌី.ស៊ី.ខេម មិនមានសំណុំឯកសារ មួយដាច់ដោយឡែកៗនេះទេ តើលោកនៅតែរក្សាចម្លើយរបស់លោកដដែលដែរឬទេ?

**ឆ៖** បាទ យើងមិនមានជាសំណុំរឿងសម្រាប់មេដឹកនាំមួយៗទេ។

**ស៖** សូមអរគុណ។ ដូច្នេះប្រសិនបើយើងមើលឯកសារមួយជាក់លាក់ដែលផ្តល់ជូនដោយមជ្ឈ មណ្ឌលឯកសារកម្ពុជា ឬក៏ ឌី.ស៊ី.ខេម គឺសូមឲ្យបង្ហាញនាពេលនេះតែម្តង។ លោកបានលើកឡើង កាលពីម្សិលមិញដែលថាលោកបានប្រគល់ឯកសារមួយចំនួនមកកាន់ ឌី.អេស.អេស លោកបាននិយាយ ដូច្នេះម្សិលមិញ ឬក៏ម្សិលម្ង៉ៃ។ នៅទីនេះ ខ្ញុំមាន *បាញ់ឌ័រ* ចំនួនបីសំណុំដែលនេះជាឯកសារទំព័រទីមួយ។ ឯកសារនេះលើកឡើងថា ចងក្រងដោយលោក ហើយដាក់ អៀង សារី។ ដូច្នេះ ខ្ញុំចង់សួរថាតើលោក

ជាអ្នកចងក្រងឯកសារនេះ ឬក៏ ឌី.អេស.អេស ខាងខ្ញុំ? ឬក៏វាសំណុំឯកសារពាក់ព័ន្ធទៅនឹង អៀង សារី ដែល ឌី.ស៊ី.ខេម ចងក្រង ហើយផ្តល់ជូនឲ្យលោកចងក្រងបន្ត? តើយ៉ាងម៉េចដែរទៅលើឯកសារនេះ?

**ឆ៖** ឯកសារនេះ គឺខ្ញុំបានបង្កើតជា *ហ្វូលឌ័រ* សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងបម្រើដល់ការសិក្សាស្រាវជ្រាវ គឺខ្ញុំបានធ្វើ។ ហើយខ្ញុំបានផ្តល់ជូនឯកសារនេះជូនទៅដល់អង្គ-- ទៅដល់អង្គភាពគាំពារការពារក្តី។

[០៩:០៥:៥៣]

**ស៖** ដោយសារតែលោកជាអ្នកបង្កើតសំណុំឯកសារនេះ។ ដូច្នេះមិនមានឯកសារណាមួយដែលដាក់កំណត់សម្គាល់ថាជា សំណុំឯកសារលោក អៀង សារី ទេឬ?

**ឆ៖** ឯកសារនេះជា ខ្ញុំហៅថា "ហ្វូលឌ័រ" ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាម្នាក់ៗមានហ្វូលឌ័របែបនេះរៀងៗខ្លួន នៅពេលដែលធ្វើការសិក្សាស្រាវជ្រាវ។ ដូច្នេះ នៅពេលដែលអាចឯកសារ ឬមានអ្នក *រីខ្វេស* ឯកសារ ស្នើសុំឯកសារ ឲ្យតែលោកប្រទះឃើញបែបនេះ គឺយើងអាចដាក់បញ្ចូលមួយដុំសម្រាប់សិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

**ស៖** ដូច្នេះខ្ញុំសូមបញ្ជាក់ឲ្យលោកយល់។ លោកនិយាយអំពីហ្វូលឌ័រ ដូច្នេះលោកបានន័យថា ហ្វូលឌ័រហ្នឹងមិនមែនជាសំណុំឯកសារនោះទេ ដែលថាវាមិនមានឯកសារនៅក្នុងហ្នឹង ឬក៏យ៉ាងម៉េច?

[០៩:០៧:០៩]

**ឆ៖** នៅពេលដែលលោកមេធាវីបានសួរខ្ញុំ គឺទាក់ទងទៅនឹងសំណុំរឿងនៅពេលដែលបកប្រែបាទ។

**ស៖** សូមអរគុណ។ ខ្ញុំចង់ឲ្យបញ្ជាក់ឲ្យបានច្បាស់ លោកនិយាយថា តាមរយៈបកប្រែគេនិយាយពាក្យថា "ហ្វូលឌ័រ" គេអត់ប្រើពាក្យថា *"ហ្វាល"* ទេឬក៏យ៉ាងម៉េច? ដែលនេះជាចម្លើយដែលលោកឆ្លើយអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំបានស្តាប់ជាភាសាខ្មែរ ដែលភាសាដែលខ្ញុំបានយល់ដឹងច្បាស់លាស់ គឺបកប្រែមកជាសំណុំរឿង ហើយសំណុំរឿង ខ្ញុំយល់ថា វាខុសគ្នាពីពាក្យអង់គ្លេសថា "ហ្វូលឌ័រ" ហើយដែលហ្វូលឌ័រនេះ គឺអ្នកសិក្សាស្រាវជ្រាវជាអ្នកបង្កើតដោយខ្លួនឯង ហើយដែលនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបុគ្គលិកម្នាក់ៗ គឺមានហ្វូលឌ័រនេះរៀងៗខ្លួននៅក្នុងការសិក្សាស្រាវជ្រាវ ឬ--។ សម្រាប់ខ្ញុំគឺឯកសារបែបនេះ គឺធ្វើឡើងគឺសម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ។

[០៩:០៨:២៣]

**ស៖** ដូច្នេះខ្ញុំសូមសួរលោកម្តងទៀត។ លោកមានហ្វូលឌ័រដែលដាក់ឈ្មោះសម្រាប់ឯកសារបុគ្គលជនជាប់ចោទម្នាក់ៗដែរឬទេ? តើមានហ្វូលឌ័រមួយៗសម្រាប់លោក អៀង សារី, ខៀវ សំផន, នួន ជា និង អៀង ធីរិទ្ធ ដែរឬទេ? លោកអាចឆ្លើយថា មាន អត់ ឬក៏ប្រហែលជាមាន ឬក៏អត់ដឹង។

**ឆ៖** គឺមានបាទ។

**ស៖** តើហ្វូលឌ័រនីមួយៗនោះ គឺបានបង្កើតឡើងមុនពេលដែលយើងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬក៏យ៉ាងម៉េច?

**ឆ៖** ហ្វូលឌ័រនេះបានបង្កើតជាយូរមកហើយ នៅពេលដែលមានការអ្នកសិក្សាស្រាវជ្រាវមានការស្នើសុំឯកសារ ហើយយើងប្រទះឃើញឯកសារតាមការស្នើសុំអ៊ីចឹង គឺយើងបានដាក់ចូលនៅក្នុងហ្វូលឌ័របែបនេះ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវ។

**ស៖** ដូច្នេះខ្ញុំចង់សួរបញ្ជាក់ដើម្បីឲ្យខ្ញុំយល់ពីលោក។ តាមខាងពីក្រុម នួន ជា ដែលសួរលោកកាលពីម្សិលមិញ ថាតើមានហ្វូលឌ័រមួយដែលដាក់សម្រាប់ដាក់ឯកសារលោក នួន ជា ដែរឬទេ? លោកនិយាយថា “មាន” ហើយនៅពេលដែលគាត់និយាយសួរថា តើមានសំណុំឯកសារពាក់ព័ន្ធទៅនឹង នួន ជា ដែរឬទេ? លោកថា អត់មានទេ។ អ៊ីចឹងថាតើលោកឆ្លើយយ៉ាងម៉េចដែរ ទៅលើសំណួរទាំងអស់នេះ?

[០៩:១០:០៩]

**ឆ៖** ព្រោះថា វា-- សំណួរនេះវាទាក់ទងទៅនឹងការរៀបចំចងក្រងឯកសារដែលបែងចែកទៅជាប្រភេទឯកសារ។ ដែលក្នុងនោះ ខ្ញុំបាននិយាយថា អត់មានហ្វូលឌ័រសម្រាប់-- អត់មាន--

**ស៖** បាទ ខ្ញុំសូមស្កាត់លោកបន្តិច។ លោកកំពុងតែចង់ឲ្យពេលវេលាខ្ញុំអស់ហើយ លោកមិនឆ្លើយសំណួររបស់ខ្ញុំនោះទេ។ ចំពោះពាក្យថា “ហ្វូលឌ័រ” និង “ហ្វាល” គ្រាន់តែលោកឆ្លើយទៅថា មាន ឬក៏មិនមាន? ហ្វូលឌ័រ ឬក៏ហ្វាល? ទាក់ទងទៅនឹងសំណុំហ្វូលឌ័រ ឬក៏សំណុំឯកសារហ្វាលនេះ ថាមាន អត់សម្រាប់បុគ្គលនីមួយៗ?

**ឆ៖** ហ្វូលឌ័របែបនេះគឺមាន។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរសំណួរមួយទៀត។ ដូច្នេះហេតុផលនេះហើយដែលលោកមិនបានឆ្លើយជូនទៅដល់មេធាវីការពារក្តី ដែលសួរម្តងហើយម្តងទៀត។ នៅក្នុងថ្ងៃនេះ គឺខ្ញុំសួរលោកម្តង

ទៀត គឺលោកនៅបានស្បថរួចមកហើយ លោកត្រូវតែនិយាយដោយស្មោះត្រង់។ ដូច្នេះ សូមលោកបញ្ជាក់មើល ហេតុអ្វីបានជាម្សិលមិញអត់បានបញ្ជាក់ឆ្លើយទៅនឹងសំណួរដែលគេបានសួរ? សូមបញ្ជាក់ជូនអង្គជំនុំជម្រះ។

**ឆ៖** បាទ ព្រោះការរៀបចំហ្វូលឌ័របែបនេះមិនមែនជាការរៀបចំចងក្រងឯកសារទេ។ នៅពេលដែលយើងនិយាយអំពីការរៀបចំចងក្រងឯកសារ នោះយើង ពេលដែលយើងបានទទួលឯកសារ គឺយើងបែងចែកឯកសារទៅជាប្រភេទផ្សេងៗ ដូចជាឯកសារ “I” ឯកសារ “D” ឯកសារ “L” ឯកសារ “K” ឯកសារ “J”។ នៅពេលដែលសួរអំពីសំណុំឯកសារបែបនេះ ថាតើនៅមានការបែងចែងទៅជាសំណុំបែបនេះនៅពេលរៀបចំឯកសារដែរឬទេ? ខ្ញុំឆ្លើយថាអត់មាន។

[០៩:១២:២១]

**សៈ** ប្រហែលយើងមើលឯកសារ D312.2.15 ខ្ញុំមានឯកសារក្រដាសមួយសន្លឹកសម្រាប់លោក ហើយសូមឲ្យមន្ត្រីតុលាការមកយកក្រដាសនេះ ដើម្បីផ្តល់ជូនទៅកាន់សាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារជាក្រដាសពីមេធាវីទៅជូនសាក្សីពិនិត្យ។

ម្តងទៀត លោកមេធាវីអត់បានបើកក្បាលមីក្រូ។

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យ សូមអភ័យទោសលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**សៈ** ឯកសារ D312.2.15 គឺជាអ៊ីម៉ែល ដែលមានប្រធានកម្មវត្ថុគឺពាក់ព័ន្ធទៅនឹងឯកសារ អៀង សារី គឺនៅថ្ងៃ ចុះថ្ងៃទី-- ចុះខែមិថុនា ឆ្នាំ២០០៦ គឺពីលោក ភីតធ័រ ម៉ាខ្វៃអ៊័រ *(Peter McGuire)* ផ្តល់ជូនទៅដល់ ឌី.ស៊ី.ខេម។ តាមរយៈអ៊ីម៉ែលនេះ គឺមានឯកសារហ្វាល ដែលយើងហៅថា “ហ្វាល” សម្រាប់តែបុគ្គល អៀង ធីរិទ្ធ គឺវាមានតាំងពីឆ្នាំ២០០៣។ តើលោកបានដឹងទៅលើហ្វាលសម្រាប់លោក អៀង ធីរិទ្ធ នេះដែរឬទេ? លោកស្រី អៀង ធីរិទ្ធ នេះដែរឬទេ?

[០៩:១៣:៥៤]

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** ដូចខ្ញុំបានជម្រាបហើយថា នៅមជ្ឈមណ្ឌលឯកសារកម្ពុជាគឺយើង ក្នុងបុគ្គលិកម្នាក់ៗគឺ

មានហ្វូលឆ័រសម្រាប់ការសិក្សាស្រាវជ្រាវរៀងៗខ្លួន។ ខ្ញុំឱ្យឧទាហរណ៍មួយ ដូចជា ហ្វារីណា ធ្វើការសិក្សាពីរឿង--

**ស៖** លោក! លោកបានប្រាប់ខ្ញុំរួចមកហើយ នេះគឺជា ឌី-- ឯកសារនៅសម្រាប់ ឌី.ស៊ី.ខេម ហើយគេផ្ញើទៅកាន់ យុ។ តើ យុ ហ្នឹងជានរណា? គាត់ជាបុគ្គលិក ឬក៏ជាប្រធាន?

**ឆ៖** លោកមេធាវី ខ្ញុំសូមបញ្ជាក់ លោកមេធាវីមិនបានសួរខ្ញុំពីសំណួរខាងដើមថា ឯកសារនេះជា លោក យុ ឆាំង ឬក៏ជាយ៉ាងណាទេ។ តែដើម្បីឱ្យលោកយល់អំពីឯកសារនេះឱ្យបានច្បាស់លាស់ដាក់នៅចំពោះមុខខ្ញុំៗត្រូវឱ្យឧទាហរណ៍ដើម្បីឱ្យលោកមេធាវីបានងាយយល់នៅក្នុងការបង្កើតហ្វូលឆ័របែបនេះ ហើយថាតើហេតុអីបានជា--

[០៩:១៥:៥៥]

**ស៖** បាទ ល្អ សូមអរគុណ។ សូមឱ្យលោកមើលឯកសារហ្នឹង ដែលខ្ញុំផ្តល់ជូនលោក។ គឺនៅខាងក្រោម គេសរសេរថា "ជូនជំពោះលោក យុ" ជាភាសាអង់គ្លេស លោកមានសញ្ញាបត្រថ្នាក់ឧត្តមសិក្សាពី *ណូតត្រឹដេម* ដូច្នេះលោកអាចមើលឯកសារហ្នឹងជាភាសាអង់គ្លេសបាន ដែលផ្ញើ មកពីលោក ភីតធ័រ ម៉ាខ្វៃអ៊ី។ សូមឱ្យលោកមើលឯកសារមួយទៀត ដែលឯកសារនេះ ចុះឆ្នាំ១៩៩៨ វាជាអ៊ីម៉ែលមួយទៀត។ សូមឱ្យសហការីរបស់ខ្ញុំ គឺបង្ហាញតាមអេក្រង់ ខ្ញុំមានឯកសារជាក្រដាសផងដែរ ផ្តល់ជូនឱ្យលោកសាក្សី។ ដូច្នេះហើយសូមឱ្យមន្ត្រីតុលាការយកឯកសារមួយច្បាប់នេះផ្តល់ជូនទៅកាន់សាក្សី។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារក្រដាស ពីលោកមេធាវីទៅជូនលោកសាក្សីពិនិត្យ!

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមឱ្យលោកអានឱ្យលោកយល់ទៅលើឯកសារនេះ នៅខាងលើគេដាក់ថា ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ញើជូន ប៊ែន ឃៀរនិន ចម្លងជូន ហេឡេន ចាវីស កម្មវត្ថុព័ត៌មានថ្មីៗ ពាក់ព័ន្ធនឹង *ហ្វាល* សម្រាប់លោក នួន ជា គឺចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ១៩៩៨ លោកបានអានទេ? ហើយតាមទាន់ទេ? រកឃើញទេបាទ? សូមឆ្លើយ ឬឃើញ ឬមិនឃើញ? មើលយល់ ឬមិនយល់?

**ឆ៖** ខ្ញុំឃើញឯកសារនៅមុខខ្ញុំ។

[០៩:១៦:៣៨]

**ស៖** ប្រសិនបើមើលទំព័រទីពីរ លោកនឹងឃើញថា ជាការចុះហត្ថលេខាឈ្មោះបុគ្គល យុគី តើ យុគី នេះគឺជា យុ ឆាំង ឬក៏មិនមែន? តើ យុគី នេះគឺជា យុ ឆាំង ឬក៏មិនមែន?

**ឆ៖** មែន ជាឈ្មោះរបស់លោក យុ ឆាំង។

**ស៖** ប្រសិនបើមើលចំណារម្សិលមិញ ម្សិលម្ង៉ៃ លោកនិយាយអំពីចំណារ ដែលលោកអាចយល់ លោកបាននិយាយថា លោកអាចយល់អំពីចំណារ។ ដូច្នេះប្រសិនបើយើងមើលទៅលើចំណារនេះខាងលើ ថាតើគេនិយាយអីគេដែរនៅលើចំណារហ្នឹង? គឺចំណារទីមួយ អាទីមួយខាងលើគេបំផុតនោះ តើគេសរសេរអ្វីដែរ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមលើកឡើងជំទាស់បាទ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

ខ្ញុំសូមឲ្យសាក្សីឆ្លើយសិនបាទ លោកប្រធាន។

**ស៖** លោក *អិន.ស៊ី ហ្វាល (NC file)* នៅខាងចំណារហ្នឹងដាក់ *អិន.ស៊ី ហ្វាល* ហ្នឹងគឺយ៉ាងម៉េចដែរ ដារ៉ា *អិន.ស៊ី ហ្វាល* ហ្នឹង?

**ឆ៖** បាទ គឺក្នុងនេះខ្ញុំអាចអានបានគឺ៖ "ដារ៉ា *ហ្វ័រ អិន.ស៊ី ហ្វាល*"។

**ស៖** សូមអរគុណ។ ដូច្នេះតាមរយៈអ៊ីម៉ែល--

[០៩:១៨:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមលើកឡើងដោយខ្លី ខាងមេធាវីការពារក្តីលោកឡើងឯកសារ D ដែលមានលេខ D ពេលមុន ប៉ុន្តែឯកសារបញ្ចាំងហ្នឹងមិនមែនឯកសារ ដែលគាត់លើកលេខ*កូដ* នោះទេ។ ដូច្នេះហើយ សូមឲ្យមេធាវីការពារក្តីបញ្ជាក់ឲ្យបានច្បាស់លាស់ទៅលើលេខឯកសារ ហើយគួរតែផ្តល់ជូនទៅកាន់សាក្សីផងដែរ។ យើងមិនមែនជំទាស់ទៅលើបញ្ហាអានទេ ប៉ុន្តែឲ្យយើងយល់ឲ្យដឹងទាំងអស់គ្នាទៅលើឯកសារនេះ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឯកសារនេះអត់មានដាក់កំណត់សម្គាល់លេខ D ទេ ក៏ប៉ុន្តែខ្ញុំមានសំណុំ-- ខ្ញុំមានឯកសារ

ហ្នឹងជាក្រដាស។ ដូច្នេះហើយ គឺអាចជូនទៅសហព្រះរាជអាជ្ញាឲ្យបានច្បាស់លាស់ ឲ្យគាត់មើលឲ្យបានច្បាស់។ នៅក្នុងចំណារដំបូងគេបំផុតទីមួយនេះ សូមឲ្យសាក្សីអានម្តងទៀត ដើម្បីឲ្យខាងសហព្រះរាជអាជ្ញានេះគាត់ស្តាប់ឮឲ្យច្បាស់ផង។

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** ខ្ញុំគិតថា ខ្ញុំបានអានយ៉ាងច្បាស់ហើយ។ បើសិនជាមិនច្បាស់ លោកព្រះរាជអាជ្ញានឹងសួរខ្ញុំ។

**ស៖** លោក ខ្ញុំសូមឲ្យលោក លោកមិនមែនជាអ្នកបង្គាប់ស្នើសុំមកយើងនោះទេ។ ខ្ញុំសូមឲ្យលោកអាន ដើម្បីជាប្រយោជន៍ទៅដល់ខាងសហព្រះរាជអាជ្ញា។ តើចំណារដំបូងបំផុត នៅខាងលើបំផុតហ្នឹង តើគេសរសេរអីដែរ? សូមឲ្យអាន។

**ឆ៖** ចំណារមួយណា សូមបញ្ជាក់ឲ្យបានច្បាស់លាស់។

**ស៖** ចំណារទីមួយ ទីមួយបំផុត។ មួយដែលលោកទើបតែបានអានអម្បាញ់មិញនេះ។ បាទ លោកចងចាំថាលោកបានស្បថ ធ្វើសម្បថរួចហើយ។

[០៩:២០:០០]

**ឆ៖** បាទ ខ្ញុំបានអានម្តងរួចហើយ ជូនលោកមេធាវីបាទ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានសូមឲ្យបង្គាប់ទៅឲ្យសាក្សី ឲ្យអានចំណារដែលគាត់អានអម្បាញ់មិញនេះឡើងវិញ។ គឺខ្ញុំជាមេធាវីមានសិទ្ធិឲ្យសាក្សីគាត់អានសាជាថ្មី ដោយយើងពិចារណាឃើញការជំទាស់ពីខាងសហព្រះរាជអាជ្ញា។ ដូច្នេះហើយ គឺខ្ញុំសូមឲ្យសាក្សីអានសាថ្មី ដើម្បីឲ្យអាចស្តាប់ទាំងអស់គ្នាបាន និងមើលយល់ទាំងអស់គ្នា ដើម្បីធ្វើការឆ្លើយតបទៅនឹងការលើកឡើងជំទាស់ពីខាងសហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

ព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

មុនពេលដែលយើងចូលទៅដល់ចំណុចសម្បទាន។ ខ្ញុំបានសុំមុននេះបន្តិចថាតើមេធាវីការពារក្តីសុំឲ្យសាក្សីនោះអាចអានខាងក្រោមផងដែរទៅ ថាតើចុះថ្ងៃណាទទួលថ្ងៃណា អ្នកណាគេទទួលបាន។ កាលបរិច្ឆេទដែលថា ឆ្នាំ១៩៩៨ នោះគឺវាមិនពាក់ព័ន្ធនោះទេ យើងគួរតែសុំឲ្យខាងសាក្សីអានផ្ញើពីខាង

ណាមកពី-- ផ្ញើទៅខាងណា ចុះថ្ងៃណា។ ដូច្នេះហើយវាជាគោលបំណងមួយដែលយើងគិតថាត្រឹមត្រូវសម្រាប់ឆ្លើយតបទៅនឹងសំណួរ។

[០៩:២១:៣០]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន គឺខ្ញុំមានឯកសារនេះជាក្រដាសមួយសន្លឹកសម្រាប់សហព្រះរាជអាជ្ញា ខ្ញុំបានអានរួចមកហើយអម្បាញ់មិញ។ ដូច្នេះហើយគឺយើងខ្ញុំសូមបង្គាប់ឲ្យសាក្សី អានពីលើរហូតមកដល់ចំណុចដែលថា "ជូនចំពោះលោក ប៉ែន"។

**ប្រធានអង្គជំនុំ៖**

លោក កាណាវាស អង្គុយចុះសិន!

[០៩:២២:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៣:៤៨]

បាទ សូមប្រគល់ភារៈទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសួរនាំអំពីបញ្ហាឯកសារនេះទៅមេធាវីការពារក្តីអន្តរជាតិការពារ អៀង សារី។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កាណាវាស យើងប្រហែលជាកំពុងតែជួបប្រទះគ្នាទៅនឹងការខ្វែងយោបល់គ្នារវាងប្រព័ន្ធច្បាប់។ ក៏ប៉ុន្តែក្រោយពីការពិភាក្សាគ្នាទៅ ដែលយើងពិភាក្សាគ្នាអម្បាញ់មិញ ឯកសារប្រភេទនេះគឺ មិនអាចយកមកប្រើប្រាស់ នៅចំពោះមុខអង្គជំនុំជម្រះនេះទេ ដោយសារមិនមាននៅក្នុងសំណុំរឿងតាមប្រព័ន្ធច្បាប់ស៊ីវិលឡ វាមិនមែនជាដីកាបង្គាប់នោះទេ ក៏ប៉ុន្តែដោយសារតែឃើញឯកសារនេះ សូមឲ្យបញ្ជាក់ថា លោកទទួលឯកសារនេះពីណាមក ហើយសូមឲ្យលោកនិយាយអំពីសាវតារនៃការប្រមូលឯកសារនេះផងដែរ ហើយចៅក្រម ឡាវែន៍ គឺគាត់អាចពន្យល់បន្ថែមទៅលើប្រព័ន្ធច្បាប់ស៊ីវិលឡ ដែលគាត់អាចយល់ច្រើនជាងខ្ញុំ។

[០៩:២៥:០០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ គឺខ្ញុំគាត់តែបញ្ជាក់ គឺមិនមែនប្រព័ន្ធស៊ីវិលឡទេ គឺប្រព័ន្ធច្បាប់ពាក់ព័ន្ធនឹងភស្តុតាង ដូច

ដែលមាននៅក្នុងវិធានផ្ទៃក្នុង ជាពិសេសវិធាន៨៧(៤) គឺជាបញ្ជាក់អំពីភស្តុតាងថ្មីដែលលោក កាណាវាស បានដាក់ចំពោះមុខអង្គជំនុំជម្រះ។

ខ្ញុំមិនដឹងថា តើយើងទៅដល់ពេលណាទេ ប៉ុន្តែខ្ញុំគ្រាន់តែចង់បញ្ជាក់ ខ្ញុំចង់ឲ្យបានបំភ្លឺអំពីប្រភពនៃការទទួលបានឯកសារនេះ តើវាជាឯកសារឯកជនរវាងមនុស្ស បុគ្គលឯកជន ហើយខ្ញុំចង់ដឹងថាតើលោកទទួលបានឯកសារនេះមកពីណា?

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម ខ្ញុំអាចពន្យល់ដោយសង្ខេប។ នេះគឺជាភស្តុតាងថ្មីដែលយើងបានដឹងកាលពីម្សិលមិញពេលរសៀល ល្ងាចហើយកាលពីម្សិលមិញ។ ដូច្នេះហើយ មិនមានពេលពេលគ្រប់គ្រាន់ ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង។

[០៩:២៦:០៣]

នៅពេលដែលខ្ញុំមើលឯកសារនេះ យើងបានយល់ឃើញថា វាជាព័ត៌មាន ទោះបីវាជាព័ត៌មានទំនាក់ទំនងឯកជនរបស់បុគ្គលនេះក៏ដោយ វាអាចឲ្យយើងយល់អំពីភាពជឿជាក់ទៅលើសាក្សីរូបនេះបាន។ ម្សិលមិញគាត់និយាយថា អត់មាន *ហ្វាល* ពាក់ព័ន្ធទៅនឹងបុគ្គលជាក់លាក់ទេ តែនៅថ្ងៃនេះគាត់និយាយអំពី *ហ្វូលឌ័រ* ដែលមានទៅវិញ។ យើងឃើញមានអក្សរសំណេរដែលគាត់ស្គាល់។ ដូច្នេះហើយ ឯកសារនេះ គឺជាឯកសារដែលរកឃើញ វាយឺតពេល ហើយវាបាន បញ្ហានេះវាកើតឡើងនៅក្នុងនិតីវិធីរបស់យើង។ នៅក្នុងពេលនេះ គឺយើងកំពុងតែព្យាយាមរកឯកសារនៅក្រៅសំណុំរឿងផងដែរ។ ហើយយើងមានសិទ្ធិស្វែងរកឯកសារទាំងឡាយនៅក្រៅសំណុំរឿងផងដែរ។ ដូច្នេះហើយ ផ្អែកតាមប្រព័ន្ធស៊ីវិលឡ គឺយើងព្យាយាមធ្វើយ៉ាងណា បង្ហាញការពិតតាមដែលអាចធ្វើទៅបាន។ យើងព្យាយាមកម្រិតការពិនិត្យឯកសារទៅលើសំណុំឯកសារដែលមាននៅក្នុងសំណុំរឿង។ ក៏ប៉ុន្តែ ដោយសារតែយើងរកឯកសារនេះបានយឺតកាលពីម្សិលមិញ ទើបតែរកឃើញ ទើបយើងដាក់ជូន។

[០៩:២៧:១៨]

ខ្ញុំដឹងថា អង្គជំនុំជម្រះនឹងមានសំណួរបន្តមកខ្ញុំទៀត។ ដូច្នេះ វាមិនមែនជាបញ្ហាដែលថាយើងយល់មិនយល់ទៅលើនីតិវិធីនោះទេ វាពាក់ព័ន្ធទៅនឹងព័ត៌មានដែលយើងរកពីប្រភពផ្សេងបាន។ ជាការពិតទៅ ខ្ញុំធ្វើឡើងនេះគឺមិនមែនថាវាមិនត្រឹមត្រូវ មិនសមស្របនោះទេ។ គឺឯកសារនេះ វាលេចចេញបង្ហាញឲ្យខ្ញុំឃើញ ដូច្នេះទើបខ្ញុំទទួលបាន ហើយខ្ញុំប្រមូលឯកសារនេះយកមកបាន។ សូមអរគុណ។

[០៩:២៧:៤៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

វាជាបញ្ហាមួយ ដែលជាគោលការណ៍ វាជាការមិនយល់ស្របរវាងខាងសហព្រះរាជអាជ្ញានិងខាងមេធាវីការពារក្តី ជាពិសេស នៅពេលឯកសារឲ្យបង្ហាញឲ្យភាគីណាមួយដឹង។ ចំពោះសក្ខីកម្មរបស់សាក្សី យើងមិនជំទាស់ទេ។ បញ្ហាដែលលំបាកនៅទីនេះ គឺថាឯកសារនេះ គឺវាមានតាំងពីយូរមកហើយ ហើយយើងក៏មិនដឹងថាឯកសារនេះសរសេរដោយបុគ្គលនេះផ្ញើជូនទៅដល់គាត់ ឬក៏យ៉ាងម៉េចហើយចំណារនេះ យើងឃើញមានឈ្មោះគាត់មែន ក៏ប៉ុន្តែយើងមិនដឹងយ៉ាងម៉េចនោះទេ។ ដូច្នេះ ចំពោះខ្ញុំយើងគិតថាគួរតែអានឯកសារនេះទាំងស្រុងចូលទៅក្នុងប្រតិចារឹក បន្ទាប់មក គឺឲ្យសាក្សីផ្តល់ជាមតិយោបល់ទៅលើឯកសារនេះ។ ខ្ញុំដឹងអំពីកាលៈទេសៈដែលលំបាកសម្រាប់ការប្រមូលឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីតំណាង--

[០៩:២៩:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣០:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

អរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី គឺយើងជំទាស់ទៅនឹងការដាក់ឯកសារនេះ ពីព្រោះមានវិធានក្នុងការដាក់តាំង ដាក់បង្ហាញឯកសារនៅចំពោះមុខ អ.វ.ត.ក ហើយវិធាននេះត្រូវតែអនុវត្តចំពោះភាគីទាំងអស់។ ដូច្នេះខ្ញុំមិននិយាយអំពីការដាក់ឯកសារសំខាន់ទេ គឺចង់និយាយអំពីការដាក់ឯកសារពិភាក្សាថ្ងៃនេះ។ ទោះបីយើងដឹងឯកសារនេះពីម្សិលមិញក៏ដោយ ក៏យើងមិនអាចធ្វើបែបនេះដែរ បើសិនជាអ៊ីចឹងយើងត្រូវតែផ្លាស់ប្តូរវិធាន ហើយយើងត្រូវតែអនុវត្តតាមវិធានថ្មី គឺមិនអាចអនុវត្តតាមបែបនេះបានទេ។ ហើយមូលហេតុ ហេតុផលទីពីរនៃជំហររបស់យើងនោះ គឺ

ថាវាជាលិខិតឆ្លើយឆ្លងឯកជន ហើយមានវិធានពាក់ព័ន្ធទៅនឹងការដាក់ឯកសារឯកជនបែបនេះ។ ដូច្នេះ ខ្ញុំមិនអាចផ្តល់ជូននូវយុត្តិសាស្ត្រអន្តរជាតិបែបនេះបានទេ ក៏ប៉ុន្តែយើងមិនអាចដាក់ឯកសារនេះដោយអាចបញ្ជាក់ថា តើមកពីណា ហើយជាឯកសាររបស់ឯកជន-- បុគ្គលឯកជននោះទេ នេះគឺជាជំហររបស់ខាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន។

**លោក ម៉ែខល កាណាវាស៖**

លោកប្រធានតាមដែលខ្ញុំស្តាប់ឮពីដំបូងមក គឺខ្ញុំមានឯកសារមួយទៀត គឺបានមកពី គឺឯកសារនេះមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយសាក្សីរូបនេះ គឺជាតំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារនេះមកពី ប៉ែន យៀរនិន មកពី *យុគី* ផ្ញើជូន ប៉ែន យៀរនិន ។ ប្រហែលជា *យុគី* នេះគឺ យុ ឆាំង នេះឯង។ គឺគោលបំណងនៃការបង្ហាញនូវឯកសារនេះ គឺដោយសារថា វាផ្ទុយទៅនឹងអ្វីដែលសាក្សីឆ្លើយពីម្សិលមិញថា មិនមានសំណុំឯកសារសម្រាប់ជនជាប់ចោទម្នាក់ៗហ្នឹង។ ប៉ុន្តែយើងមានការបញ្ជាក់នៅខាងដើមទំព័រនេះ។ ហើយគាត់ជាអ្នកផ្តល់នូវឯកសារនេះ ហើយគាត់អាចនឹងជម្រាបជូនយើងខ្ញុំបានថា តើ ដារ៉ា គឺជាអ្នកណា? ហើយសម្រាប់សំណុំឯកសារ នួន ជា ឆ្នាំ២០០៨ ឬក៏ឆ្នាំ ២០០១ នេះៗបើយោងទៅតាមចំណារនេះ។

[០៩:៣២:៥៧]

ព័ត៌មាននៅក្នុងឯកសារនេះដែលខ្ញុំបានទទួលមក គឺថាយ៉ាងអស់ពេលណាស់ គឺខ្ញុំព្យាយាមចង់បង្ហាញដោយស្មោះត្រង់ ដើម្បីស្វែងរកឲ្យឃើញនូវភស្តុតាង។ ហេតុដូច្នេះហើយបានជាខ្ញុំបានបង្ហាញនូវឯកសារនេះ។ បើមាននីតិវិធីណាឲ្យខ្ញុំធ្វើយ៉ាងណានោះ គឺថាខ្ញុំនឹងអនុវត្តតាម ប៉ុន្តែយើងខ្ញុំប្រើប្រាស់ភស្តុតាងទាំងអស់ ហើយដោយសារវាមកយឺតពេលទៅហើយ ខ្ញុំមិនអាចស្នើដាក់ ហើយខ្ញុំសូមឲ្យអង្គជំនុំជម្រះប្រាប់ទៅសាក្សីឲ្យនឹកឡើងវិញនូវឯកសារនេះ ដើម្បីជាមូលហេតុឲ្យដំណើរការនីតិវិធីនេះឿនលឿនទៅមុខបាន។ បានខ្ញុំយកឯកសារមកបង្ហាញ ហើយដើម្បីចង់ដឹងពីភាពស្មោះត្រង់ និងជំនឿទុកចិត្តពីសាក្សីរូបនេះផង។

[០៩:៣៣:៥១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានប្រសិទ្ធភាព។ អង្គជំនុំជម្រះសម្រេចថា នាពេលនេះមិនអនុញ្ញាតឲ្យមេធាវីប្រើប្រាស់នូវ

ឯកសារភស្តុតាងយកមកដេញដោល នូវឯកសារភស្តុតាងណាដែលមិនបានមាននៅក្នុងសំណុំរឿង ហើយមិនទាន់កំណត់អំពីប្រភព និងអត្តសញ្ញាណឲ្យបានច្បាស់លាស់នោះនៅឡើយទេ។ អ្វីៗដែលត្រូវបានដាក់ជាឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវប្រព្រឹត្តទៅតាមវិធានផ្ទៃក្នុងដែលមានចែងរវាងការដាក់សំណុំឯកសារដែលមាននៅក្នុងសំណុំរឿង ហើយនិងឯកសារថ្មី ដែលមានចែង និងកំណត់រួចហើយៗមានការណែនាំរួចហើយផងដែរ។

[០៩:៣៤:៤៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមយោងទៅឯកសារដែលបានទទួលយកដាក់សំណុំ ប្រហែលជាបញ្ហានេះគឺថាពាក់ព័ន្ធទៅនឹងលោក យុ ឆាំង ទៀត។ ខ្ញុំយល់អំពីបញ្ហា ហើយសូមអរគុណចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ។

ខ្ញុំចូលទៅប្រធានបទថ្មី ជាសង្ខេបទេ ដោយសារពីម្សិលមិញយើងនិយាយគ្នាអំពីការវិភាគឯកសារ ហើយពីម្សិលមិញសាក្សី ឆ្លើយថាលោកមិនធ្វើការវិភាគទេ តែលោកធ្វើការវាយតម្លៃ។ ដូច្នេះខ្ញុំផ្តល់ឱកាសឲ្យលោក ថាតើលោកចង់កែតម្រូវសក្ខីកម្មរបស់លោកពីម្សិលមិញ និងពីម្សិលម៉្ងៃដែរឬទេ? ប្រសិនបើមើលឯកសារ D2-15.7 ខ្ញុំសូមជូនឯកសារក្រដាសជូនទៅសាក្សី ហើយជា ពិសេសឯកសារនេះ ជាភាសាអង់គ្លេស ERN00719721 ឯកសារនេះគឺបានសម្រេចនៅក្នុងដីកាបញ្ជូនរឿង ទៅជំនុំជម្រះ គឺកថាខណ្ឌ៩១ និងកថាខណ្ឌ២៥៩ ហើយឯកសារ E199 បើសិនជាសាក្សីរូបនេះអាចមើលទៅលើឯកសារនេះ ខ្ញុំអាចជូនជាឯកសារក្រដាស ជូនទៅសាក្សីបាន។

[០៩:៣៦:៤០]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទទួលឯកសារពីមេធាវី ទៅជូនសាក្សី!

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី សូមឲ្យលោកពិនិត្យមើលឯកសារនេះ នៅទំព័រ(ឮមិនច្បាស់) គឺខែកញ្ញា ២០០៦ តើឯកសារនេះ ជាឯកសារចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាមែនទេ?

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** បាទជាការត្រឹមត្រូវ។

**ស៖** ប្រសិនជាយើងចូលទៅមើលទំព័រទី២ ជាERN អង់គ្លេស 00719721 ហើយសូមមើលកថាខណ្ឌខាងដើមដំបូងបំផុត។ សូមលោកអានដោយខ្លួនឯង ព្រោះលោកចេះភាសាអង់គ្លេស។

**ឆ៖** ដោយសារថាខ្ញុំជឿជាក់លើភាសាខ្មែរដែលជាភាសាកំណើតរបស់ខ្ញុំបានច្បាស់ និងសុក្រឹតនោះ ខ្ញុំស្នើសុំឲ្យមានការបកប្រែជាភាសាខ្មែរជាជាង។

**ស៖** យើងមិនមានឯកសារបកប្រែជាភាសាខ្មែរទេ ប៉ុន្តែខ្ញុំបង្ហាញជូនតាមរបៀបនេះ។ តើលោកនៅតែរក្សាជំហរថាមិនមានការវិភាគឯកសារដោយ ឌី.ស៊ី.ខេម ដដែលឬ?

**ឆ៖** ខ្ញុំបាននិយាយថា នៅពេលដែលធ្វើការងារចងក្រងឯកសារនេះ គឺខ្ញុំមិនបានធ្វើការវិភាគទៅលើឯកសារទេ។

[០៩:៣៨:៥៩]

**ស៖** ដូច្នេះ មានថាន័យថាលោកមិនបានធ្វើការវិភាគឯកសារទេ មែនទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត។ គឺនៅពេលដែលចងក្រងឯកសារ រៀបចំឯកសារ--

**ស៖** លោកគ្រាន់តែឆ្លើយថា បាទ ឬក៏ទេ ប៉ុណ្ណឹងទៅបានហើយ។

**ឆ៖** បាទ ជម្រាបប្រសាសន៍លោកមេធាវី ដើម្បីឲ្យបានលោកជ្រាបច្បាស់ ខ្ញុំសូមឆ្លើយតាមអ្វីដែលខ្ញុំគិតថាចម្លើយនេះនឹងច្បាស់ជូនទៅលោក។

**ស៖** ថាតើលោកមានវិភាគឯកសារ ដើម្បីបញ្ជាក់ឲ្យឃើញថាឯកសារនោះមានយថាភាពដែរឬក៏អត់?

**ឆ៖** ចំពោះការធ្វើយថាភាពលើឯកសារ ខ្ញុំមិនបានធ្វើការវិភាគទេ។

[០៩:៤០:០០]

**ស៖** នៅពេលដែលនិយាយពាក្យថា “យើង” តើ “យើង” ហ្នឹងរួមទាំងលោកផងដែរឬក៏អត់នៅពេលដែលចាប់ផ្តើមសម្រេចអំពីបញ្ហាយថាភាពនេះ?

**ឆ៖** ប្រើពាក្យ “យើង” គឺខ្ញុំបានជម្រាបពីខាងដើមថានៅក្នុងការចងក្រងឯកសារនេះ មិនមែនមានតែខ្ញុំម្នាក់ឯងទេ។

**ស៖** បាទ ខ្ញុំត្រឡប់ទៅក្រោយទៀត នៅពេលដែលលោកប្រើពាក្យថា “យើង” តើយើងនេះរួមទាំងលោកផងឬក៏អត់? ដូចថាពាក្យ “យើង” នេះគឺនិយាយអំពីមជ្ឈមណ្ឌលឯកសារ-- ឬក៏និយាយតែមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ឆ៖** រួមទាំងខ្ញុំផង។

[០៩:៤០:៤០]

**ស៖** បាទ ដូច្នេះមជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានធ្វើការវិភាគក្នុងការសម្រេចថា តើឯកសារណាមួយដែលខ្លួនបានទទួល ដែលខ្លួនបានរក្សាទុកនោះ មានយថាភាពនោះទេ មែនទេ?

**ឆ៖** បាទ សូមលោកមេធាវីបញ្ជាក់សំណួរម្តងទៀត។

**ស៖** ឌី.ស៊ី.ខេម រួមទាំងរូបលោកផង គឺមិនបានធ្វើការវិភាគទៅលើឯកសារណាមួយទេ នៅពេលសម្រេចថាតើ-- នៅពេលវិភាគឯកសារដែលខ្លួនទទួលដើម្បីបញ្ជាក់អំពីយថាភាព មែនទេ?

**ឆ៖** ដើម្បីបញ្ជាក់ពីយថាភាពឯកសារ គឺមជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានធ្វើការវិភាគទៅលើឯកសារទេ។

**ស៖** តើវាជាការត្រឹមត្រូវឬទេ នៅពេលដែលនិយាយថា ការមិនមានការវិភាគអំពីយថាភាពរបស់ឯកសារកម្ពុជា? ឌី.ស៊ី.ខេម ក៏មិនបានធ្វើការវិភាគទៅលើភាពគួរឲ្យទុកចិត្តបាននៃឯកសារមួយនោះដែរ មែនទេ?

[០៩:៤១:៥៤]

**ឆ៖** សូមលោកមេធាវីមេត្តាបញ្ជាក់ម្តងទៀតអំពីសំណួរមួយនេះបាទ។ សូមមេត្តាបញ្ជាក់ម្តងទៀត។

**ស៖** ក្នុងនាមជាមេធាវី លោកទទួលបានការបណ្តុះបណ្តាលជាអ្នកច្បាប់ លោកមានការវិភាគទៅលើភាពគួរឲ្យទុកចិត្តបានដែរឬទេ ចំពោះឯកសារហ្នឹងមួយដែរឬទេ?

**ឆ៖** បើសិនជាខ្ញុំអាចសួរបញ្ជាក់បាន ថាតើទាក់ទងទៅនឹងការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏ទាក់ទងទៅនឹងការរៀនសូត្រផ្នែកច្បាប់របស់ខ្ញុំ?

**ស៖** ខ្ញុំសួរសំណួរនេះទូទៅ យើងបានបញ្ជាក់ហើយថា ឌី.ស៊ី.ខេម មិនបានបញ្ជាក់អំពីយថាភាពទេ។ ហើយតើ ឌី.ស៊ី.ខេម មានការធ្វើការវិភាគទៅលើភាពគួរឲ្យទុកចិត្តបានដែរឬក៏អត់? លោកឆ្លើយប៉ុណ្ណឹងមក ខ្ញុំនឹងសួរបន្តទៅមុខទៀតហើយ។

**ឆ៖** បាទ ពិតជាបាន។

**ស៖** តើ ឌី.ស៊ី.ខេម មានធ្វើការវិភាគទៅលើភាពគួរឲ្យទុកចិត្តបាននៃឯកសារដែល ឌី.ស៊ី.ខេម បានទទួលដែរឬទេ?

**ឆ៖** បាទ មានធ្វើ។

**ស៖** នៅពេលលោកនិយាយថា មានការធ្វើការវិភាគខ្លះៗ គឺវិភាគខ្លះ ឬក៏វិភាគឯកសារទាំងអស់តែម្តង?

**ឆ៖** ខ្ញុំបាននិយាយអំពីការធ្វើការវាយតម្លៃមិនមែនធ្វើការវិភាគនៅក្នុងការឆ្លើយថាភាពឯកសារទេ។

**ស៖** លោកនិយាយអំពីយថាភាព អ៊ីចឹងលោកអាចបញ្ជាក់បានទេ តើវាមានភាពខុសគ្នាយ៉ាងម៉េចរវាងយថាភាព និងភាពគួរឲ្យទុកចិត្តបាន ពីព្រោះភាសានេះវាមានទំនាក់ទំនងគ្នា លោកអាចពន្យល់ពាក្យខុសគ្នារវាងពាក្យទាំងពីរនេះបានទេ?

[០៩:៤៥:១០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមគោរពលោកប្រធាន សហព្រះរាជអាជ្ញាសូមជំទាស់ទៅនឹងសំណួរនេះ សាក្សីរូបនេះមិនបានហៅមកផ្តល់សក្ខីកម្មជំនាញទាក់ទងទៅនឹងភាពខុសគ្នារវាងយថាភាព និងភាពគួរឲ្យទុកចិត្តបានទេ ប្រហែលជាការសមស្របទៅ ថាតើដំណាក់កាលអីខ្លះដែល ឌី.ស៊ី.ខេម បានយកមកប្រើប្រាស់ ឬក៏និយាយអំពីដំណាក់កាល ឬក៏អ្វីមួយដែលប្រើប្រាស់ក្នុងការមានឯកសារនេះ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ប្រហែលជាខ្ញុំសូមឆ្លើយតបទៅសហព្រះរាជអាជ្ញជាសង្ខេបទេ។ ហេតុផលដែលខ្ញុំសួរ គឺដោយសារប្រហែលជាមានការបាត់ពាក្យពេចន៍ណានៅក្នុងការបកប្រែ ឬក៏មានការប្រាស្រ័យទាក់ទងគ្នាមិនបានគ្រប់គ្រាន់។ ដូច្នេះប្រសិនណាជា ខ្ញុំសូមឲ្យគាត់ឆ្លើយ ថាតើវាមានភាពខុសគ្នាយ៉ាងម៉េចរវាងពាក្យទាំងពីរ? ប៉ុន្តែ ឌី.ស៊ី.ខេម បាននិយាយអំពីវិធីសាស្ត្រដែលខ្លួនបាន ប្រើប្រាស់។ បើសិនណាជាសាក្សីរូបនេះគាត់ឆ្លើយថា ដឹង ឬក៏មិនដឹង គឺខ្ញុំនឹងសួរបន្តទៅទៀតហើយ។ ដោយខ្ញុំមិនចាំបាច់ចោទសួរគាត់នោះទេ ខ្ញុំសួរគ្រាន់តែពាក់ព័ន្ធទៅនឹងពាក្យ "យថាភាព" និង "ភាពគួរឲ្យទុកចិត្ត" បានតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ ការជំទាស់របស់សហព្រះរាជអាជ្ញា គឺត្រឹមត្រូវ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនទៅមេធាវីថា ការអញ្ជើញលោក ដារ៉ាពៅ មកនេះ ក្នុងនាមជាសាក្សី មិនមែនក្នុងនាមជាអ្នកជំនាញឯនោះ

ទេ។ ដូច្នេះលោកអាចប្រើសំណួរផ្សេង។

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** ឥឡូវសូមចូលទៅអ្វីដែលយើងនៅសល់កាលពីម្សិលមិញ។ លោកនិយាយអំពីបណ្ណសារ-ដ្ឋានជាតិ តើលោកអាចរៀបរាប់បានទេ ថាតើ ឌី.ស៊ី.ខេម បានរៀនសូត្រអ្វីខ្លះពីបណ្ណសារដ្ឋានជាតិដែលខ្លួនបានប្រើប្រាស់ទាក់ទងទៅនឹងយថាភាពនៃឯកសារ ដែលខ្លួនបានទទួល ហើយយកមករក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ?

[០៩:៤៦:៣៤]

**លោក វ៉ាន់ថាន ដាវ៉ាពៅ៖**

**ឆ៖** ខ្ញុំតាមការ-- ការងារជាក់ស្ដែងរបស់ខ្ញុំ គឺខ្ញុំបានទៅប្រមែប្រមូលឯកសារនៅបណ្ណសារដ្ឋានជាតិ។ នៅពេលដែលទៅដល់ គឺយើងបានសុំការអនុញ្ញាតពីអ្នកគ្រប់គ្រងនៅបណ្ណសារដ្ឋានជាតិ ដើម្បីធ្វើការសិក្សាអំពីឯកសារ។ ហើយនៅពេលនោះ គឺយើងបានឃើញឯកសារដែលពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនៅពេលនោះ គឺយើងសុំការអនុញ្ញាតដើម្បីធ្វើការថតចម្លងយកមកដាក់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបម្រើដល់ការសិក្សាស្រាវជ្រាវ។

[០៩:៤៧:១៩]

**ស៖** សូមអរគុណសាក្សី។ តាមដែលខ្ញុំយល់ចម្លើយរបស់លោក នោះ គឺ ឌី.ស៊ី.ខេម រួមទាំងរូបលោកផងមិនបានសួរទៅបណ្ណសារដ្ឋានជាតិ ថាតើបណ្ណសារដ្ឋានជាតិបានទទួលឯកសារនេះមកពីណា? អ្នកណាមកប្រគល់ឲ្យបណ្ណសារដ្ឋានជាតិ? នេះ តើសំណួរប្រភេទនេះ ឌី.ស៊ី.ខេម ដែលបានសួរទៅបណ្ណសារដ្ឋានជាតិដែរឬទេ?

**ឆ៖** ខ្ញុំពិតជាបានសួរអ្នកគ្រប់គ្រងបណ្ណសារជាតិ ហើយបើសិនជាលោកមេធាវីចង់ច្បាស់ គឺលោកមេធាវីអាចអញ្ជើញអ្នកធ្វើការនៅបណ្ណសារដ្ឋានជាតិ មកឆ្លើយពីបញ្ហានេះឲ្យបានកាន់ច្បាស់។

**ស៖** ឥឡូវនេះខ្ញុំពិភាក្សាជាមួយលោក គឺថាលោកបានសួរ យើងបានសំណួរនេះ-- លោកបានសួរសំណួរនេះដោយសារលោកចង់ដឹង ឬក៏ឌី.ស៊ី.ខេម ចង់ដឹងថាតើឯកសារទាំងនោះបានមកបណ្ណសារដ្ឋានជាតិដោយរបៀបណា មែនទេ?

[០៩:៤៨:៣៤]

**ឆ៖** ដោយសារលោកបានសួរបញ្ជាក់មកខ្ញុំ ហើយខ្ញុំដែលមិនមែនជាអ្នកធ្វើការងារនៅបណ្ណសារជាតិ។ ដូច្នេះហើយបានជាខ្ញុំធ្វើការស្នើសុំទៅលោក ដើម្បីឲ្យលោកបានយល់ដឹងកាន់តែច្បាស់អំពីការងារនៅបណ្ណសារជាតិ។

**សៈ** ក្នុងការសួរទៅសំណួរទៅកាន់បុគ្គលិករបស់បណ្ណសារដ្ឋានជាតិ ដើម្បីទទួលចម្លើយទាំងនោះ។ តើលោកនៅចាំចម្លើយទាំងនោះទេ? លោកមានកត់ត្រាចម្លើយទាំងនោះ ដើម្បីឲ្យ ឌី.ស៊ី.ខេម មានកំណត់ត្រាប្រវត្តិសាស្ត្រច្បាស់ណាស់ ថាតើឯកសារទាំងនោះមានប្រភពដើមមកពីណា មុននឹងចូលមកបណ្ណសារដ្ឋានជាតិនោះ។ តើលោកមានសរសេរចម្លើយដែលឆ្លើយទៅនឹងសំណួររបស់លោកនេះមានកត់ត្រាទុកទេ?

**ឆ៖** បាទ ជាការងាយស្រួលទេ ព្រោះដោយសារថា បណ្ណសារជាតិនេះនៅតែនៅទីក្រុងភ្នំពេញ ហើយជាស្ថាប័នដែលផ្ទុកឯកសារ ហើយទោះបីជាយើងបានសួរ យើងអត់បានកត់ត្រាទេ ដោយសារបណ្ណសារនេះជាស្ថាប័នមួយ ដែលមានរហូតមកដល់សព្វថ្ងៃ។

[០៩:៥០:០០]

**សៈ** បើសិនជាខ្ញុំយល់លោកមិនច្រឡំទេ មជ្ឈមណ្ឌលឯកសារកម្ពុជា មិនដែលបានទទួលព័ត៌មានណាមួយ ឬក៏មិនដែលបានសំណួរណាមួយ ថាតើបណ្ណសារដ្ឋានជាតិនេះបានទទួលឯកសារទាំងនេះមករក្សាទុកនៅទីនោះដោយរបៀបណានោះទេ មែនទេ?

**ឆ៖** យើងពិតជាបានសួរ ប៉ុន្តែយើងមិនបានកត់ត្រាទុកទេ ហើយដោយសារហេតុផលនេះ គឺដោយសារយើងយល់ថា បណ្ណសារជាតិនេះគឺនៅមានជាស្ថាប័ននៅឡើយ ហើយបើសិនជាមានការចង់សួរបញ្ជាក់បន្ថែមអីនោះ គឺមានស្ថាប័ននេះនៅទីនេះ។

**សៈ** ដូច្នេះបើកាលណានិយាយអំពីការរក្សាទុកឯកសារនេះ គឺថាតើលោកទទួលឬក៏ ឌី.ស៊ី.ខេម បានទទួលដោយរបៀបណា? គឺប្រសិនណាយើងនិយាយអំពីយថាភាពនៃឯកសារនៅ ឌី.ស៊ី.ខេម គឺលោកចង់ឲ្យខ្ញុំទៅសួរនៅបណ្ណសារដ្ឋានជាតិទៅវិញ។ តើនេះជាសំណួររបស់លោកមែនទេ?

[០៩:៥១:១២]

**ឆ៖** នៅពេលដែលទៅទទួល នៅពេលដែលទៅប្រមែប្រមូលឯកសារ និងទទួលឯកសារនៅបណ្ណសារដ្ឋាននេះ គឺយើង--

**ស៖** លោកគ្រាន់តែឆ្លើយសំណួររបស់ខ្ញុំ មិនបាច់ចាំពន្យល់ទេ។ អ្វីដែលលោកប្រាប់ខ្ញុំនោះ គឺថាលោកឲ្យខ្ញុំទៅបណ្ណសារដ្ឋានជាតិ ដើម្បីទៅសួរសំណួរទាំងឡាយ ដើម្បីបានចម្លើយ ដែលខ្ញុំចង់បានពាក់ព័ន្ធទៅនឹងយថាភាពនៃឯកសារ។ នេះគឺជាអ្វីដែលលោកកំពុងប្រាប់ខ្ញុំមែនទេ?

**ឆ៖** ខ្ញុំបានឆ្លើយអំពីយថាភាពនៃឯកសារនូវឯកសារដែលប្រមូលបានមកពីបណ្ណសារដ្ឋានជាតិ ហើយបើសិនជាលោកមានចេតនាចង់ធ្វើដូច្នេះ គឺជាអាស្រ័យទៅលើលោកមេធាវីផ្ទាល់បាទ។

**ស៖** លោក មជ្ឈមណ្ឌលឯកសារកម្ពុជា គាត់ទទួលបានឯកសារពីបុគ្គលម្នាក់ៗផងដែរ គឺឯកសារដែលបានទទួលពីបុគ្គលឯកជនណាម្នាក់ ដោយយកមកដាក់រក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាតែម្តង។ តើមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

[០៩:៥២:៣២]

**ស៖** ទាក់ទងទៅនឹងបុគ្គលឯកជនទាំងនោះ ឬក៏អង្គការណាមួយ ឧទាហរណ៍និយាយអំពីរដ្ឋាភិបាលកម្ពុជាទៅចុះ ឬក៏និយាយអំពីអ្នកសិក្សាស្រាវជ្រាវណាម្នាក់ ដែលថាមជ្ឈមណ្ឌលឯកសារកម្ពុជាមានពិធីសាររបស់ខ្លួន ដែលខ្លួនបានស្នើសុំទៅម្ចាស់ជំនួយ។ ថាតើខ្លួនបានទទួលឯកសារទាំងនេះមកពីណា? ទទួលបានក្នុងស្ថានភាពបែបណា? នៅពេលមុនរក្សាទុកដើម្បីឲ្យទទួលបានប្រវត្តិសាស្ត្រមួយឲ្យច្បាស់លាស់ពី តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា។ ថាតើឯកសារនោះមានប្រភពដើមមកពីណា? អ៊ីចឹងតើម្ចាស់ជំនួយនោះ គេមានដែលសួរមកដូច្នេះទេ?

[០៩:៥៣:២០]

**ឆ៖** នៅពេលដែលទទួលឯកសារ មានឯកសារខ្លះគឺខ្ញុំបានទទួលដោយផ្ទាល់ដែទេ មានឯកសារខ្លះទទួលដោយលោកប្រធានរបស់ខ្ញុំ ហើយបើសិនជាឯកសារណាដែលទទួលលោកប្រធានខ្ញុំ សូមមេត្តាចោទសំណួរនេះទៅលោកប្រធានខ្ញុំ ហើយប្រហែលជាលោកអាចនឹងស្នើសុំទៅអង្គជំនុំជម្រះដើម្បីអញ្ជើញលោកប្រធានខ្ញុំមកឆ្លើយបំភ្លឺ ព្រោះខ្ញុំមិនអាចនឹងដឹងបានទាំងអស់នោះទេ។

**ស៖** ឥឡូវសូមជួយឆ្លើយមកខ្ញុំ គឺអ្វីដែលលោកកំពុងតែប្រាប់មកខ្ញុំនោះ គឺថាមិនមានពិធីសារកំណត់ច្បាស់លាស់ គឺថានីតិវិធីកំណត់នៅច្បាស់លាស់ទេ ថានៅពេលដែលទទួលបានឯកសារមក គឺត្រូវមានរៀបចំជាសំណួរ ដែលនាំឲ្យឈានទៅដល់ការរកឃើញនូវការរក្សាទុកនូវឯកសារនីមួយៗនោះ។ មិនមានទេឬ?

**ឆ៖** យើងបាន វាអាស្រ័យទៅលើឯកសារមួយៗដែរ គឺថាយើងបានសួរនាំអំពីឯកសារនោះមុននៅពេលដែលយើងទទួលបាន។

**ស៖** ឥឡូវនិយាយរូបលោកទៅចុះ ឧទាហរណ៍ថា តើលោកមានបានសួរថាតើឯកសារទាំងនេះអ្នកឯង ឬក៏រកឃើញបានមកពីណា? លោកមានបានសួរអ៊ីចឹងទេ?

[០៩:៥៥:00]

**ឆ៖** ខ្ញុំឆ្លើយ ចំពោះឯកសារដែលខ្ញុំបានទទួល គឺជាពិសេសគឺនៅបណ្ណសារជាតិ ឬក៏នៅទួលស្លែង។ ខ្ញុំបានសួរសំណួរនេះ ហើយចម្លើយគឺថាអ្នកដែលឆ្លើយក៏អត់ដឹងដែរ។ ខ្ញុំបានចម្លើយអ៊ីចឹង។

**ស៖** បើសិនជាខ្ញុំយល់លោកមិនច្រឡំទេ គឺលោកប្រមូលឯកសារមកពីបណ្ណសារជាតិ ពីទួលស្លែង ក៏ដូចពីអ្នកសិក្សាស្រាវជ្រាវដោយផ្ទាល់ខ្លួនលោកតែម្តងមែនទេ?

**ឆ៖** ចំពោះឯកសារដែលទទួលបានពីអ្នកស្រាវជ្រាវនេះ គឺភាគច្រើន គឺលោកប្រធានរបស់ខ្ញុំគាត់ទទួលបាន គាត់មានទំនាក់ទំនង។

**ស៖** តើខ្លួនលោកផ្ទាល់ មានដែលបានទទួលឯកសារណាមួយពីអ្នកសិក្សាស្រាវជ្រាវណាម្នាក់ពី*ស្តូឡា* ណាម្នាក់ដែរឬទេ?

**ឆ៖** ខ្ញុំ អឺ ឯកសារបែបនេះ គឺខ្ញុំតែងតែទទួលបានពីលោកប្រធានរបស់ខ្ញុំឲ្យយកមកធ្វើការរៀបចំ និងកាតាឡុក ទុកនៅក្នុងមជ្ឈមណ្ឌល។

**ស៖** ដោយសារតែលោកធ្វើការជិតដិតជាមួយប្រធានរបស់លោក ថាតើប្រធានរបស់លោកមាននីតិវិធីដែលត្រូវចោទសួរនូវសំណួរដែលខ្ញុំកំពុងសួរទៅលោក ដើម្បីចង់ឲ្យដឹងថាតើខ្សែចង្វាក់នៃការរក្សាទុកឯកសារនោះរបៀបណា? អ្នកណាប្រគល់ឯកសារ? អ្នកណារកឃើញនៅទីណា? ហើយរកឃើញហើយ អ្នកនោះរក្សាទុកដោយរបៀបណា? តើលោកមានដឹងថា លោកយុ ឆាំង មាន*ប្រូតូកូល* បែបនេះ ឬក៏លោកខ្លួនលោកផ្ទាល់មាន*ប្រូតូកូល* បែបនេះ ដើម្បីសួរ ឬក៏បុគ្គលិកនោះ ឬក៏អ្នកសិក្សាស្រាវជ្រាវ ដើម្បីឲ្យអ្នកសិក្សាស្រាវជ្រាវ ឬក៏បុគ្គលិក អាចធ្វើការៗវិភាគទៅលើឯកសារទាំងនេះ មុននឹងទទួលយកអត់?

[០៩:៥៧:០៧]

**ឆ៖** ខ្ញុំមិនបានដឹងអស់អំពីកិច្ចការរបស់លោកនាយក យុ ឆាំង ទេ។

**ស៖** តើនេះមានន័យថា លោកមិនបានដឹងថាតើគាត់មាននីតិវិធីណាមួយច្បាស់លាស់នោះទេ

មែនទេ?

**ឆ៖** ជាការត្រឹមត្រូវ។

**ស៖** ដោយសារលោកបញ្ជាក់ថា ឯកសារដែលលោកទទួលមកពីអ្នកសិក្សាស្រាវជ្រាវតាមធម្មតា លោកទទួលតាមរយៈនាយករបស់លោក នៅពេលលោកទទួលឯកសារនេះ ថាតើមានចំណារណាមួយ ឬក៏មានកំណត់ត្រាណាមួយដែលត្រូវដាក់សរសេរទៅលើសំណុំឯកសារ ឬក៏ *ហ្វាល* ណាមួយទេ នៅពេលដែលនាយករបស់លោកបញ្ជាក់ នៅពេលដែល-- នៅពេលគាត់ ៗដែលបានប្រាប់ថាតើគាត់ទទួលឯកសារនោះមកពីណា? ហើយគាត់មានសួរសំណួរបែបនេះទៅកាន់អ្នកដែលប្រគល់មកទេ? តើលោកមានដែលបានជួបថា ប្រធានរបស់លោកសួរសំណួរបែបនេះដែរឬទេ?

**ឆ៖** ជាទូទៅ បើសិនជាឯកសារនេះទទួលបានដោយលោកនាយករបស់ខ្ញុំ គឺខ្ញុំទទួលពីលោកនាយករបស់ខ្ញុំយកទៅធ្វើការចាត់ចែង ត្រង់លោកនាយករបស់ខ្ញុំសួរនាំ អាហ្នឹងជារឿងមួយផ្សេងទៀត ហើយលោកក៏អាចចោទសួរទៅលោកប្រធានរបស់ខ្ញុំបាន។

[០៩:៥៨:៤៥]

**ស៖** ខ្ញុំគ្រាន់តែចង់សួរទៅលោកឲ្យច្បាស់ ដើម្បីឲ្យខ្ញុំទទួលបានចម្លើយឲ្យបានច្បាស់តែប៉ុណ្ណោះទេ។ ឧបមាថា ប្រធានរបស់លោកបានសួរសំណួរទាំងឡាយដូចដែលខ្ញុំសួរលោកអ៊ីចឹង។ ឧទាហរណ៍ថា គាត់ធ្លាប់បានសួរប្រភពឯកសារ ប្រភពឯកសារមកពីណា? ហើយឯកសារត្រូវបានគេរកឃើញដោយរបៀបណា? នៅពេលណា? រកឃើញដោយរបៀបណា? តើនាយករបស់លោកមានកាតព្វកិច្ចផ្តល់ព័ត៌មានទាំងអស់នេះ ហើយសរសេរនូវលក្ខណៈវិនិច្ឆ័យទាំងអស់នេះភ្ជាប់ទៅនឹងឯកសារដើម្បីឲ្យអ្នកសិក្សាស្រាវជ្រាវទទួលបានព័ត៌មានទាំងអស់នេះដែរឬអត់?

**ឆ៖** បាទលោកមេធាវី បានសួរខ្ញុំថា ឧបមាថា ខ្ញុំនឹងមានការពិបាកឆ្លើយឲ្យបានច្បាស់លាស់អំពីពាក្យថា ឧបមាថា ព្រោះខ្ញុំឮការបកប្រែយ៉ាងដូច្នេះ។

[០៩:៥៩:៤៨]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយនឹងសំណួរនេះទេ! ហើយមេធាវីមិនអាចប្រើសំណួរឧបមា ឧបមាណវិធីមកតាំងសំណួរចំពោះសាក្សីបានទេ។

បញ្ហានេះអង្គជម្រះបានរំឭកតាំងពីដំបូងនៅក្នុង ចាប់ផ្តើមកិច្ចដំណើរការសវនាការ គឺបានរំឭក

អំពីការហាមប្រាមមិនឲ្យប្រើប្រាស់នូវការតាំងសំណួរមួយចំនួន សំណួរត្រួតគ្នា សំណួរដឹកមុខ ហើយសំណួរឧបមាណវិធីជាដើម។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** អ៊ីចឹងខ្ញុំសូមចោទសួរឲ្យចំៗតែម្តង។ តើខ្លួនលោកផ្ទាល់ធ្លាប់បានសួរសំណួររបៀបនេះទេ នៅពេលណាឯកសារទាំងនោះធ្លាក់មកពីដៃរបស់អ្នកសិក្សាស្រាវជ្រាវនោះ? ហើយយកសំណួរទាំងអស់នេះទៅភ្ជាប់ទៅនឹងឯកសារ ដើម្បីឲ្យអ្នកណាក៏ដោយដែលប្រើប្រាស់ឯកសារទាំងអស់នេះ មានកំណត់ត្រាច្បាស់លាស់ ថាតើឯកសារទាំងអស់នោះរកឃើញដោយរបៀបណា ដោយស្ថានភាពណា នៅពេលណាជាដើម។ល។

**ឆ៖** ចំពោះឯកសារ បើសិនជាលោកមេធាវីបង្ហាញឯកសារនោះ ខ្ញុំអាចបានដឹងថាតើ ឯកសារមួយណាដែលខ្ញុំបានទទួលនោះ បើសិនជាសួរបែបនេះវាមានលក្ខណៈទូលំទូលាយ ហើយខ្ញុំនឹងឆ្លើយជាដដែលថា ឯកសារដែលផ្តល់ដោយអ្នកសិក្សាស្រាវជ្រាវនោះ គឺភាគច្រើនខ្ញុំបាននិយាយហើយថាជាឯកសារដែលប្រគល់ជូនលោកនាយករបស់ខ្ញុំ ហើយនៅពេលដែលបានទទួលដោយ-- ឯកសារនោះហើយគឺលោកនាយករបស់ខ្ញុំ បានប្រគល់ជូនខ្ញុំឲ្យធ្វើការចាត់ចែងចុះលេខ និងទុកដាក់។

[១០:០១:៣៧]

**ស៖** ដូច្នេះមានតែនាយករបស់លោកទេ ដែលទទួលឯកសារទើបបានលោកមិនអាចឆ្លើយនឹងឯកសារខ្ញុំបាននោះ?

**ឆ៖** គឺខ្ញុំនិយាយអំពីឯកសារដែលប្រគល់ដោយអ្នកសិក្សាស្រាវជ្រាវ ដែលលោកបានសួរខ្ញុំអំពីឯកសារបែបនេះ។

**ស៖** ដូច្នេះ ខ្ញុំចង់សួរថា ប្រសិនបើអ្នកសិក្សាស្រាវជ្រាវផ្តល់លោក នូវឯកសារ។ ខ្ញុំសូមសួរថាថ្មី ថាតើអ្នកសិក្សាស្រាវជ្រាវមានដែលធ្លាប់ ផ្តល់ឯកសារជូនលោកដែរឬទេ? ឬក៏លោក យុ ឆាំង ធ្លាប់បានទទួលឯកសារពីអ្នកសិក្សាស្រាវដែរឬទេ?

**ឆ៖** ជាដដែលលោកបានសួរខ្ញុំថា តើលោក យុ ឆាំង ដែលទទួលបានឯកសារពីអ្នកស្រាវជ្រាវដែរឬទេ? ខ្ញុំសូមបញ្ជាក់សំណួរនេះ តើជាសំណួរដែលលោកចោទសួរអ៊ីចឹងឬ? អ៊ីចឹងសូម--

**ស៖** ខ្ញុំសួរថាតើលោកធ្លាប់ទទួលឯកសារពីអ្នកសិក្សាស្រាវជ្រាវដែរឬទេ? តើលោកធ្លាប់ទទួលឯកសារពីអ្នកសិក្សាស្រាវជ្រាវដែរឬទេ?

[១០:០៣:០៩]

**ឆ៖** ខ្ញុំមិនធ្លាប់បានទទួលឯកសារផ្ទាល់ដៃពីអ្នកសិក្សាស្រាវជ្រាវទេ។

**ស៖** ដូច្នេះតាមការយល់ដឹងរបស់លោក ដើម្បីបញ្ជាក់ចម្លើយឱ្យបានច្បាស់លាស់ តាមការយល់ដឹងរបស់លោក គឺមិនមាននីតិវិធីដែលគេកំណត់ឡើង ដើម្បីសួរទៅលើខ្សែចង្វាក់នៃការរក្សាកាន់កាប់ឯកសារនោះទេ នៅពេលដែលឯកសារតួមកពីប្រភពផ្សេងៗ ដូចជា ទទួលមកពីអ្នកសិក្សាស្រាវជ្រាវជាដើម។ តើមែនដែរឬទេ?

**ឆ៖** អ្នកដែលទទួលឯកសារបែបនេះ បើតាមខ្ញុំអាចយល់បាន គឺបានសួរបាទ។

**ស៖** សំណួរចុងក្រោយមួយទៀត។ បន្ទាប់មកយើងនឹងសួរអំពីឯកសារផ្សេងទៀត។ ពាក់ព័ន្ធទៅនឹងរដ្ឋាភិបាល លោកបានលើកឡើងថា ឯកសារមួយចំនួនយកមកពីរដ្ឋាភិបាល លោកទៅដល់ជួបប្រទះឯកសារហ្នឹងនៅទីណាមួយ? ឬក៏រដ្ឋាភិបាលជាអ្នកផ្តល់ជូនមកកាន់ស្ថាប័នរបស់លោក?

**ឆ៖** ខ្ញុំបានទៅផ្ទាល់នៅ-- ទៅទទួលឯកសារនៅក្រសួងមហាផ្ទៃ។

**ស៖** នៅពេលដែលលោកទៅដោយផ្ទាល់ទៅទទួលឯកសារ ថាតើរដ្ឋាភិបាលអនុញ្ញាតឱ្យលោកយកនូវឯកសារ ឬក៏រដ្ឋាភិបាលឱ្យលោកពិនិត្យគ្រប់ឯកសារតាមសេរីដូចនៅបណ្ណសារដ្ឋានជាតិដែរឬទេ? ឬក៏រដ្ឋាភិបាលជាអ្នកប្រគល់ឯកសារជាក់លាក់ទៅដល់លោកតែម្តង?

[១០:០៥:១៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ប្រសិនបើអនុញ្ញាត ខ្ញុំសូមលើកឡើង និងជំទាស់ទៅលើសំណួរនេះ។ ដោយសារសំណួរនេះហាក់ដូចជាមិនពាក់ព័ន្ធនោះទេ។ ថាតើរដ្ឋាភិបាលផ្តល់ជូនឯកសារ ឬក៏ផ្តល់ជូនឯកសារតាមរបៀបណា? ខុសពីបណ្ណសារដ្ឋានជាតិដែរឬទេ? គឺខ្ញុំគិតថាសំណួរបែបនេះសួរទៅកាន់សាក្សី គឺមិនពាក់ព័ន្ធឡើយ។

**លោក ម៉ៃខល កាណាវាស៖**

ប្រសិនបើអនុញ្ញាត លោកប្រធាន ខ្ញុំសូមលើកឡើង នៅពេលដែលពិនិត្យឯកសារនៅបណ្ណសារដ្ឋានជាតិ គឺជារឿងមួយ ហើយនៅពេលដែលគាត់និយាយអំពីឯកសារដែលគាត់ត្រូវទទួលនៅបណ្ណសារ

ដ្ឋានជាតិ ឬក៏នៅរដ្ឋាភិបាលជាតិនោះ គឺខ្ញុំចង់សួរថាតើរដ្ឋាភិបាល ឬក៏សមាជិករដ្ឋាភិបាលនោះ គឺផ្តល់ឯកសារតាមសេរី ដូចទៅនឹងបណ្ណសារដ្ឋានជាតិដែរឬទេ មិនថាគាត់ជានាយករដ្ឋមន្ត្រី ឬក៏បុគ្គលណាមួយនោះទេ?

[១០:០៦:១៣]

ខ្ញុំជឿថាឯកសារមួយចំនួននោះ គឺផ្តល់ជូនមកពីខាងខុទ្ទកាល័យរបស់លោក ហ៊ុន សែន ដោយផ្ទាល់។ ដូច្នេះហើយ ទើបខ្ញុំចង់សួរបញ្ជាក់ទៅលើចំណុចហ្នឹង ដោយសារតែសាក្សីបានលើកឡើងរួចមកហើយថាស្ថាប័នរបស់សាក្សី គឺអព្យាក្រឹត និងមិនលម្អៀង។ ដូច្នេះគឺយើងចង់បង្ហាញអំពីភាពជឿជាក់ និងទុកចិត្តបាន ថាតើស្ថាប័ននោះឯករាជ្យ មិនលម្អៀង និងអព្យាក្រឹតដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ជំទាស់គ្មានប្រសិទ្ធភាព ហើយសាក្សីត្រូវឆ្លើយនឹងសំណួរដែលសួរដោយមេធាវីអម្បាញ់មិញនេះ។

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

បាទ សូមមេត្តាបញ្ជាក់សំណួរម្តងទៀតទេ ព្រោះមានការឆ្លើយឆ្លងទៅវាឃ្លាតឆ្ងាយបន្តិច ហើយខ្ញុំអាចថាមិនចាំច្បាស់ចំពោះសំណួររបស់លោក។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសួរម្តងទៀត ហើយសូមរំឭកមេធាវីនៅសល់ពេលតែប្រាំបីនាទីទៀតទេ។

[១០:០៧:១៧]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំស្វាគមន៍នឹងសូមបញ្ជាក់សំណួរសាជាថ្មី។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** នៅពេលដែលលោកទៅប្រមូលឯកសារពីរដ្ឋាភិបាល មិនមែនទៅបណ្ណសារដ្ឋានជាតិទេ។ ដូច្នេះថាតើរដ្ឋាភិបាលនោះ អនុញ្ញាតដោយសេរីឱ្យលោកពិនិត្យមើលឯកសារនៅក្នុងបណ្ណសារដ្ឋានរបស់គេដែរឬទេ? ឬក៏រដ្ឋាភិបាលជាអ្នកផ្តល់ឯកសារជូនលោក តើមួយណា? ចម្លើយមួយណា? បាទ សូមលោកឆ្លើយ។

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** ដោយសារមានការអនុញ្ញាតពីរាជរដ្ឋាភិបាលនេះហើយ ដែលយើងអាចទៅបានគ្រប់ទីកន្លែង

ហើយយើងបានជម្រាបច្បាស់ថា យើងនឹងមានបំណងប្រមែប្រមូលឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឬទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ។

[១០:០៨:១៣]

**ស៖** សូមអរគុណ។ តើមានការព្យាយាមចូលទៅបណ្ណសារដ្ឋានរបស់ព្រះមហាក្សត្រដែរឬទេ ដែលថាបណ្ណសារដ្ឋានរបស់ព្រះមហាក្សត្រនេះអាចមានឯកសារសម្រាប់របបដែលបានកើតឡើងសម្រាប់ខាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី--

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ ឌី.ស៊ី.ខេម គឺមិនមានកាតព្វកិច្ចក្នុងការស្វែងរកព័ត៌មានទៅលើការចោទប្រកាន់ដូចសហចៅក្រមស៊ើបអង្កេតនោះទេ។ យើងដឹងថាមានដំណើរការស៊ើបអង្កេតយ៉ាងយូរមកហើយ។ ហើយប្រហែលជាសាក្សីនេះអាចត្រូវបានបង្គាប់ឲ្យសួរសំណួរថា តើគេបានទៅបណ្ណសារដ្ឋានជាតិណាមួយក្រៅពីសំណួរដែលបានលើកឡើងជាក់លាក់។

**លោក ម៉ៃខល កាណាវ៉ាស៖**

លោកប្រធាន គឺខ្ញុំសូមលើកឡើង គឺមិនមានគំនិតណាមួយដែលលើកឡើងថាមានការស៊ើបអង្កេតឯកសារពីភាគី ឬការិយាល័យស្ថាប័នណាមួយនោះទេ។ យើងគ្រាន់តែចង់សួរបណ្ណសារដ្ឋានរបស់ព្រះមហាក្សត្រតែប៉ុណ្ណោះ។ ហើយសំណួររបស់យើង គឺស្របទៅនឹងអ្វីដែលយើងបានសួរ ហើយខ្ញុំសូមសួរសំណួរឡើងវិញ។ ខ្ញុំសូមសួរថា ថាតើសាក្សីមានការព្យាយាមដើម្បីទៅរកមើលឯកសារនៅក្នុងបណ្ណសារដ្ឋានរបស់ព្រះមហាក្សត្រដែរឬទេ?

[១០:០៩:៥០]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់សហព្រះរាជអាជ្ញាគ្មានប្រសិទ្ធភាព ហើយសាក្សីឆ្លើយនឹងសំណួរដែលសួរដោយមេធាវី។

**លោក វ៉ាន់ថាន់ ពៅដារ៉ា៖**

**ឆ៖** បាទអរគុណ។ ខ្ញុំមិនបានទៅស្វែងរកបណ្ណសារ ឯកសារនៅបណ្ណសាររបស់ព្រះមហាក្សត្រទេ។ ហើយខ្ញុំក៏មិនដឹងថាបណ្ណសារនៅទីណាផង។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** តើមានសំណើបានធ្វើឡើងដែរឬទេ? លោកបានលើកឡើងរួចមកហើយ តាមអ្វីដែលលោកដឹងតើមានសំណើពីខាង ឌី.ស៊ី.ខេម សុំចូលទៅមើលបណ្ណសារដ្ឋានរបស់ព្រះមហាក្សត្រដែរទេ? ប្រសិនបើលោកថាអត់ដឹងទេ គ្រាន់តែជម្រាបថាអត់ដឹងទៅបានហើយ។

**ឆ៖** ខ្ញុំមិនដឹងទេ។

**ស៖** តើលោកបានដឹងថា មានការព្យាយាមចូលទៅបណ្ណសារដ្ឋានរបស់រដ្ឋាភិបាលបរទេសដូចជា រដ្ឋាភិបាល ដូចជាស្ថានទូតរបស់អាមេរិក វៀតណាម ចិន ដែរឬទេ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា លោកនាយមកមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើលិខិតជាការអំពាវនាវដល់ប្រទេសទាំងឡាយណា បើសិនជាមានឯកសារទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏អំពីរបបកម្ពុជាប្រជាធិបតេយត្យនេះ សូមផ្ញើមកឲ្យ សូមផ្តល់មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ឬផ្តល់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ហើយបើសិនជាខ្ញុំចាំបានច្បាស់នោះ គឺលិខិតហ្នឹងចេញនៅក្នុងឆ្នាំ២០០៥។

[១០:១១:៤៣]

**ស៖** ដូច្នេះ តើមានអ្វីកើតឡើងនៅពេលដែលចេញលិខិតនេះបញ្ជូនទៅដល់រដ្ឋាភិបាលអាមេរិក ចិន និងវៀតណាមនោះ តើមានលទ្ធផលអីឆ្លើយតបដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងថា តើនេះមិនមែនជាលិខិតដែលផ្ញើ គឺជាការអំពាវនាវ ហើយខ្ញុំមិនបានដឹងថា តើការអំពាវនាវនេះបានទៅដល់ប្រទេសណាខ្លះទេ ខ្ញុំមិនដឹងទេ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំៗសូមអរគុណអង្គជំនុំជម្រះដែលមានការអត់ឱនចំពោះខ្ញុំ។ តើលោកដឹងដែរឬទេថា តើលោក ឆាំង យុ តាំងនាមឲ្យ ឌី.ស៊ី.ខេម បានអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាដើម្បីជំរុញឲ្យរដ្ឋាភិបាលបរទេសទាំងនោះដូចជា រដ្ឋាភិបាលអាមេរិក វៀតណាម ចិន ឲ្យសហការហើយបើកចំហទ្វារបណ្ណសារដ្ឋានរបស់ខ្លួន ដើម្បីឲ្យ ឌី.ស៊ី.ខេម នេះចូលទៅស្រាវជ្រាវព័ត៌មាននៅក្នុងនោះដែរឬទេ?

[១០:១៣:០៣]

**ឆ៖** ជាថ្មីម្តងទៀត គឺស្នើសុំលោកមេធាវីសួរផ្ទាល់ទៅលោកនាយក ឆាំង យុ តែម្តងទៅ។

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណច្រើន លោកសាក្សី។ សូមអរគុណ អង្គជំនុំជម្រះ ក្រុមប្រឹក្សាជំនុំជម្រះ ខ្ញុំសូមអរគុណដែលបានផ្តល់នាទីឲ្យខ្ញុំមួយ ឬពីរបីនាទីបន្ថែមទៀតនេះ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ហើយជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ប្រសិនបើមាន។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

លោកប្រធាន ដោយសារពេលវេលារបស់យើងនេះហើយ តើអាចសម្រាកសិន ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បន្តការសួរទៅ!

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមគោរពក្រុមប្រឹក្សាជំនុំជម្រះ ហើយតទៅនេះខ្ញុំសូមតាំងសំណួរចំពោះសាក្សី។ ជាបឋមសូមជម្រាបសួរលោក វ៉ាន់ថាន់ ពៅដារ៉ា។

**ស៖** តើខ្ញុំអាចហៅលោកថាជា ដារ៉ា ឬពៅដារ៉ា?

**លោក វ៉ាន់ថាន់ ដារ៉ាពៅ ៖**

**ឆ៖** បាទ ចំពោះឈ្មោះមួយណាក៏បាន។

**ស៖** អ៊ីចឹងខ្ញុំបាទសូមហៅលោកថា លោក ដារ៉ា ហើយខ្ញុំនឹងសុំសួរអំពីប្រវត្តិរបស់លោកខ្លះដើម្បីបញ្ជាក់បន្ថែម។ លោកបានធ្វើការនៅក្នុង ឌី.ស៊ី.ខេម តាំងពីឆ្នាំ១៩៩៥ អ៊ីចឹងមែនទេ លោកបានឆ្លើយកន្លងមក?

[១០:១៥:00]

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** ហើយលោកបានជម្រាបថា លោកបានធ្វើការនៅទីនោះរយៈពេល១៧ឆ្នាំហើយ មកដល់ឥឡូវនេះ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយបច្ចុប្បន្ននេះលោកមានតួនាទីជានាយករងនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១០:១៥:២៥]

**ស៖** តើលោកអាចជម្រាបបានទេថា លោកធ្វើជានាយករងហ្នឹងពីពេលណាមក តាំងពីចាប់ផ្ដើម ឬមួយក៏ពេលក្រោយ?

**ឆ៖** ខ្ញុំបានធ្វើជានាយករងមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឆ្នាំ២០០៥។

**ស៖** តាមការឆ្លើយបញ្ជាក់របស់លោកកន្លងមក លោកបានទៅសិក្សានៅបរទេស ហើយដែលជាប្រទេសប្រើភាសាអង់គ្លេស អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** អ៊ីចឹង លោកអាចប្រើប្រាស់ភាសាអង់គ្លេសបានក្នុងកម្រិតមួយដែលលោកបានបញ្ជាក់ច្រើនដងនៅក្នុងសវនាការនេះ ហើយខ្ញុំបានដឹងថា លោកពេញចិត្តនឹងប្រើភាសាខ្មែរជាង។ អ៊ីចឹងមែនទេ?

[១០:១៦:១០]

**ឆ៖** ដោយសារភាសាខ្មែរជាភាសាដើមកំណើតរបស់ខ្ញុំ ហើយខ្ញុំមានជឿជាក់ មានជំនឿជាក់ជាងភាសាអង់គ្លេស។

**ស៖** អ៊ីចឹង បើសិនជាខ្ញុំសូមឲ្យលោកអាននូវពាក្យជាភាសាអង់គ្លេស លោកមិនថាអីទេមែនទេ?

**ឆ៖** ខ្ញុំសូមមេត្តារក្សានូវការអានជាភាសាខ្មែរជាជាង ដើម្បីជាការងាយស្រួលសម្រាប់ខ្ញុំផង។

**ស៖** ដោយសារមានបញ្ហាខ្លះ ដែលភាសាដើមនោះជាភាសាអង់គ្លេស ហើយដែលខ្ញុំគិតថាអាចសួរចំពោះឯកសារនេះ។ អ៊ីចឹងបើសិនជាលោកសហការ ខ្ញុំនឹងឲ្យលោកជួយអាន ឬមួយក៏មានអ្នកបកប្រែជួយបន្ថែមផងដែរ។

[១០:១៧:០៧]

ខ្ញុំបាទ សូមសួរអំពីប្រវត្តិរបស់អង្គការរបស់លោក មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំបានឮថាអង្គការរបស់លោកបានចេញពីការិយាល័យរបស់សាកលវិទ្យាល័យយ៉េល។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** សូមលោកប្រាប់ឈ្មោះការិយាល័យនោះផង បានទេ?

**ឆ៖** ជាការិយាល័យសិក្សាស្រាវជ្រាវ អំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ នេះជា-- បាទ សូមបន្ថែម គឺនេះជាការកម្មវិធីរបស់ កម្មវិធីមួយនៃការសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យយែល។

**ស៖** ជាភាសាអង់គ្លេសមានន័យថាម៉េចដែរលោក? អាចបញ្ជាក់បានទេ?

[១០:១៨:០៣]

**ឆ៖** ខ្ញុំបានឃើញនៅក្នុងឯកសារដែរ គឺគេប្រើពាក្យ *ខេមបូឌា ដេណូសាយ ប្រូក្រាម*។

**ស៖** បើអ៊ីចឹង ក្នុងដំណាក់ដំបូងនោះ គឺអង្គការរបស់លោកមានប្រវត្តិជាឈ្មោះមួយថា *"ខេមបូឌាន ដេណូសាយ ប្រូក្រាម"* ជាភាសាអង់គ្លេស។ អ៊ីចឹងមែនទេបាទ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា ពេលចូលមកដល់ធ្វើការនៅឆ្នាំ១៩៩៥ គឺត្រូវបានហៅថា មជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** សូមទោសលោកបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង កើតឡើងនៅឆ្នាំ១៩៩៥ អ៊ីចឹងមែនទេអម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំអត់បាននិយាយអ៊ីចឹងទេ។

**ស៖** អ៊ីចឹងលោកនិយាយថាម៉េចមុនហ្នឹងអំមិញ?

**ឆ៖** ខ្ញុំបាននិយាយថា ពេលដែលខ្ញុំមកចូលធ្វើការ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងឆ្នាំ៩៥ គឺកន្លែងហ្នឹងគេហៅថា មជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមតាំងសំណួរមួយចំនួនទាក់ទងទៅនឹងការប្រមូលឯកសាររបស់មជ្ឈមណ្ឌលកម្ពុជា ដែលលោកបានមានប្រសាសន៍ខាងដើម បញ្ជាក់អង្គសវនាការថា អង្គការរបស់លោក គឺប្រមូលឯកសារ។ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត គឺថាមជ្ឈមណ្ឌលឯកសារកម្ពុជា គឺប្រមូលនិងចងក្រងឯកសារ។

**ស៖** អីគេ? ប្រមូលនិងចងក្រងឯកសារ?

**ឆ៖** បាទ។

**ស៖** លោកអាចបញ្ជាក់បានទេថា លោកប្រមូលឯកសារទាំងអស់នោះដើម្បីអ្វីដែរ?

[១០:២០:០០]

**ឆ៖** ប្រមូលឯកសារ គឺដើម្បីដល់ការចងចាំ និងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈការសិក្សាស្រាវជ្រាវ ហើយមួយទៀត គឺដើម្បីបម្រើដល់គោលបំណងយុត្តិធម៌ គឺមានន័យថា

សម្រាប់ផ្តល់ឯកសារដល់ជនទាំងឡាយណាដែលចង់ប្រើប្រាស់ឯកសារនេះនៅក្នុងការស្វែងរកយុត្តិធម៌។

**ស៖** ការប្រើប្រាស់ក្នុងគោលបំណងយុត្តិធម៌ ដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ គឺក្នុងទិសដៅដើម្បីចោទប្រកាន់ ឬមួយយ៉ាងម៉េច?

**ឆ៖** ខ្ញុំបានផ្តល់ឯកសារនេះតាមការចង់បានរបស់អ្នកចង់បានបាទ មិនមានការចោទប្រកាន់អីនោះទេ។

**ស៖** ខ្ញុំសូមបង្ហាញឯកសារ-- សុំសួរពីអត្ថបទឯកសារមួយ អម្បាញ់មិញខ្ញុំបានឮលោកមានប្រសាសន៍ដែរថា លោកបានឃើញមានសេចក្តីអំពាវនាវពីលោកប្រធានរបស់លោក ដើម្បីសុំឲ្យផ្តល់ឯកសារពាក់ព័ន្ធទៅនឹងខ្មែរក្រហម។ តើលោកមានប្រសាសន៍អ៊ីចឹង ទាក់ទងនឹងចំណុចហ្នឹងមែនទេអម្បាញ់មិញ ពេលដែលលោកមេធាវីម៉ែខល កាណាវ៉ាសសួរលោក?

**ឆ៖** លោកអាចរកឃើញឯកសារនេះផងដែរនៅក្នុងគេហទំព័រ។

**ស៖** ខ្ញុំបានឃើញឯកសារហ្នឹងបោះពុម្ពនៅក្នុងអត្ថបទរបស់ទស្សនាវដ្តីស្វែងរកការពិត មានលេខពិសេស ជាភាសាអង់គ្លេស ហើយបោះពុម្ពនៅត្រីមាសទីពីរ ឆ្នាំ២០០៥។

[១០:២២:២០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមឲ្យលោកមេធាវីបង្ហាញឯកសារ នៅពេលដែលគាត់លើកឡើងយកមកពិភាក្សាជាមួយនឹងសាក្សី។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសូមបង្ហាញអត្តសញ្ញាណឯកសារ ដើម្បីក្នុងការសួរពាក់ព័ន្ធនឹងឯកសារសួរទៅសាក្សី។ អម្បាញ់មិញនេះយើងបានសម្រេចរួចហើយ អំពីឯកសារគឺត្រូវមានការចាត់បញ្ចូលទៅក្នុងសំណុំរឿងតាមនីតិវិធី រវាងឯកសារភស្តុតាងដែលមាននៅក្នុងសំណុំរឿងស្រាប់ ហើយនិងឯកសារភស្តុតាងថ្មី ដែលត្រូវអនុវត្តវិធានភស្តុតាង ដែលមានចែងនៅក្នុងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ ប្រសិនបើឯកសារថ្មី ដែលស្នើសុំ គឺត្រូវស្នើសុំមុន ដោយបង្ហាញតាមមូលហេតុទាំងឡាយដែលមានចែងនៅក្នុងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ហើយក៏ពាក់ព័ន្ធផងដែរទៅនឹងវិធាន៨៧(៣) អង្គជំនុំជម្រះសម្រេចជាមុន នោះទើបឯកសារភស្តុតាងហ្នឹងអាចដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះបាន។

ដោយឡែកឯកសារដែលយកមកដាក់ដេញដោលនៅពេលនេះ គឺឯកសារដែលមាននៅក្នុងសំណុំ

រឿង ជាពិសេសគឺឯកសារដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការសវនាការដេញដោលនៅក្នុងដំណាក់កាលដំបូងនៃកិច្ចដំណើរការសវនាការសំណុំរឿង០០២ ដែលយើងឲ្យឈ្មោះមួយទៀតថាសំណុំរឿង០០២/១។

[១០:២៣:៥៤]

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំបាទចង់បង្ហាញថា ឯកសារដែលយើងខ្ញុំកំពុងនិយាយនេះ វាជាឯកសារព័ត៌មានទូទៅ ឯកសារសាធារណៈទេ មិនមែនឯកសារនៅក្នុងសំណុំរឿងទេ។

**ប្រធានអង្គជំនុំ៖**

មិនពាក់ព័ន្ធទេ ឯកសារនោះយើងមិនអាចដាក់ទទួលយកមកឲ្យដាក់ដេញដោលនាពេលនេះទេ។

**លោក គង់ សំអុន៖**

*(មិនឮសំឡេងនិយាយ)*

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូន! ហើយនិយាយម្តងទៀត!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមបន្តសំណួរទាក់ទងទៅនឹងការ-- ចំណុចដែលលោកមានប្រសាសន៍ពីរយៈពេលពីរថ្ងៃកន្លងមកថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្វើការស៊ើបអង្កេតនោះទេ។ អ៊ីចឹង ខ្ញុំបាទចង់សួរសំណួរមួយចំនួនដើម្បីបំភ្លឺចំណុចនេះ។ សំណួរថា តើលោកអាចប្រមូលឯកសារដោយពិនិត្យទៅលើតម្លៃនៃឯកសារនោះដោយរបៀបណា បើសិនជាលោកមិនធ្វើការស៊ើបអង្កេតនោះ?

[១០:២៥:៣៨]

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** បាទ សូមលោកមេធាវីមេត្តាសួរសំណួរឲ្យបានច្បាស់ជាងនេះបន្តិចបាទ។

**សួរដោយ លោក គង់ សំអុន៖**

**ស៖** ខ្ញុំចង់សួរថា តើការប្រមូលឯកសាររបស់លោកនេះ វាជាប់ពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតដែរឬទេ? លោកអាចឆ្លើយបានទេ?

**ឆ៖** ខ្ញុំ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលឯកសារ គឺដើម្បីបម្រើជូនដល់សាធារណជនទាំងអស់

អត់មានរើសអើងទេ។

**ស៖** បាទ សំណួរសួរថា តើលោកទទួលស្គាល់ទេ ថាមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស៊ើបអង្កេតចំពោះករណីដែលពាក់ព័ន្ធទៅនឹងខ្មែរក្រហម ឬក៏កម្ពុជាប្រជាធិបតេយ្យ?

[១០:២៦:៣២]

**ឆ៖** មជ្ឈមណ្ឌលឯកសារកម្ពុជាមិនដែលប្រើប្រាស់ពាក្យថា "ស៊ើបអង្កេត" ទេ។

**ស៖** សូមអរគុណ។ លោកទទួលស្គាល់ទេ ពីកម្មវិធីមួយចំនួននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជានោះ មានចរិតលក្ខណៈជាការស៊ើបអង្កេត?

**ឆ៖** លោកសួរខ្ញុំឲ្យធ្វើការ-- សូមទោសបាទ លោកសួរខ្ញុំឲ្យធ្វើការវាយតម្លៃទៅលើកម្មវិធីនីមួយៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏លោកសួរខ្ញុំអំពីឯកសារ?

**ស៖** ខ្ញុំសួរលោកអំពីកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** បើសួរអំពីកម្មវិធី សូមលោកមេធាវីមេត្តាបង្ហាញឈ្មោះកម្មវិធីណាមួយ ដើម្បីឲ្យខ្ញុំអាចយល់បាន។

**ស៖** បាទ សូមអរគុណ។ ឧទាហរណ៍ កម្មវិធីមួយទាក់ទងគេហៅ "*ហ្វ័រវិនស៊ិក*" គឺ ខ្ញុំគិតថាលោកយល់ភាសានេះ គឺមានន័យថា "ការធ្វើកោសល្យវិច័យ"។ តើលោកគិតថា កម្មវិធីនេះទាក់ទងទៅនឹងការស៊ើបអង្កេតទេ?

[១០:២៧:៥១]

**ឆ៖** ការធ្វើកោសល្យវិច័យ គឺជាការធ្វើដោយក្រុមអ្នកជំនាញមួយក្រុម មិនមែនខ្ញុំទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ខ្ញុំបាទសូមទាញចំណាប់អារម្មណ៍របស់លោកទៅលើក្រុមអ្នកជំនាញរបស់លោកនោះ ថាតើក្រុមអ្នកជំនាញរបស់លោកនោះជាក្រុមអ្វី? ជាមនុស្សមកពីណា? មានសមត្ថភាពអ្វី?

**ឆ៖** បាទ បើសិនជាលោកមេធាវីអាចបង្ហាញឯកសារនោះ គឺនៅលើឯកសារនោះគឺមានឈ្មោះស្រាប់។ អ៊ីចឹងលោកមេធាវីអាចដឹងអំពីឈ្មោះអ្នកដែលធ្វើកិច្ចការងារនោះ។

**ស៖** ក្រុមរបស់លោកដែលលោកនិយាយនេះជាទីប្រឹក្សារបស់លោក ឬមួយយ៉ាងម៉េច? លោកអាចឆ្លើយបានទេ?

[១០:២៨:៥២]

**ឆ៖** ជាថ្មីម្តងទៀត ខ្ញុំសូមលោកមេធាវីបង្ហាញនូវឯកសារមួយនោះទៅ ដើម្បីឱ្យងាយស្រួលនៅក្នុងការបានឃើញថា តើអ្នកណាជាអ្នកធ្វើកិច្ចការងារមួយនោះ។

**ស៖** ខ្ញុំអត់-- លោកសូមទោស ខ្ញុំគ្រាន់តែចង់ឱ្យលោកឆ្លើយបញ្ជាក់ថា តើមានអ្នកដែលជាអ្នកជំនាញ ឬក៏ទីប្រឹក្សារបស់លោកជាអ្នកធ្វើកិច្ចការនៅក្នុង *ប្រូជេកត៍* “Project” នេះ ឬមួយក៏គ្មានទេ។ លោកអាចឆ្លើយបានទេ?

**ឆ៖** សម្រាប់ការងារធ្វើកោសល្យវិច័យនេះ បើសិនជាគ្មាន វាមិនអាចមានជាឯកសារចេញនោះទេបាទ។ អ៊ីចឹងហើយបានជាខ្ញុំស្នើសុំឱ្យលោកមេធាវីបង្ហាញឯកសារនោះទៅ ដើម្បីឱ្យឃើញថាឈ្មោះអ្នកដែលធ្វើការងារនោះ គឺនៅលើនោះតែម្តង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹងបង្ហាញ ហើយខ្ញុំ អ្វីដែលខ្ញុំចង់បាន គឺដើម្បីឱ្យលោកបញ្ជាក់ជាទូទៅសិនថា លោកទទួលស្គាល់ថាមានកម្មវិធីធ្វើកោលស្សវិច័យនេះនៅក្នុងអង្គការរបស់លោក។ លោកទទួលស្គាល់អ៊ីចឹងទេ?

[១០:២៩:៥២]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ហើយមានកម្មវិធីមួយទៀតនោះ *មេបភីង អូហ្វ ឌី ឃីលលីង ហ្វៀល*។ លោកយល់ពាក្យដែលខ្ញុំនិយាយអម្បាញ់មិញនេះទេ?

**ឆ៖** ពាក្យនេះត្រូវបានប្រើប្រាស់សម្រាប់កម្មវិធីហ្នឹងតែម្តង។

**ស៖** លោកអាចជួយបកប្រែជាភាសាខ្មែរផងបានទេ?

**ឆ៖** នៅជាភាសាខ្មែរនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺយើងប្រើប្រាស់ជា កម្មវិធីស្រាវជ្រាវនិងចងក្រងរណ្តៅសាកសពរួម។

**ស៖** លោកយល់ថាម៉េចដែរចំពោះកម្មវិធីនេះ?

**ឆ៖** កម្មវិធីនេះគឺល្អបាទ។

**ស៖** លោកគិតថា វាជាផ្នែកមួយនៃការស៊ើបអង្កេត ដែលខ្ញុំកំពុងតែសួរលោកនេះទេ?

**ឆ៖** របៀបនៃលោកមេធាវីសួរ គឺចង់សួរខ្ញុំអំពី ថាតើខ្ញុំបានវិភាគទៅលើកម្មវិធីនេះឱ្យទៅជាការធ្វើរបៀបការស៊ើបអង្កេតដែរឬទេ? មេធាវីសួរតាមរបៀបនេះឬ?

**ស៖** បាទ ខ្ញុំចង់សួរថាតើការងាររបស់កម្មវិធី *"មេបភីង អូហ្វ ឌី ឃីលលីង ហ្វៀល"* នេះវាជាការងារមួយសម្រាប់ស៊ើបអង្កេត ក្នុងករណីកម្ពុជាប្រជាធិបតេយ្យនេះដែរឬទេ?

[១០:៣១:២២]

**ឆ៖** យើងមិនមានសិទ្ធិអំណាចនៅក្នុងការធ្វើការស៊ើបអង្កេត ព្រោះស្ថាប័នមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាតុលាការទេ។

**ស៖** បាទ អរគុណ។ ខ្ញុំយល់បញ្ហានេះ ប៉ុន្តែអ្វីដែលខ្ញុំចង់បានឲ្យលោកឆ្លើយជូនក្រុមប្រឹក្សាជំនុំជម្រះហ្នឹងគឺថា តើកម្មវិធីរបស់លោកមួយនេះ វាជាផ្នែកមួយនៃការស៊ើបអង្កេត មែន ឬក៏មិនមែន?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ប្រសិនបើខ្ញុំអាច ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ។ សាក្សីលើកឡើងជាច្រើនដងហើយថា ឌី.ស៊ី.ខេម មិនមានការស៊ើបអង្កេតនោះទេ។ ដូច្នេះ សូមឲ្យមេធាវីសួរតែទៅលើកម្មវិធី និងគម្រោងនៃសកម្មភាពគម្រោងនោះបានហើយ។ ហើយធ្វើយ៉ាងណាកុំឲ្យមេធាវីការពារក្តីនោះសួរសំណួរដែលធ្វើឲ្យសាក្សីភ័ន្តច្រឡំ ហើយសាក្សីបានបញ្ជាក់រួចហើយថា ឌី.ស៊ី.ខេម មិនមានគោលបំណងក្នុងការស៊ើបអង្កេតនោះឡើយ។ សូមអរគុណ។

[១០:៣២:២៦]

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំបាទសូមបញ្ជាក់ថា មូលហេតុដែលយើងចង់បញ្ជាក់នៅពេលនេះ ដោយសារតែសាក្សីនិយាយផ្សេង ហើយយើងមានភស្តុតាងផ្សេង ដូចអ្វីដែលសាក្សីបានបញ្ជាក់ថា អង្គការរបស់លោកមិនធ្វើការស៊ើបអង្កេតទេ។ ក៏ប៉ុន្តែមានកម្មវិធីមួយចំនួន សកម្មភាពមួយចំនួននៃអង្គការនេះបញ្ជាក់អំពីការស៊ើបអង្កេត។ ដូច្នេះហើយបានជាយើងចង់លើកបញ្ជាក់ចំណុចនេះ ជូនក្រុមប្រឹក្សាជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។ លោកអាចតាំងសំណួរបាននៅក្នុងកិច្ចដំណើរការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែលោកមិនអាចសួរសំណួរណាឲ្យសាក្សីធ្វើការធ្វើសេចក្តីសន្និដ្ឋាននោះឡើយ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សំណួរមួយទៀត ទាក់ទងទៅនឹងចំណុចនេះដែរ។ មជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់បាន ហ្វឹកហ្វឺនមន្ត្រីនគរបាលដែរឬទេ?

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** ខ្ញុំចាំបាន គឺមានការហ្វឹកហ្វឺនបែបនេះ។

**ស៖** បាទ លោកបានដឹងច្បាស់អំពីកម្មវិធីនេះទេ?

[១០:៣៤:០៥]

**ឆ៖** ខ្ញុំមិនបានចូលរួមនៅក្នុងការធ្វើកម្មវិធីនេះទេ។

**ស៖** ប៉ុន្តែលោកបានគ្រប់គ្រងកម្មវិធីនេះទេ?

**ឆ៖** មានអ្នកដែលធ្វើការងារនេះផ្ទាល់ គឺមាននៅក្នុងកម្មវិធីហ្នឹងតែម្តង។

**ស៖** លោកអាចជម្រាបក្រុមប្រឹក្សាជំនុំជម្រះ អំពីខ្លឹមសារនៃការហ្វឹកហ្វឺននោះបានទេ?

**ឆ៖** ដោយខ្ញុំមិនបានចូលរួមនៅក្នុងការហ្វឹកហ្វឺននោះ ខ្ញុំមិនអាចជម្រាបបាននោះទេបាទ។

**ស៖** តើលោកអាចជម្រាបពីគោលបំណង នៃការហ្វឹកហ្វឺននោះបានទេ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា មានកម្មវិធីបណ្តុះបណ្តាលមន្ត្រីប៉ូលិស។

**ស៖** បាទ អ៊ីចឹងមានន័យថាលោកមិនបានដឹងពីគោលបំណង នៃកម្មវិធីហ្វឹកហ្វឺនមន្ត្រីប៉ូលិស នោះទេ លោកទទួលស្គាល់អ៊ីចឹងទេ?

**ឆ៖** បាទ។

**ស៖** ប៉ុន្តែនៅឆ្នាំ២០០៥ លោកធ្វើជានាយករងនៃមជ្ឈមណ្ឌលឯកសារម្ពុជា អ៊ីចឹងមែនទេ?

**ឆ៖** ជាការត្រឹមត្រូវ។

[១០:៣៥:៤២]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមសួរលោកទាក់ទងទៅនឹងការទទួលឯកសារ ដែលលោក បានបញ្ជាក់ជូនអង្គសវនាការច្រើនដងរួចមកហើយថា លោកបានធ្វើយថាភាពនៃឯកសារនោះ។ តើ លោកបានឆ្លើយថា លោកបានធ្វើយថាភាពអ៊ីចឹងមែនទេ ចំពោះឯកសារទាំងឡាយដែលទទួលបាននៅ មជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** បាទ ខ្ញុំបាននិយាយយ៉ាងដូច្នេះមែន។

**សៈ** ប៉ុន្តែខ្ញុំហាក់ដូចជាឮថា នៅពេលដែលលោកមេធាវី ម៉ែខល កាណាវាស សួរ គឺលោកមិនបានទទួលឯកសារទាំងអស់ដែលចូលមក តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ។ មែនទេ?

**ឆៈ** លោកបានប្រើពាក្យថា ហាក់ដូចជាឮ? តើលោកឮពិតប្រាកដ ឬក៏លោកបានហាក់បីដូចជាបានឮ?

**សៈ** បាទ ខ្ញុំបានឮ ដោយខ្ញុំអត់ច្បាស់ ខ្ញុំសុំឲ្យលោកជួយបញ្ជាក់។ តើច្បាស់ជាអ៊ីចឹងទេ?

**ឆៈ** សូមលោកមេត្តានិយាយឃ្លាហ្នឹងឡើងវិញ ដើមហ្នឹងឡើងវិញ ឲ្យខ្ញុំបានមានការចងចាំផងបាទ។

**សៈ** បាទ បើខ្ញុំមិនច្រឡំទេ នៅពេលដែលលោកមេធាវី ម៉ែខល កាណាវាស សួរ លោកបានឆ្លើយថា លោកមិនបានទទួលឯកសារទាំងអស់ ដែលចូលមកនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ។ ត្រឹមត្រូវទេ?

**ឆៈ** មិនត្រឹមត្រូវទេ។

**សៈ** បាទ អ៊ីចឹងមានន័យថា លោកបានទទួលឯកសារទាំងអស់ដែលចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា។ អ៊ីចឹងមែនទេ?

**ឆៈ** ខ្ញុំបាននិយាយថា ខ្ញុំបានទៅ-- ខ្ញុំបានទទួលឯកសារមួយចំនួនដោយផ្ទាល់ដៃខ្ញុំ និងឯកសារមួយចំនួនទៀត គឺដោយបុគ្គលិក និងលោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១០:៣៧:៤០]

**សៈ** បាទ អ៊ីចឹងលោកទទួលស្គាល់ថា លោកមិនបានទទួលឯកសារទាំងអស់ដោយផ្ទាល់ដៃលោកពីអ្នកដែលផ្តល់ឲ្យឯកសារនោះ មកមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ។

**សៈ** បាទ សូមអរគុណ។ លោកបានឆ្លើយបញ្ជាក់ថា លោកបានសួរនូវសំណួរមួយចំនួនអំពីប្រភពនៃឯកសារទាំងនោះ។ តើលោកមានសួរអ៊ីចឹងមែនទេ?

**ឆៈ** ចំពោះឯកសារដែលខ្ញុំបានទទួលផ្ទាល់ដៃ គឺខ្ញុំបានសួរ។

**សៈ** តើលោកសួរក្នុងលក្ខណៈបែបម៉េចដែរ ការតាំងសំណួររបស់លោក សំណួរដែលលោកសួរនោះ មានសំណួរអ្វីខ្លះ លោកអាចជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះផងបានទេ?

**ឆៈ** ជាធម្មតានៅពេលដែលខ្ញុំទៅទទួលឯកសារ ខ្ញុំតែងតែមានការងឿងឆ្ងល់ ថាតើឯកសារ

ទាំងអស់នោះ បានមកពីណា? ហើយបានមកយ៉ាងម៉េច? ហើយសំណួរបែបនេះ ដែលខ្ញុំតែងតែសួរអ្នកដែលប្រគល់ឯកសារមកឲ្យយើង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងនៅពេលដែលលោកតាំងសួរ គឺបានន័យថាលោកមិនបានផ្ដោតទៅលើឯកសារនីមួយៗ ដែលលោកបានទទួលនោះទេ គឺលោកសួរក្នុងលក្ខណៈជារួម អ៊ីចឹងមែនទេ?

**ឆ៖** ព្រោះឯកសារ យើងទទួល វាជាបណ្ដុំឯកសារ នោះយើងមិនបានសួរឯកសារនីមួយៗនៅក្នុងបណ្ដុំឯកសារនោះទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា លោកក៏មិនបានដឹងពីប្រវត្តិនៃការទុកឯកសារនីមួយៗ មុនពេលដែលចូលមកដល់កន្លែងដែលលោកត្រូវទទួល ឧទាហរណ៍នៅបណ្ណសារដ្ឋានជាតិ ក៏លោកអត់បានដឹងថា ការថែរក្សាឯកសារមុននឹងចូលមកដល់បណ្ណសារដ្ឋានជាតិនេះយ៉ាងម៉េចដែរ ត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំបានសួរអំពីបញ្ហានេះ ហើយនៅបណ្ណសារជាតិនៅតែជាបណ្ណសារជាតិ រហូតមកដល់សព្វថ្ងៃ ដែលយើងគិតថា យើងបានសួរប៉ុណ្ណឹងជាការគ្រប់គ្រាន់។

[១០:៤០:០៦]

**ស៖** អ៊ីចឹង សំណួរលោកអាចបញ្ជាក់សាឡើងវិញថាសំណួរអ្វីខ្លះដែលលោកបានសួរជាទូទៅ?

**ឆ៖** សួរទៅកន្លែងបណ្ណសារដ្ឋានជាតិ?

**ស៖** បាទ សួរទៅបណ្ណសារដ្ឋានជាតិ ឬកន្លែងណាដែលលោកបានទទួលឯកសារនោះ?

**ឆ៖** បាទ អរគុណ ខ្ញុំនឹងឆ្លើយអំពីការទទួលបានឯកសារនៅបណ្ណសារជាតិ គឺខ្ញុំបានសួរថាតើឯកសារនោះបានមកពីណា? ហើយពីមុននៅកន្លែងណា?

**ស៖** អ៊ីចឹង លោកបានសួរថា ឯកសារនោះបានមកពីណា? ហើយនៅកន្លែងណា? តែពីរសំណួរហ្នឹងទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវមេធាវី ឥឡូវហ្នឹងដល់ពេលសមល្មមនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរ

ការសវនាការហើយមន្ត្រីសម្របសម្រួល មន្ត្រីតុលាការជួយសម្របសម្រួលដល់សាក្សី ដើម្បីមានកន្លែងសម្រាកសមរម្យ ហើយនិងអញ្ជើញគាត់មកកាន់បន្ទប់សវនាការនេះឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញលោកមេធាវីការពារក្តី អៀង សារី!

[១០:៤១:៣៥]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំបាទតាមរយៈខ្ញុំបាទ ហើយដោយសារលោក អៀង សារី មានបញ្ហាសុខភាព ជាពិសេសមានបញ្ហាឈឺចង្កេះទៅហើយ ដោយសារនេះគាត់មិនអាចអង្គុយនៅទីនេះតទៅទៀតបាន។ លោក អៀង សារី សូមលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅទីនេះ សម្រាប់ថ្ងៃនេះទាំងស្រុង ប៉ុន្តែសូមតាមដានសវនាការនៅបន្ទប់រង់ចាំខាងក្រោយ។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាសម្រេច។ សូមអរគុណ។

[១០:៤២:០៨]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើតាមរយៈមេធាវីរបស់ខ្លួនដោយលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយសូមដកថយខ្លួនទៅកាន់បន្ទប់ខាងក្រោម ដែលមានប្រព័ន្ធសោតទស្សន៍ ដើម្បីតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយបញ្ហាមូលហេតុសុខភាព អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមមេធាវីរបស់ខ្លួន ដោយលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍។ តែក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ សម្រាប់ថ្ងៃនេះ ដោយមានចុះហត្ថលេខា ឬផ្តិតម្រាមដៃពីជនជាប់ចោទផង។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ ហើយតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ហើយបង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោម ដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍

សម្រាប់តាមដានកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៤៣ នាទី ដល់ម៉ោង ១១:២២ នាទី)*

[១១:២២:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជាបន្តទៅនេះ សូមប្រគល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**ស៖** លោក ដាវ៉ា មុននឹងសម្រាកអំមិញនេះ ខ្ញុំបានសួរលោកអំពីយថាភាពនៃឯកសារដែលចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឥឡូវ ខ្ញុំបាទសូមសួរសំណួរចុងក្រោយមួយទាក់ទងនឹងចំណុចនេះ ថាតើចម្លើយដែលលោកទទួលបានអំពីបណ្ណសារដ្ឋានជាតិ ទាក់ទងទៅនឹងយថាភាពនៃឯកសារទាំងអស់នោះ លោកបានធ្វើកំណត់ត្រាទុកទេ?

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** បាទជម្រាបប្រសាសន៍លោកមេធាវី ខ្ញុំអត់បានធ្វើកំណត់ត្រាទុកទេ។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរលោកអំពីការសម្ភាសវិញម្តង សម្រាប់ក្នុងខ្លួនលោកផ្ទាល់ លោកបានធ្លាប់ទៅធ្វើសម្ភាស អាចថាជាជនរងគ្រោះ ឬក៏ជាពលរដ្ឋខ្មែរណាម្នាក់ ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១១:២៤:០៣]

**ឆ៖** បាទ ខ្ញុំបានធ្វើសម្ភាស បទសម្ភាសបែបនេះ ផ្ទាល់ខ្លួនខ្ញុំ។

**ស៖** លោកបានធ្វើសម្ភាសបានចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** ចំនួនច្បាស់លាស់ ខ្ញុំអត់អាចចងចាំបានទេ។

**ស៖** លោកអាចវាយតម្លៃពីចំនួនប្រហាក់ប្រហែលទេ?

**ឆ៖** បាទ បើសិនជាចំនួនប្រហាក់ប្រហែល អាចថារាប់រយនាក់ដែរ។

**ស៖** រាប់រយនាក់សរុបទាំងអស់ ឬមួយក៏សម្រាប់តែលោកម្នាក់ទេ។ ចង់និយាយថា តាំងពីលោកធ្វើការមក លោកសម្ភាសរាប់រយនាក់ ឬមួយក៏ ឌី.ស៊ី.ខេម សម្ភាសរាប់រយនាក់?

**ឆ៖** តើលោកចង់បានចម្លើយ ឌី.ស៊ី.ខេម ឬចង់ចម្លើយពីខ្ញុំ?

**ស៖** សម្រាប់លោកផ្ទាល់?

**ឆ៖** បាទ សម្រាប់ពីខ្ញុំគឺក្នុងចំនួនរាប់រយនាក់។

**ស៖** បាទសូមអរគុណ។ ចុះបើសរុបទាំងមជ្ឈមណ្ឌលផង មជ្ឈមណ្ឌលឯកសារកម្ពុជាផង តើការសម្ភាសហ្នឹង ចំនួនប្រហែលជាប៉ុន្មាននាក់ទៅ?

[១១:២៥:០៩]

**ឆ៖** អាចថាទៅដល់រាប់ពាន់នាក់។

**ស៖** ឯកសារដែលបានពីការសម្ភាសនោះ លោកធ្វើការផ្សព្វផ្សាយជាសាធារណៈទេ?

**ឆ៖** បាទ យើងបានផ្សព្វផ្សាយជាសាធារណៈដែរ។

**ស៖** តើលោកផ្សព្វផ្សាយទាំងអស់ ឬមួយក៏មានការជ្រើសរើសដែរ?

**ឆ៖** មានការផ្សព្វផ្សាយមួយចំនួននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក្នុងអត្ថបទសម្ភាសនោះក៏មានការយកទៅសរសេរជាអត្ថបទចុះផ្សាយផងដែរ។

[១១:២៥:៥២]

**ស៖** ខ្ញុំសួរថា តើលោកចុះផ្សាយទាំងអស់ ឬមួយក៏លោកជ្រើសរើសតែអត្ថបទដែលលោកគិតថាចាប់អារម្មណ៍ ដើម្បីធ្វើការផ្សព្វផ្សាយ?

**ឆ៖** តាមខ្ញុំអាចដឹងបាន គឺមិនមែនបទសម្ភាសទាំងអស់ត្រូវបានយកទៅសរសេរ និងផ្សព្វផ្សាយទាំងអស់នោះទេ។

**ស៖** បាទសូមអរគុណ ចុះលោកសម្រេចពីការជ្រើសរើសអត្ថបទណាមួយទៅចុះផ្សាយនេះដូចម្តេចដែរ?

**ឆ៖** ចំពោះការសរសេរផ្ទាល់ខ្លួនរបស់ខ្ញុំ គឺខ្ញុំចាប់អារម្មណ៍ទៅសាច់រឿង ដែលខ្ញុំបានដឹងអំពី

ការសម្ភាស ហើយសរសេរជាអត្ថបទ។

[១១:២៦:៣៨]

**ស៖** បាទសូមអរគុណ។ មុននេះពីថ្ងៃម្សិលម្ង៉ៃ និងម្សិលមិញ លោកបានបញ្ជាក់ថាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្វើការវិភាគទៅលើខ្លឹមសារនៃឯកសារនោះទេ។ តើលោកនៅប្រកាន់ជំហរបែបនេះទេ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមសួរសំណួរមួយចំនួនទាក់ទងទៅនឹងតួនាទីរបស់ទីប្រឹក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ តើទីប្រឹក្សាទាំងអស់នោះធ្វើកិច្ចការអ្វីដែរ?

**ឆ៖** បាទ ជាទីប្រឹក្សា គឺយើងមានសរសេរជា *ហ្កាយឡាញ*។ ជា *ហ្កាយឡាញ* ហ្នឹងគឺមានន័យថា អ្វីដែលទីប្រឹក្សាអាចធ្វើបាន ហើយនិងមិនធ្វើបាន។ ហើយជាពិសេសនោះ គឺទីប្រឹក្សាធ្វើការឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈការស្ម័គ្រចិត្ត តាមជំនាញ ហើយនិងតាមពេលវេលាដែលខ្លួនអាចផ្តល់ឲ្យបាន។

[១១:២៧:៥៨]

**ស៖** សូមលោកបញ្ជាក់ថា ការងារយ៉ាងម៉េចធ្វើបាន? ការងារយ៉ាងម៉េចធ្វើមិនបាន?

**ឆ៖** សូម ឧទាហរណ៍ដូចជា ការងារខ្លះដែលយើងមិនយល់ទាក់ទងទៅនឹងគម្រោងនៃការងារ គឺយើងអាចនឹងសាកសួរទៅអ្នកជំនាញមួយណា ទីប្រឹក្សាមួយណា ដែលគាត់មានជំនាញពាក់ព័ន្ធទៅនឹងការងារមួយនោះបាន។

**ស៖** ចុះតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលដំបូន្មាន ឬការប្រឹក្សាអ្វីខ្លះពីក្រុមអ្នកជំនាញ?

**ឆ៖** បាទ ដោយសារសំណួរមានលក្ខណៈទូលំទូលាយ ហើយខ្ញុំអាចមិនបានដឹងទាំងអស់។ ខ្ញុំសូមឲ្យលោកទុកសំណួរ ប្រហែលជានឹងទៅសួរលោកប្រធានរបស់ខ្ញុំ ដែលជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ជាជាងសួរខ្ញុំ។ បាទសូមអរគុណ។

[១១:២៩:០៩]

**ស៖** នៅចំពោះការផ្តល់ដំបូន្មានរបស់ទីប្រឹក្សា ថាតើការងាររបស់គេនោះយកមកប្រើប្រាស់ក្នុងគោលបំណងអ្វីដែរ? ខ្ញុំសូមបញ្ជាក់សាឡើងវិញ ខ្ញុំសូមបញ្ជាក់ថា តើគោលបំណងនៃការជ្រើសរើសក្រុមប្រឹក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ ក្នុងគោលបំណងអ្វីដែរ?

**ធ៖** បាទ សូមជម្រាបប្រសាសន៍លោកមេធាវី គឺដើម្បីឲ្យជួយដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** ជួយក្នុងលក្ខខណ្ឌយ៉ាងម៉េច លោកអាចជម្រាបបានទេ?

**ធ៖** ជួយក្នុងន័យថា បើសិនជាយើងមានការឆ្ងល់ ឬការមិនយល់ត្រង់ណា យើងអាចសាកសួរទៅអ្នកជំនាញ-- ទៅអ្នកទីប្រឹក្សាដែលទៅតាមជំនាញរបស់ខ្លួន ហើយការជូនយោបល់មកមិនមែនមិនមានកាតព្វកិច្ចត្រូវតែបង្ខំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានោះ ត្រូវធ្វើតាមនោះទេ។

**ស៖** ក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា មានដែលបង្គាប់ឲ្យទីប្រឹក្សាសរសេរអត្ថបទជាអត្ថបទសិក្សាសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរទេ?

**ធ៖** ខ្ញុំមិនអាចយល់បានទេ ត្រង់បញ្ហានេះ។

**ស៖** លោកមិនយល់សំណួរ ឬមួយក៏លោកមិនយល់ពីខ្លឹមសារ?

**ធ៖** គឺទាំងពីរយ៉ាង។

[១១:៣១:១៨]

**ស៖** ខ្ញុំសូមសួរឡើងវិញ ខ្ញុំសួរថា តើមជ្ឈមណ្ឌលឯកសារកម្ពុជា មានដែលបញ្ជា ឬមួយក៏បង្គាប់ឲ្យទីប្រឹក្សានៃមជ្ឈមណ្ឌលឯកសារកម្ពុជាសរសេរអត្ថបទបែបស្រាវជ្រាវ ឬសិក្សាសម្រាប់មជ្ឈ-មណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ធ៖** បើតាមខ្ញុំដឹង គឺថាមានអ្នក-- មានទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសរសេរអត្ថបទដោយផ្អែកទៅលើចំណេះដឹង ដោយផ្អែកទៅលើជំនាញរបស់គាត់រៀងៗខ្លួន។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតបង្ហាញឯកសារមួយហើយ ដែលមានឈ្មោះថា ខ្ញុំសូមអានជាភាសាអង់គ្លេស ដោយសារឯកសារនេះឈ្មោះដើមជាភាសាអង់គ្លេស។ ឯកសារនេះមានលេខ D155.3 នៅក្នុង-- ជាភាសាអង់គ្លេស ដែលមានលេខ ERN 00291504។

ជាបឋមខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះទៅសាក្សីសិន។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ មន្ត្រីតុលាការយកឯកសារយកឯកសារ ទទួលឯកសារពីមេធាវីយកទៅជូនសាក្សីពិនិត្យ!

បើកក្បាលមីក្រូហ្វូន!

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមបញ្ចោក់សាក្សី លោកដារ៉ា។ លោកស្គាល់ឈ្មោះ ចន.ឌី. ស៊ីរ៉ូស៊ែរី ទេ ខ្ញុំសូមប្រកប ឈ្មោះឲ្យលោក ចន-- "J-O-H-N ហើយ D" ហើយ ស៊ីរ៉ូ ស៊ែរី ហ្នឹងគឺ "C-I-O-R C-I-A-R-I"។

**ឆ៖** ខ្ញុំធ្លាប់-- ខ្ញុំស្គាល់គាត់ច្បាស់លាស់។

**ស៖** តើគាត់មានទំនាក់ទំនងយ៉ាងម៉េចដែរជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា?

[១១:៣៤:៥៧]

**ឆ៖** បាទ លោកជាទីប្រឹក្សាច្បាប់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកថា តើលោកបានធ្លាប់ឃើញឯកសារមួយ ដែលមាន ចំណងជើងថា *"ឌុកខ្សូមិនធីង ឌី ក្រាម អហ្វ ឌី ម៉ូក្រាទីក កម្ពុជា"* ហើយសរសេរដោយលោក *John Ciorciari* ជាមួយនិងលោក យុ ឆាំង។ ធ្លាប់ឃើញឯកសារនេះទេ?

**ឆ៖** បាទ ខ្ញុំបានឃើញ។

**លោក គង់ សំអុន៖**

បាទសូមអរគុណ។ លោកប្រធាន ដោយសាក្សីបានឃើញទៅហើយ តើត្រូវប្រគល់ឯកសារ ហ្នឹងទៅជូនសាក្សីទៀតទេ បានទទួលស្គាល់ថា វាជាឯកសារ ព្រោះនេះមាននៅក្នុងសំណុំរឿង។

**ប្រធានអង្គជំនុំ៖**

លោកត្រូវការដេញដោលអ្វី ដែរឬទេលើបញ្ហាទម្រង់នៃឯកសារហ្នឹង? ឬក៏ចប់ត្រឹមហ្នឹង?

[១១:៣៦:១០]

**លោក គង់ សំអុន៖**

ទាក់ទងនឹងឯកសារនេះ ខ្ញុំនឹងលើកបង្ហាញពីចំណុចខ្លីមួយ គ្រាន់តែអានជូនសាក្សីស្តាប់ និង ក្រុមប្រឹក្សាជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់ទេអ៊ីចឹង បើសិនជាលោកអានលើខ្លឹមសារនៃឯកសារ។ បាទសូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក ដារ៉ា ទាក់ទងទៅនឹងតួនាទីរបស់ទីប្រឹក្សា លោកអាចបញ្ជាក់បានទេថា គាត់អាចធ្វើការវិភាគទៅលើផ្លូវច្បាប់មួយចំនួន ពិសេសទាក់ទងទៅនឹងឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្រោមយុត្តាធិការនៃតុលាការនេះ។

[១១:៣៧:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំជំទាស់ចំពោះសំណួរនេះ។ សាក្សីមិនអាចឆ្លើយសំណួរទាក់ទងទៅនឹងបុគ្គលរូបនេះ។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំលើកសំណួរនេះដោយហេតុថា សាក្សីបានបង្ហាញថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនធ្វើការវិភាគឯកសារទេ ហើយព្យាយាមបង្ហាញថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអង្គការមួយដែលមានអព្យាក្រឹត្យមិនធ្វើការរិះគន់ ឬក៏វាយប្រហារទៅលើភាគីណាមួយ។ ដូច្នេះ អ្វីដែលខ្ញុំបាទនឹងលើកយកមកបង្ហាញនេះ វាជាប់ពាក់ព័ន្ធទៅនឹងគោលជំហររបស់អង្គការមជ្ឈមណ្ឌលឯកសារកម្ពុជានេះ។ បាទសូមអរគុណ។

[១១:៣៨:៤៨]

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិគ្មានប្រសិទ្ធភាព។ ដូច្នេះ សាក្សីត្រូវឆ្លើយនឹងសំណួរដែលសាកសួរដោយមេធាវី។

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

បាទ សូមលោកប្រធានមេត្តាឲ្យមេធាវី បញ្ជាក់សំណួរឡើងវិញម្តងទៀតបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មេធាវីបញ្ជាក់សំណួរសាជាថ្មីឡើងវិញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសួរថា តើទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង បានធ្វើការវិភាគទៅលើ

អត្ថបទដែលមជ្ឈមណ្ឌលឯកសារ-- ឯកសារដែលមជ្ឈមណ្ឌលឯកសារទទួលបាននោះ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការនៃតុលាការនេះដែរឬទេ?

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** ដោយសារអម្បាញ់មិញលោកមេធាវី បានបង្ហាញឯកសារទាក់ទងទៅនឹងឈ្មោះ លោក ចន ឆរឈីអារី (John Ciorciari) ជាមួយនឹងលោក យុ ឆាំង តើលោកសំដៅពាក្យថា ទីប្រឹក្សានេះ គឺសំដៅលើលោក ចន ឌីស្សេរ៉ូសារី ឬក៏ជារួម? បាទ សូមបញ្ជាក់ម្តងទៀតបាទ។

[១១:៤០:០០]

**ស៖** បាទ សូមអរគុណ គឺខ្ញុំចង់និយាយជារួម។

**ឆ៖** បាទ ជារួមគឺថានៅ ទីប្រឹក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការដោយឯករាជ្យរបស់គាត់។ គាត់មានសិទ្ធិផ្តល់ជាយោបល់ដល់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈការស្នើសុំឲ្យគាត់ធ្វើ ហើយមិនមានចងកាតព្វកិច្ចឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានោះ ត្រូវតែទទួលយកយោបល់ទាំងអស់នោះទេ។

**ស៖** សូមអរគុណ។ លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតបង្ហាញវេបសាយមួយរបស់ ឌី.ស៊ី.ខេម ដែលសហព្រះរាជអាជ្ញា បានបង្ហាញរួចហើយដែរ។ សូមអរគុណ។

[១១:៤១:០២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក ដារ៉ា សូមលោកពិនិត្យទៅលើស្ក្រីនកុំព្យូទ័ររបស់លោក ថាតើលោកទទួលស្គាល់ថា នេះជាវេបសាយរបស់ ឌី.ស៊ី.ខេម ទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** ព័ត៌មានដែលផ្សាយនៅក្នុងវេបសាយនេះ តើមានការត្រួតពិនិត្យ ឬក៏អនុម័តដោយប្រធាន ឬក៏ក្នុងកម្រិតណាដែរ?

**ឆ៖** ព័ត៌មាននៅខាងស្តាំដៃនោះ គឺជាសរសេរតូចៗនោះ គឺជាអ្វីដែលខ្ញុំសរសេរផ្ទាល់ដៃ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថា ព័ត៌មានដែលមាននៅក្នុងវេបសាយ ឌី.ស៊ី.ខេម

នេះគឺបានទទួលការត្រួតពិនិត្យត្រឹមត្រូវមែនហើយមែនទេ?

[១១:៤២:២៣]

**ឆ៖** ជាធម្មតា គឺថា គឺបានទទួលការពិនិត្យហើយ បានដាក់ចូលនៅក្នុងវេបសាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** បាទ សូមអរគុណ។ សូមលោកអានឲ្យខ្ញុំបន្តិចចំពោះអក្សរធំៗដែលមាននៅខាងក្រោមរូបនេះ។ លោកអាចចាប់ពីដំបូងរហូតដល់ចប់ក៏បានដែរ។ ចាប់ពីផ្ដើមរហូតដល់ចប់។

**ឆ៖** ជាដដែល ភាសាអង់គ្លេសមិនមែនជាភាសាដើមរបស់ខ្ញុំ ហើយខ្ញុំសូមមិនធ្វើការអានទេ ព្រោះខ្ញុំមិនមានភាពជឿជាក់ភាសាអង់គ្លេស ជាងភាសាខ្មែរនោះទេ។

**ស៖** អ៊ីចឹងមានន័យថាលោកមិនអាចអានបានទេ?

**ឆ៖** គឺខ្ញុំមិនអានតែម្ដងបាទ។

[១១:៤៣:២២]

**ប្រធានអង្គជំនុំ៖**

នេះសាក្សីជាជនជាតិខ្មែរ លោកមេធាវីមិនគប្បីព្យាយាមបង្វែរទិស ដើម្បីឲ្យសាក្សីជាខ្មែរនិយាយភាសាបរទេសនៅក្នុងកិច្ចដំណើរការសាធារណៈ ដែលត្រូវបានស្ដាប់តាមដានដោយសាធារណជនខ្មែរជាច្រើននោះឡើយ។

ជាតិខ្មែរ ត្រូវតែប្រើប្រាស់ភាសាខ្មែរជាភាសាផ្លូវការនៅទីនេះ ហើយជនជាតិខ្មែរដែលជាអ្នកគោលដៅនៃការឆ្លើយតបទៅនឹងសំណួរ ហើយគាត់បានបញ្ជាក់ហើយ ភាពមិនជឿជាក់ទៅលើការប្រើប្រាស់ភាសាបរទេស។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់តូចមួយ ដោយហេតុថា អត្ថបទជាភាសាអង់គ្លេសនេះ សាក្សីមានសមត្ថភាពនឹងបង្ហាញ ហើយម្យ៉ាងទៀតសាក្សីបានបញ្ជាក់អម្បាញ់មិញថាអត្ថបទមួយផ្នែកនៅផ្នែកខាងស្ដាំនោះ គាត់បានសរសេរដោយខ្លួនឯងទៀត។ ដូច្នេះបានន័យថា គាត់ប្រើប្រាស់ភាសាអង់គ្លេស ប៉ុន្តែមិនថ្វីទេ ខ្ញុំបាទនឹងស្នើសុំឲ្យអ្នកបកប្រែធ្វើការផ្ទៀងផ្ទាត់ទៅលើប្រយោគនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក គង់ សំអុន៖**

ដោយសារបច្ចេកទេស បាទឥឡូវបានចេញមកវិញហើយ។ នៅក្នុងអត្ថបទនេះ បានបង្ហាញនូវពាក្យមួយ ខ្ញុំបាទសូមអានជូនសាក្សី ហើយលោកអាចផ្ទៀងផ្ទាត់តាមរយៈការបកប្រែ។

(អានភាសាអង់គ្លេស)៖ "មជ្ឈមណ្ឌលឯកសារកម្ពុជា អនុវត្តការសិក្សាស្រាវជ្រាវគម្រោងសិក្សាស្រាវជ្រាវជាបន្ត ដើម្បីចងក្រង និងវិភាគឯកសារជាបឋម ដែលបានប្រមូលតាមរយៈមធ្យោបាយផ្សេងៗ"។ (ចប់ការអានភាសាអង់គ្លេស)

ខ្ញុំបាទ សូមអស់សំណួរ សូមប្រគល់ឱ្យសហមេធាវីអន្តរជាតិ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី។ សូមអញ្ជើញ មេធាវីអន្តរជាតិការពារក្តីឱ្យលោក ខៀវ សំផន!

**សួរដោយលោក ហ្សាក់ វ៉ែកហ្សេស៖**

លោកប្រធាន លោក លោកស្រីជាទីគោរព! ការពិភាក្សាគ្នានៅព្រឹកនេះ ជាមួយសំណួរដែលចោទសួរដោយសហភាតារបស់ខ្ញុំ គឺថាល្អមែនទែន ដោយចំពោះមុខសាក្សីនេះ ហើយខ្ញុំនិយាយដោយខ្លីទេ។ ខ្ញុំចង់ចោទសំណួរពីរបី។

[១១:៤៦:៤៧]

**ស៖** សាក្សី កាលពីពីរបីថ្ងៃនោះបាននិយាយថា ការចូលរួមវិភាគទានផ្នែកហិរញ្ញវត្ថុនៅក្នុងកន្លែងខ្លួននោះ ពុំមានកំណត់លក្ខខណ្ឌអីទេ ហើយម្សិលមិញនោះ គាត់បាននិយាយថា គាត់មិនដឹងពីប្រភពជំនួយនៃមជ្ឈមណ្ឌលរបស់គាត់ទេ។ តើអ៊ីចឹង គាត់ម៉េចក៏គាត់ដឹងថាពុំមានការដាក់លក្ខខណ្ឌបើគាត់អត់ដឹងផង? អ៊ីចឹងថាតើគាត់មានមូលដ្ឋានអីដើម្បីនិយាយបែបហ្នឹង?

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** តើលោកមេធាវីអាចសម្រួលសំណួរឱ្យបានច្បាស់លាស់ ហើយសួរមកកាន់ខ្ញុំឱ្យបានច្បាស់លាស់បានទេ។ សូមអរគុណ។

**ស៖** បាទឥឡូវខ្ញុំនិយាយម្តងទៀត។ សាក្សីពីរបីថ្ងៃមុន គាត់បាននិយាថាការជួយខាងផ្នែកហិរញ្ញវត្ថុនោះពុំមានដាក់លក្ខខណ្ឌអីទេ។ ហើយម្សិលមិញនោះ គាត់និយាយថា គាត់និយាយថាគាត់អត់

ដឹង អត់ស្គាល់អ្នកដែលផ្តល់ជំនួយទេ។ អ៊ីចឹង ខ្ញុំចង់ដឹងថា ហេតុអីបានគាត់ដឹងថាពុំមានលក្ខខណ្ឌ ហើយបើគាត់អត់នឹងស្គាត់ថាអ្នកណាដែលជាអ្នកផ្តល់ជំនួយផងនោះ។

[១១:៤៨:១៥]

**ឆ៖** ខ្ញុំមិនមែននិយាយថា ខ្ញុំមិនស្គាល់ម្ចាស់ជំនួយនោះទេ។ ខ្ញុំបាននិយាយថា ខ្ញុំមិនដឹងចំនួនទឹកប្រាក់ ដែលជាជំនួយផ្តល់មកមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** បើអ៊ីចឹងសំណួរចោទសួរកាលពីម្សិលមិញគឺថា ហើយសាក្សីឆ្លើយថា គាត់មិនដឹងចំនួនប្រាក់ជំនួយនោះទេ។ អ៊ីចឹងមិនសំខាន់ទេ រឿងចំនួនទឹកប្រាក់នោះ។ អ៊ីចឹងតើគាត់យល់ឃើញថា តើការផ្តល់ជំនួយនេះពុំមានលក្ខខណ្ឌអីទេ ឬក៏គាត់គិតថាមានក្រុមហ៊ុនហ្នឹងមួយថា មកនិយាយថា អ៊ីចឹងដោយសារមានឧក្រិដ្ឋកម្មនោះកើតឡើងហ្នឹង អ៊ីចឹងគេត្រូវបន្តធ្វើការជាមួយមជ្ឈមណ្ឌលរបស់គាត់នោះ?

**ឆ៖** បាទ គ្រប់ម្ចាស់ជំនួយដែលផ្តល់ជំនួយមកមជ្ឈមណ្ឌលឯកសារកម្ពុជា គឺម្ចាស់ជំនួយនោះចង់ដឹងតែម្យ៉ាងថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការទៅតាមអ្វីដែលបានស្នើសុំទៅម្ចាស់ជំនួយ តើធ្វើការហ្នឹងមានអំពើពុករលួយនៅក្នុងជំនួយហ្នឹងដែរឬទេ? មានតម្លាភាពដែរឬទេ? ហើយជំនួយឧបត្ថម្ភបែបនេះ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មលំដាប់អន្តរជាតិ ដែលមានការទទួលស្គាល់ដោយម្ចាស់ជំនួយនោះទៀតផង។

[១១:៥០:០៩]

**ស៖** អ៊ីចឹងគឺថាមិនមែន មិនឆ្លើយតបទៅនឹងសំណួរខ្ញុំទេ។ នៅពេលដែលអ្នកគណនេយ្យមកផ្ទៀងផ្ទាត់ គឺថាមកផ្ទៀងផ្ទាត់គណនេយ្យនោះជារឿងមួយ ក៏ប៉ុន្តែពុំមានលក្ខខណ្ឌដាក់ឲ្យមកនោះគឺថាៗជាការមិនអាចយល់បានទេ ពីព្រោះគាត់និយាយកាលពីម្សិលមិញនោះគឺថា គាត់មិនដឹងថាចំនួនដែលគេផ្តល់មកឲ្យនោះជាទឹកប្រាក់នោះប៉ុន្មាន។ ដូច្នេះសំណួរដែលខ្ញុំចោទឥឡូវនេះ តើហេតុអ្វីបានជាអនុប្រធាននៃអង្គការដ៏សំខាន់នេះមួយ ដែលធ្វើការងារនោះគឺសំខាន់ណាស់ផ្នែកនយោបាយ។ ហើយគាត់នោះ គាត់និយាយថាគាត់មិនដឹងឈ្មោះអ្នកផ្តល់ជំនួយ ហើយនិងចំនួនទឹកប្រាក់ដែលគេផ្តល់មកឲ្យនោះ។ អ៊ីចឹង តើយើងមិនអាចគិតបានថា នេះជាមានជាអាថ៌កំបាំងមួយដែលចោទជាបញ្ហា។

**ឆ៖** ខ្ញុំនៅតែរក្សាចម្លើយរបស់ខ្ញុំដដែលថា ខ្ញុំមិនបាននិយាយថា ខ្ញុំមិនបានដឹងឈ្មោះម្ចាស់ជំនួយនោះទេ បើលោកមេធាវីចង់សួរសំណួរនេះ លោកមេធាវីអាចសួរខ្ញុំបានអំពីថា តើម្ចាស់ជំនួយមានជំនួយនោះគឺអ្វីខ្លះ?

**ស៖** ហេតុអីម្សិលមិញហ្នឹង ម្សិលមិញហេតុអីក៏លោកមិនផ្តល់បញ្ជីឲ្យមកខាងមេធាវី បើម្សិលមិញគេសុំបញ្ជីទៅលោកនោះ?

**ឆ៖** សូមមេត្តា លោកមេធាវីពិនិត្យមើលស្ថានភាពខ្ញុំផ្ទាល់នៅពេលនេះ គឺខ្ញុំដើរចូលមកដោយដៃទទេ។

**ស៖** លោកប្រធានអង្គការដ៏សំខាន់នេះមិនចាំអំពីឯកសារទាក់ទងទៅនឹងឈ្មោះអ្នកដែលជួយអង្គការរបស់ខ្លួននោះ។ យើងអាចជឿគាត់បាន ក៏ប៉ុន្តែត្រូវថា តើត្រូវរកពេទ្យមកព្យាបាលជំងឺភ្លេចរបស់គាត់ ភ្លេចភ្លាំងរបស់គាត់។ នៅពេលដែលគាត់ អ៊ីចឹងគឺថានៅមានអាថ៌កំបាំងនៅក្នុងការផ្តល់ជំនួយរបស់គាត់នេះ។ បើសិនជាមានអង្គការអាមេរិកាំងម្នែ-សាមសិប មកជួយនោះ អ៊ីចឹងអត់មានបានរៀបរាប់ពីការផ្តល់ជំនួយនេះសោះ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានទីមួយ ខ្ញុំមិនដឹងថានេះជាសំណួរ ឬក៏អត់ទេ ហាក់បីដូចជាសំណើទៅវិញទេ។ ម្ចាស់ជំនួយសម្រាប់ ឌី.ស៊ី.ខេម គឺមានពន្យល់លម្អិតនៅលើគេហទំព័ររបស់ ឌី.ស៊ី.ខេម ហើយ។ មេធាវីការពារក្តីអាចបើកមើលបញ្ជីទាំងអស់ហ្នឹងបាននៅលើគេហទំព័រហ្នឹងបាន។

ខ្ញុំមិនយល់ថា តើវាមានការពាក់ព័ន្ធអ្វីនោះទេ ម្ចាស់ជំនួយនោះគឺថា អាចនឹងបើកមើលពីម្ចាស់ជំនួយនេះបាននៅលើគេហទំព័រនេះបានហើយ។

[១១:៥៣:៣២]

**លោក ហ្សាក់ វែកហ្សេស៖**

តាំងពីព្រឹកមក គាត់ជំទាស់រហូត។ អ្វីដែលខ្ញុំចង់និយាយនោះគឺថា។ បើបញ្ជីនេះមាន តើហេតុអីក៏គាត់មិនបានជម្រាបថាមាន។ ឥឡូវនេះ គាត់បញ្ជូនឲ្យយើងទៅមើលនៅក្នុងគេហទំព័រ។ នេះជាសំណួរ។ អ៊ីចឹងសំណួរខ្ញុំចោទទៅខាងសាក្សីទេ មិនចោទទៅខាងសហព្រះរាជអាជ្ញាទេ។

បាទ ខ្ញុំដាក់លក្ខខណ្ឌមួយទៀត សំណួរហ្នឹងបានចោទកាលពីម្សិលមិញ--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរៀបចំនូវការប្រើពាក្យពេចន៍របស់លោកឲ្យបានសមរម្យ លោកមិនអាចប្រើពាក្យ

ពេចន៍ធ្វើឲ្យប៉ះពាល់ដល់បុគ្គលភាពនៃសាក្សីដែលកំពុងនៅចំពោះមុខអង្គជំនុំជម្រះទេ។ លោកគ្មានមូលដ្ឋានអ្វីយកសាក្សីនេះយកទៅពិនិត្យពេទ្យអី បញ្ហាជំងឺភ្លេចភ្លាំងនោះទេ។ លោកសួរសំណួរក៏មិនប្រាកដថាជាសំណួរដែរ យើងមិនដឹងថាមកពីបកប្រែ ឬក៏យ៉ាងណានោះទេ។ ប៉ុន្តែរបៀបដែលលោកប្រើប្រាស់នេះ វាបច្ចេកទេសខ្ពស់ដែលស្តាប់ទៅមិនមែន អាចមិនមែនជាសំណួរទេ។

[១១:៥៤:៥៣]

បញ្ហាទីពីរ តួលេខនៃម្ចាស់ជំនួយដែលជួយមកច្រើនឆ្នាំ ជាងដប់ឆ្នាំមកហើយ ប្រហែលជាទំនងអាចសួរទាំងលោកខ្លួនឯងផង ក៏ដូចជាមិនអាចយល់បានទេ បើជំនួយ២០ឆ្នាំ សួរផ្ទាល់មាត់ ថាជួយមកហ្នឹង ថវិកាប៉ុន្មាន ហើយម្ចាស់ជំនួយអ្នកណាខ្លះ? ហើយឈ្មោះនោះ? ដោយផ្ទាល់មាត់ទំនងជាមិនអាចចម្លើយបានទេ។ ជាក់ស្តែង រដ្ឋមួយៗដែលទទួលជំនួយពីបរទេសទាំងពីកើតរដ្ឋរហូតមកដល់ពេលនេះ ទំនងទាល់ត្រូវតែបានពិនិត្យពិច័យដោយបញ្ជីស្ថានផ្សេងៗដែលមានតម្កល់ទុកនៅបណ្ណសារដ្ឋានត្រឹមត្រូវ ហើយរៀបចំជាមុន នោះទើបអាចឆ្លើយតបនឹងសំណួរបែបនេះបាន។ ដូច្នេះ សូមលោកមេធាវីរៀបចំនូវពាក្យពេចន៍ឲ្យសមរម្យក្នុងការសួរ ហើយសួរសូមតាំងសំណួរឲ្យបានច្បាស់ ចៀសវាងសួរមិនច្បាស់ មិនដឹងសំណួរ ឬក៏គ្រាន់តែជាការបំភ្លឺ ពាក្យខ្មែរអាចមានន័យគ្រប់គ្រាន់ក្នុងការសួរ។ មានតែពាក្យសំណួរនេះ ដែលមានន័យថាជាការសួរ ដើម្បីឲ្យឆ្លើយ។

**លោក ហ្សាក់ វែកហ្សេស៖**

បាទ ខ្ញុំគិតអំពីការកត់សម្គាល់របស់លោកប្រធាន។

**សួរដោយលោក ហ្សាក់ វែកហ្សេស៖**

**ស៖** ហើយអ៊ីចឹងខ្ញុំចោទសំណួរទៅសាក្សីថា គាត់មានចាំទេ ចាំអង្គការណាដែលថាផ្តល់ជំនួយមកមជ្ឈមណ្ឌលគាត់ទេ? ខ្ញុំមិនថាឲ្យចាំទាំងអស់នោះទេ។

**លោក វ៉ាន់ថាន់ ដារ៉ាពៅ៖**

**ឆ៖** បាទ មានការចងចាំចំពោះប្រទេសម្ចាស់ជំនួយ ម្ចាស់ជំនួយមកមជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសគឺផ្នែកហរិញ្ញវត្ថុនេះតែម្តង។

**ស៖** សំណួរនោះ ខ្ញុំសូមឲ្យផ្តល់ឈ្មោះអង្គការ ដែលជួយមកមជ្ឈមណ្ឌលរបស់គាត់នេះ មិនឲ្យថាផ្តល់មកគ្រប់ឈ្មោះអង្គការនោះទេ គឺថាពីរបីនោះក៏បានដែរ?

**ឆ៖** បាទ សូមជម្រាបប្រសាសន៍លោកមេធាវីបាន-- ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់ដោយ-សារថា សំណួរដំបូង លោកមេធាវីសួរខ្ញុំថា មានការចងចាំទេ។ អ៊ីចឹង ខ្ញុំឆ្លើយថា មានការចងចាំ។ បើសិនជាលោកមេធាវីឲ្យខ្ញុំរៀបរាប់បន្ថែម ថាតើម្ចាស់ជំនួយនោះឈ្មោះអីខ្លះ? នោះ ខ្ញុំនឹងរៀបរាប់ជូនបាន។ ដូចជា យើងទទួលបានថវិកា ពីអង្គការ យូ.អេស.អេ.អាយ.ឌី(USAID), ស៊ីដា (SIDA) របស់ប្រទេសស៊ុយអែត ជាឧទាហរណ៍។

[១១:៥៧:៥៧]

**ស៖** បើអ៊ីចឹង បើខ្ញុំម្សិលមិញនេះ មានសំណួរមួយដែលចោទម្សិលមិញនោះ គឺថាឈ្មោះសាកលវិទ្យាល័យដែលគាត់សហការជាមួយនោះ តើគាត់អាចផ្តល់បញ្ជីសាកលវិទ្យាល័យនុ៎ងបានទេ មិនថាមិនឲ្យក្បោះលម្អិតនោះទេ គឺយ៉ាងហោចណាស់ គឺថាឲ្យឈ្មោះសាកលវិទ្យាល័យចំនួនពីរបី ក៏បានដែរ?

**ឆ៖** បាទ សូមអរគុណលោកមេធាវី។ គឺឈ្មោះសាកលវិទ្យាល័យដែលយើងកិច្ចការជាមួយនេះ មានសាកលវិទ្យាល័យយ៉ែល, ញ៉ូវសៅវែល, សាកលវិទ្យាល័យសាន់តាក្លារ៉ា, សាកលវិទ្យាល័យរ៉ាត់ហ្គ័រ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរមួយទៀត គឺថាទាក់ទងនឹងកម្រងសំណួរ ដែលថាគាត់ប្រើជាមូលដ្ឋានដើម្បីទៅសម្ភាសគេ ដែលសរសេរជាអង់គ្លេស ហើយលោកប្រធានបានរំឭក គឺថាសាក្សីហ្នឹងនិយាយភាសាខ្មែរ។ អ៊ីចឹង ខ្ញុំចង់ដឹងថា អ្នកណាជាអ្នកសរសេរកម្រងសំណួរនេះ ដែលថាពេលក្រោយមក ដើរទៅសួរខ្មែរ នៅពេលក្រោយនោះ?

**ឆ៖** បើខ្ញុំចងចាំបាន គឺទាំងការឃើញទាំងឯកសារនេះ ដែលបង្ហាញនៅមុខខ្ញុំ កាលពីម្សិលមិញ គឺកម្រងសំណួរទាំងអស់នេះ ត្រូវបានរៀបចំដោយលោក ចន ឆរឃីអារី ហើយកម្រងសំណួរនេះ មានបកប្រែជាភាសាខ្មែរនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១១:៥៩:៤៥]

**ស៖** បាទខ្ញុំយល់មិនខុសទេ គឺថា បាទជារឿងធម្មតាទេ ព្រោះថាអ្នកនិពន្ធនោះ គឺជាជនជាតិបរទេស។ លោកសាក្សីបាននិយាយថា គាត់ទទួលនូវឯកសាររបស់អ្នកជំនាញទាំងអស់ ហើយគាត់បាននិយាយផងដែរថា ឯកសារមួយចំនួនបានផ្តល់ជូនដោយវៀតណាម។ តើគាត់ចាត់ទុកថា នៅក្នុងបរិបទកម្ពុជានេះ វៀតណាមជាអ្នកជំនាញដែរឬទេនៅក្នុងវិស័យនេះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ មិនដឹងថាតើអ្នកជំនាញនេះវាមានពាក់ព័ន្ធដែរឬក៏អត់នោះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទៅនឹងសំណួរដែលសួរដោយមេធាវីអំពីបញ្ហានេះទេ អំពីអ្នកជំនាញប្រទេសវៀតណាមជាអ្នកជំនាញដែរឬទេនេះ។

[១២:០០:៥០]

**លោក ហ្សាក់ វែកហ្សេស៖**

ជាការសំខាន់ណាស់នៅក្នុងការដឹងថា ដោយសារមានជម្លោះជាមួយប្រទេសវៀតណាម ដែលថា យើងដឹងថា តើឯកសារទាំងអស់នេះគួរឲ្យទុកចិត្តបានដែរឬក៏អត់? ឯកសារដែលថា វៀតណាមផ្តល់ជូននេះគួរឲ្យទុកចិត្តបានដែរឬក៏អត់?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំគិតថា សំណួរនេះគឺជាសំណួរមិនត្រូវទិសដៅទេ។

[១២:០១:៣១]

**ប្រធានអង្គជំនុំ៖**

អំមិញនេះយើងនិយាយរួចហើយ អត់ឲ្យសាក្សីឆ្លើយទេ។ លោកមានសំណួរទៀតទេ? បើអត់មានសំណួរទេ យើងនឹងសម្រាកប៉ុណ្ណឹងទេ។ តើមានសំណួរថ្មីទៀតទេ?

**សួរដោយលោក ហ្សាក់ វែកហ្សេស៖**

ខ្ញុំសោកស្តាយណាស់ ព្រោះខ្ញុំនៅសល់សំណួរមួយទៀតលោកប្រធាន។

**ស៖** សាក្សីបាននិយាយថា ថាឯកសារគួរឲ្យទុកចិត្តបាន ដោយហេតុថាសម្គាល់លើក្រដាសហើយនិងភាសាដែលប្រើនៅក្នុងឯកសារទាំងអស់នោះ។ អ៊ីចឹងសំណួរ ខ្ញុំសួរថាតើសាច់ក្រដាសហ្នឹងបានប្រែប្រួលទេ ថាពី៥០ឆ្នាំមកហើយនៅប្រទេសខ្មែរ នៅវៀតណាមនោះ។ បើសិនជាវា បើសិនជាមិនមានការប្រែប្រួលសាច់ក្រដាស់នោះទេ យើងមិនអាចធ្វើការវិនិច្ឆ័យថា ឯកសារនោះ ឯកសារនៅពីសម័យនោះ ឬក៏សម័យនេះនោះទេ។

[១២:០២:៣៣]

**លោក វ៉ាន់ថាន់ ដាវ៉ាពៅ៖**

**ឆ៖** ធម្មតាបើសិនជាឯកសារនោះជាឯកសារដើម គឺវាមានលក្ខណៈមានយើងអាចមើលឃើញនឹងភ្នែក ថាជាក្រដាសវាមានពណ៌យ៉ាងម៉េច អីយ៉ាងម៉េចនោះ ដែលវាខុសពីក្រដាសយើងឥឡូវនេះ។

**លោក ហ្សាក់ វែកហ្សេស៖**

លោកប្រធាន ខ្ញុំចប់ហើយ។ បើអ៊ីចឹង ខ្ញុំទទួលសំណួរថាអាចចាត់ទុកថាជា ចម្លើយនេះជាចម្លើយ។ អ៊ីចឹង កាលណាខ្ញុំជាមេធាវី ខ្ញុំត្រូវចោទសំណួរអ៊ីចឹង បើថាទោះបីថាអ្វី សំណួរដែលខ្ញុំសួរទៅគេមិនពេញចិត្ត គេមិនសប្បាយចិត្តក៏ដោយ ក៏ខ្ញុំត្រូវតែសួរ ទោះបីជាប៉ះពាល់ដល់បញ្ហានយោបាយក៏ដោយចុះ។

[១២:០៣:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណលោក ដារ៉ាពៅ ដែលបានខិតខំចំណាយពេលវេលាបញ្ញាស្មារតីចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងរយៈពីរថ្ងៃកន្លះកន្លងមកនេះ។ ហើយឥឡូវនេះ កិច្ចដំណើរការសួរដេញដោលក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះបានប្រព្រឹត្តទៅចប់ហើយតាមផែនការដែលបានគ្រោងទុក។ ហើយដូច្នេះ គឺលោកអាចត្រឡប់ទៅវិញទៅលំនៅដ្ឋាន ឬក៏គោលដៅដែលលោកចង់ទៅវិញបានហើយ។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់បី និងសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញ!

[១២:០៤:៤៤]

**លោក ម៉ៃខល ផេសមិន៖**

កូនក្តីរបស់ខ្ញុំចង់សួរថា តើអង្គជំនុំជម្រះបន្ត អាចឲ្យគាត់ហ្នឹងបន្តនីតិវិធីពីបន្ទប់រង់ចាំខាងក្រោមដែរឬទេ? គឺខ្ញុំបានដាក់ពាក្យសុំបោះបង់សិទ្ធិចូលរួមដោយផ្ទាល់នៅទីនេះរួចមកហើយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលស្នើសុំតាមរយៈមេធាវីរបស់ខ្លួនក្នុងការលះបង់សិទ្ធិមិនចូលដោយផ្ទាល់នៅក្នុងសាលសវនាការនេះ សម្រាប់ថ្ងៃនេះ ទៅតាមដាក់កិច្ចដំណើរការសវនាការពីចម្ងាយតាមបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការ ដោយឧបករណ៍សោតទស្សន៍។

[១២:០៥:៣២]

ហើយក្រុមមេធាវីត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការដោយមានចុះហត្ថលេខា ឬផ្តិតម្រាមដៃនៃជនជាប់ចោទឲ្យបានជាក់ច្បាស់ផង។ ហើយសូមបញ្ជាក់ថាសូមឲ្យការបង្ហាញនៅក្នុងលិខិតលះបង់សិទ្ធិហ្នឹងធ្វើឲ្យបានក្បោះក្បាយ ជាក់ច្បាស់នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងរឿងក្តីដ៏ធំនេះ មិនមែនសរសេរមួយបន្ទាត់មកអង្គជំនុំជម្រះនោះឡើយ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ តាមដាក់កិច្ចដំណើរការសវនាការពីចម្ងាយ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់ខាងក្រោម ហើយរសៀលនេះសូមឲ្យនាំតែជនជាប់ចោទ ខៀវ សំផន មកកាន់សាលសវនាការឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៤១នាទី)*

[១៣:៤១:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចនីតិវិធីសវនាការតាមកាលវិភាគដែលបានជម្រាបជូនភាគីរួចហើយ គឺយើងនៅរសៀលនេះ យើងដំណើរការស្តាប់សក្ខីកម្មសាក្សី TCW-542 ហើយមុននឹងឈានចូលដល់កិច្ចដំណើរការស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តី និងសាធារណជនបានជ្រាបថា កិច្ចដំណើរការសវនាការនៅរសៀលនេះ នឹងប្រព្រឹត្តទៅត្រឹមតែមួយពេលទេ គឺប្រព្រឹត្តទៅត្រឹមតែពេលឈប់សម្រាក គឺម៉ោងពីរនិងសែសិបនាទី ដើម្បីអង្គជំនុំជម្រះមានពេលវេលាមួយចំនួនសម្រាប់ពិភាក្សាផ្ទៃក្នុងលើបញ្ហាសំខាន់ៗមួយចំនួន ដែលកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃស្អែកវិញ គឺនៅតែប្រព្រឹត្តទៅជាធម្មតា។ ហេតុដូច្នេះ សូមភាគីនិងសាធារណជនជ្រាប។

មន្ត្រីរដ្ឋបាលតុលាការត្រួតពិនិត្យទៅ សំឡេងអីគេ? នរណាគេ?

ក្រឡាបញ្ជីឡើងរាយការណ៍អំពី តើសាក្សី TCW-542 មានវត្តមានហើយឬនៅ? ហើយតើគាត់

បានស្បថរួចហើយឬនៅ? ហើយគាត់មានទំនាក់ទំនងញាតិលោហិត ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្តីហ្នឹងយ៉ាងម៉េចដែរ តាមអ្វីដែលគាត់-- តាមសមត្ថភាពដែលគាត់បានដឹងនោះ?

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សាក្សី TCW-542 ដែលអង្គជំនុំជម្រះបានកោះហៅ មានវត្តមានរួចហើយ គឺរង់ចាំនៅបន្ទប់រង់ចាំ ដោយរង់ចាំការកោះហៅពីអង្គជំនុំជម្រះ ដើម្បីចូលសាលសវនាការ។

សាក្សីរូបនេះបានធ្វើសម្បថរួចហើយ សាក្សីក៏បានបញ្ជាក់ផងដែរថា តាមសមត្ថភាពដែលគាត់បានដឹង គឺគាត់មិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់នោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណក្រឡាបញ្ជី។ ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីចូលមកកាន់ទីកន្លែងផ្តល់សក្ខីកម្មក្នុងសាលសវនាការ!

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ទន្ទឹមនឹងពេលដែលសាក្សីកំពុងធ្វើដំណើរ ខ្ញុំសូមជម្រាបជូនលោកប្រធាន ពាក់ព័ន្ធនឹងសាក្សីនេះ មេធាវីនាំមុខសូមប្រគល់សិទ្ធិជូនលោកមេធាវី សំ សុគង់ ហើយនិងលោកស្រីមេធាវី ហ្វីលីពីន ស៊ុតហ្ស៍ សម្រាប់ធ្វើអន្តរាគមន៍ពាក់ព័ន្ធនឹងសាក្សីនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណដែលបានបញ្ជាក់អំពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ តាមប្រធានបទនៃ ឬក៏តាមការសាកសួរទៅសាក្សីជាក់លាក់។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៤៦:១០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីសាក្សី! តើលោកស្រីឈ្មោះអ្វីដែលលោកស្រី? លោកស្រីឆ្លើយម្តងទៀត

លោកស្រីបង្អន់បន្តិច រង់ចាំភ្លើងក្រហមនៅក្បាលមក្រូសូមចាប់ផ្តើមនិយាយ។

តើលោកស្រីឈ្មោះអ្វី?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំឈ្មោះ ប្រាក់ យុត។

**ស៖** លោកស្រីមានអាយុប៉ុន្មាន?

**ឆ៖** ប្រាំពីរ--

**ស៖** ម្តងទៀត លោកស្រីកុំអាលឆ្លើយរហ័សពេក ចាំរង់ចាំបង្អង់បន្តិចដើម្បីមានភ្លើងនៅក្បាលមេក្រូ ចាំស្តាប់ ទើបអាចឆ្លើយទៅ វាចូលទៅក្នុងប្រព័ន្ធនៃការស្តាប់ផង និងការបកប្រែភាសាផង។ លោកស្រីមានអាយុប៉ុន្មាន?

**ឆ៖** ខ្ញុំ៦៧។

[១៣:៤៧:០៦]

**ស៖** លោកស្រីមានទីកន្លែងកំណើតនៅឯណាដែរ?

**ឆ៖** ខ្ញុំស្រុកនៅត្រាំកក់ ខេត្តតាកែវ ឃុំជាងទង ភូមិក្បាលអូរ។

**ស៖** ហើយសព្វថ្ងៃនេះ លោកស្រីមានទីលំនៅនៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃ ខ្ញុំនៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ភូមិទួល ឃុំចក្រី។

**ស៖** លោកស្រីមានប្តីដែរឬទេ? ហើយប្តីលោកស្រីឈ្មោះអី?

**ឆ៖** ជំនាន់៧៧។

**ស៖** ម្តងទៀត លោកស្រីចាំស្តាប់សំណួរ ហើយនិងចាំភ្លើងក្រហមនៅក្បាលមេក្រូសឹមឆ្លើយ។ លោកស្រីសព្វថ្ងៃនេះនៅមានប្តីដែរឬទេ? ឬក៏ជាស្ត្រីមេម៉ាយ?

**ឆ៖** ខ្ញុំមេម៉ាយ។

**ស៖** លោកស្រីមានកូនប៉ុន្មាននាក់? ម្តងទៀត អត់ទេ មិនទាន់ចាំទេ ឲ្យបង្អង់បន្តិចណ៎ា។ លោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំកូនម្នាក់។

**ស៖** លោកស្រី ប្រាក់ យុត តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ ថាតាមសមត្ថភាពដែលលោកស្រីអាចដឹង គឺលោកស្រីមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធ ដូចជា ឪពុកម្តាយ កូន

បច្ចាជាតិ បងប្អូនប្រុសស្រី បងថ្លៃ ប្ដី ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដីនេះទេ។ តើជាការពិតមែនដែរឬទេ?

**ឆ៖** សូមការ-- ការពិត។

**ស៖** តើលោកស្រី បានធ្វើសម្បថហើយឬនៅមុននឹងចូលមកកាន់ទីកន្លែងដែលឆ្លើយចំពោះមុខអង្គជំនុំជម្រះនេះ?

**ឆ៖** ខ្ញុំបានស្បថរួចហើយ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកស្រីចាំស្ដាប់ យើងជាប្រធានអង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីកិច្ចដល់លោកស្រី ក្នុងនាមលោកស្រីជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងនាមលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការឲ្យធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារចម្លើយ ឬការអះអាងរបស់លោកស្រីនាំឲ្យលោកស្រីនឹងត្រូវទទួលរងនូវការចោទប្រកាន់។ ករណីយកិច្ចរបស់លោកស្រីត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលបានសួរចំពោះលោកស្រី ហើយត្រូវតែឆ្លើយការពិតដែលខ្លួនបានដឹងបានឮ បានឃើញ។ តើលោកស្រីយល់ទេ?

[១៣:៥០:៣៥]

**ឆ៖** ចាស ខ្ញុំយល់។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីសួរដេញដោលចំពោះសាក្សីរូបនេះមុនគេ មុនភាគីផ្សេងៗទៀតនៃរឿងក្ដី។

ហើយសូមអញ្ជើញ! ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា សហព្រះរាជអាជ្ញាមានពេលវេលាបួនម៉ោងនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ជម្រាបសួរលោកស្រី។ ខ្ញុំឈ្មោះ សេង ប៊ុនឃាង ហើយនិងសហការីរបស់ខ្ញុំនេះឈ្មោះ ឌេល លីសាក់ នឹងសួរសំណួរលោកស្រីមួយចំនួននូវអ្វីដែលអ្នកស្រីបានដឹង បានឮ បានឃើញ ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយសំណួរដំបូងរបស់ខ្ញុំនេះ គឺចង់ដឹងថា តើអ្នកស្រីធ្លាប់បានចូលបម្រើក្នុងជួរបដិវត្តន៍ដែរទេ?

[១៣:៥១:៣៨]

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ចាស ខ្ញុំធ្លាប់ចូល។

**ស៖** អ្នកស្រីចូលបម្រើក្នុងជួរបដិវត្តន៍នេះនៅពេលណាដែរ?

**ឆ៖** ខ្ញុំចូលឆ្នាំ៧០។

**ស៖** តើអ្នកស្រីបានដឹងទេថា ការចូលបដិវត្តន៍ហ្នឹងគឺដើម្បីអ្វីទៅ?

**ឆ៖** ខ្ញុំអត់ដឹងដែរ អង្កាល់ហ្នឹងនៅតូចៗ ចេះតែចូលតាមគេតាមឯង។

**ស៖** អ៊ីចឹងនៅពេលនោះ គេឲ្យអ្នកស្រីធ្វើអ្វីដែរ ហើយធ្វើនៅកន្លែងណា?

**ឆ៖** ខ្ញុំអង្កាល់នោះអត់ទាន់បានធ្វើអីផងចូលមក គ្រាន់នៅមន្ទីរកុមារ។

**ស៖** តើអ្នកណាជាអ្នកជ្រើសរើសលោកស្រីឲ្យចូលបក្សហ្នឹង ជ្រើសរើស និងអ្នកណែនាំលោកស្រីឲ្យចូលបក្សហ្នឹង?

**ឆ៖** អត់ដឹងអ្នកណាដែរអង្កាល់នុ៎ង ខ្ញុំអត់ដឹងថាអ្នកណានាំចូលនាំអីចេះ តែឃើញគេចូលៗជាមួយគេជាមួយឯងទៅ។

**ស៖** អ៊ីចឹងលោកស្រីអាចជម្រាបបានទេ ថាការចូលបក្សរបស់លោកស្រីហ្នឹងគឺធ្វើយ៉ាងម៉េចខ្លះទៅ?

**ឆ៖** អត់បានចូលបក្សហ្នឹងផង។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាជាតិ សូមបង្អាក់បន្តិចក្នុងការសួរឆ្លើយនេះ ដើម្បីឲ្យការបកប្រែហ្នឹងបានពេញលេញ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** តើអ្នកស្រីបានរៀនអំពីគោលនយោបាយរបស់បក្សដែរឬទេនៅពេលនុ៎ង?

**ឆ៖** អង្កាល់នុ៎ងនៅតូចដែរ អត់ទាន់បានរៀនសូត្រអីឲ្យច្បាស់លាស់ដែរ។ មិនទាន់អាយុច្រើន។

**ស៖** ចុះនៅពេលដែលអ្នកស្រីអាយុច្រើនហើយ ដែលថាអាចមានចំណេះដឹងគ្រប់គ្រាន់ក្នុងការរៀនហ្នឹង តើលោកស្រីបានរៀនទេ?

**ឆ៖** ខ្ញុំមិនសូវបានចូលសាលាដែរ ព្រោះអង្កាល់ហ្នឹងខ្ញុំអត់បានធ្វើអីនឹងគេផង។

**ស៖** អ៊ីចឹងការចូលបដិវត្តន៍របស់លោកស្រីហ្នឹង តើគេមានពេលដែលបន្ទាប់ពីលោកស្រីនៅកុមារហើយហ្នឹង? តើគេឲ្យលោកស្រីធ្វើអ្វីទៀតនៅពេលដែលលោកស្រីធំឡើង?

**ឆ៖** ដល់ពេលខ្ញុំធំ គេនៅមន្ទីរហ្នឹងគេឲ្យខ្ញុំមើលគោ ឲ្យជ្រូក អ៊ីចឹងទៅ។ ខ្ញុំមិនបានធ្វើអីផង។

**ស៖** ចុះនៅពេលណាដែលគេចាត់តាំងលោកស្រីឲ្យធ្វើជាប្រធានកងចល័ត តើមានពេលណាមួយទេដែលគេចាត់តាំងលោកស្រីឲ្យធ្វើជាប្រធានកងចល័តនោះ?

[១៣:៥៤:១៣]

**ឆ៖** ពេលដែលខ្ញុំបានធ្វើជាប្រធានកងចល័ត ខ្ញុំធំដែរហើយអង្កាល់ហ្នឹង គេឲ្យខ្ញុំនៅកងចល័តនៅស្រុកឈូក។

**ស៖** តើលោកស្រីបានដឹងទេថា ហេតុអីបានជាគេឲ្យលោកស្រីធ្វើជាប្រធានកងចល័តនុ៎ង?

**ឆ៖** ខ្ញុំអត់ដឹងដែរ។ គេឲ្យធ្វើចេះតែធ្វើទៅ អង្កាល់ហ្នឹងខ្ញុំនៅស្ទើរដែរ។

**ស៖** ហើយក្នុងតួនាទីដែលលោកស្រីជាប្រធានកងចល័តហ្នឹង តើគេឲ្យលោកស្រីធ្វើអ្វីខ្លះទៅ?

**ឆ៖** ឲ្យខ្ញុំមើលកុមារ មើលកងចល័តហ្នឹងលើកទំនប់លើកអី មានធ្វើអីផង។

**ស៖** អរគុណ។ ហើយនៅក្នុងកងចល័តរបស់លោកស្រីហ្នឹង មានកងចល័តដែលមានមនុស្សប៉ុន្មាននាក់ដែរ?

**ឆ៖** កងចល័តហ្នឹងអង្កាល់នុ៎ងមានប្រហែលជាពីរ-បីរយនាក់ហ្នឹង ចល័តធ្វើទំនប់ហ្នឹង។

**ស៖** តើលោកស្រីអាចបញ្ជាក់ជូនអង្គសវនាការបានទេថា កងចល័តចំនួនពីរ-បីរយនាក់ហ្នឹងយកមកពីខាងណាដែរ?

**ឆ៖** តាមឃុំ។ មិនមែនតាមឃុំទេ តាមភូមិ។

**ស៖** អរគុណ។

**ឆ៖** សូមទោស។

**ស៖** ការជ្រើសរើសឲ្យចូលក្នុងកងចល័តនេះ គេធ្វើឡើងដោយស្ម័គ្រចិត្ត ឬក៏មានបញ្ជាថ្នាក់លើពីណាមកឲ្យធ្វើ?

**ឆ៖** ការជ្រើសរើសនេះតាមភូមិគឺ តាមភូមិគេជ្រើសរើសឲ្យយើងៗចេះតែយកមក យើងមិនដឹងថាតាមភូមិគេនិយាយយ៉ាងម៉េចដែរ ខ្ញុំមិនបានដឹងដែរ។

**ស៖** សូមអរគុណ។ លោកស្រីនៅចាំទេថា ក្នុងស្រុកមួយដែលលោកស្រីនៅនោះកងចល័តទាំងអស់មានប៉ុន្មាននាក់ដែរ?

**ឆ៖** នៅ ខ្ញុំដូច នៅស្រុកឈូកហ្នឹងៗ កងចល័តប្រហែលជាប្រាំរយជាងហ្នឹង។ អត់សួរតាមសំណួរ។

**ស៖** តើកងចល័តដែលគេជ្រើសរើសឲ្យបន្តមកឲ្យចូលជាកងចល័តនេះ តើជាទូទៅមានអាយុប៉ុន្មាន?

**ឆ៖** ជាទូទៅ ១៧, ១៨, ១៦, ១៥ ធ្វើបាន និយាយរួមការងារធ្វើបាន។ តូចពេកក៏យើងធ្វើអត់បាន។

**ស៖** បាទ សូមអរគុណ។ ជាទូទៅកងចល័តនេះ តើមានការងារអ្វីខ្លះផ្សេងពីការលើកទំនប់ដែរទេ?

**ឆ៖** កងចល័តនេះ បើគិតទៅយើងយកមកធ្វើទំនប់ មិនមានអីធ្វើក្រៅពីទំនប់ទេ។

[១៣:៥៧:០៥]

**ស៖** អ៊ីចឹងទំនប់ដែលកងចល័តដែលលោកស្រីធ្វើហ្នឹងគឺមានទំនប់អ្វីខ្លះ លោកស្រីអាចនៅចាំបានទេ?

**ឆ៖** ខ្ញុំចាំមិនបានដែរទំនប់ យូរ។

**ស៖** តើលោកស្រីស្គាល់ទំនប់ទ្រាំងទេ?

**ឆ៖** ខ្ញុំស្គាល់តែទំនប់ស្ទឹងប្រាំងមួយ។

**ស៖** ស្ទឹងប្រាំង។

**ឆ៖** ស្ទឹងប្រាំង។

**ស៖** ស្ទឹងប្រាំង។ ទំនប់ស្ទឹងប្រាំងនោះ មានទំហំធំទេ?

**ឆ៖** កាលហ្នឹងមិនដឹងថា បណ្តោយប៉ុន្មាន ទទឹងប៉ុន្មាន ខ្ញុំភ្លេចដែរយូរពេក។

**ស៖** ហើយទំនប់ហ្នឹងចំណាយកម្លាំងចល័តរបស់លោកស្រីហ្នឹងច្រើនទេ ឬក៏មានកងចល័តពីឃុំផ្សេងចូលមកជួយដែរទេ?

**ឆ៖** អត់មានពីឃុំផង ឃុំក្រាំងស្បូវតែមួយហ្នឹង យកតែមួយហ្នឹង។

[១៣:៥៨:០៥]

**ស៖** តើកងចល័តទាំងនោះមានរបបអាហារ ឬក៏ការស្នាក់នៅយ៉ាងម៉េចដែរ?

**ឆ៖** កងចល័តកាលនោះមានរបបឃុំឧបត្ថម្ភដូចជាអង្ករ ដូចជាម្ហូបអីចឹងណា យើងជួយឲ្យគាត់ហូបនៅក្នុងកន្លែងធ្វើការហ្នឹង។ យើងដូចថាគាត់អត់អង្ករ អត់អីចឹង ឃុំគាត់ជាអ្នកជួយឧបត្ថម្ភ។

**ស៖** តើលោកស្រីយល់ថារបបទាំងអស់នោះគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** របបនោះ ខ្ញុំយល់ថា នៅកន្លែងហ្នឹង ខ្ញុំយល់ថាកន្លែងហ្នឹងវាអាចគ្រប់គ្រាន់ដែរ ព្រោះកន្លែងហ្នឹងមិនសូវអីប៉ុន្មានទេ គឺយើងបានផ្តល់ស្បៀងមកអីចឹងឲ្យកងចល័តហូបគ្រប់គ្រាន់ មិនមានបញ្ហាអីទេកន្លែងហ្នឹង តាមខ្ញុំពិនិត្យមើល វាអត់--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តី នួន ជា។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន ដើម្បីបង្ហាញថា សំណួរនិងចម្លើយទាំងអស់នេះវាពាក់ព័ន្ធទៅនឹងវគ្គទីមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ គឺយើងចង់ឲ្យព្រះរាជអាជ្ញាបញ្ជាក់ថា តើគាត់លើកឡើងនូវបញ្ហាអង្គហេតុពាក់ព័ន្ធទៅនឹងអំឡុងមុនឆ្នាំ១៩៧៥ ឬក៏ចន្លោះ ១៩៧៥ ដល់ ១៩៧៩?

[១៣:៥៩:៣៩]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ នូវការធ្វើការសង្កេតរបស់មេធាវីការពារក្តី នួន ជា ។ តំណាងសហព្រះរាជអាជ្ញាជាតិសូមបញ្ជាក់បញ្ហានេះ ពីព្រោះកិច្ចដំណើរការសវនាការ សហព្រះរាជអាជ្ញាបានជ្រាបហើយ ហើយយើងកំណត់នូវបញ្ហាដែលយើងលើកមកដេញដោលនេះ គឺពាក់ព័ន្ធជាមួយនឹងតែសំណុំរឿង០០២/១ គឺ

អង្គហេតុដំណាក់កាលដំបូងនៃកិច្ចដំណើរការសវនាការដែលអង្គជំនុំជម្រះជូននូវភាគីរួចហើយ។ ហើយ ឥឡូវនេះ អាចសួរដេញដោលបញ្ហានេះ ថាតើមានការពាក់ព័ន្ធអ្វីទៅនឹងអង្គហេតុដែលកំណត់របស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ធ្វើសវនាការនៅក្នុងដំណាក់កាលដំបូង ដែលយើងអាចហៅម្យ៉ាងទៀតថា សំណុំរឿង០០២/១ នេះ។

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមសួរទៅសាក្សីជាបន្ត។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** តើលោកស្រីអាចបញ្ជាក់បានទេ រយៈពេលដែលធ្វើការនោះគឺនៅក្នុងរយៈពេលណាដែរ? លោកស្រីនៅចាំពេលវេលាឆ្នាំអីដែរ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំដូចមិនបានចាំពេលវេលាដែរ មិនដឹងជាឆ្នាំប៉ុន្មាន។ ខ្ញុំនិយាយរួមភ្លេចការចងចាំដែរហ្នឹង មិនដឹងឆ្នាំចិតប៉ុន្មាន ខ្ញុំវាមិនបានកត់ត្រាទុក។

[១៤:០១:៣៨]

**ស៖** បាទ សូមអរគុណ។ លោកស្រីបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេតកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រង់សំណួរទី២២ គឺអ្នកស្រីបានឆ្លើយថា ខ្ញុំបានព្យាយាមដោះស្រាយបញ្ហានោះ។ បើមនុស្សល្អ គឺយើងបញ្ជូនទៅកន្លែងល្អ និងមនុស្សដែលអាក្រក់ គឺយើងបញ្ជូនទៅកន្លែងអាក្រក់។ តើកន្លែងនេះ អ្នកស្រីចង់មានន័យថាយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំចង់និយាយ កាលនោះ ខ្ញុំមានការអប់រំ ដូចថាកន្លែងអ្នកល្អ ឧទាហរណ៍ ខូច លួចអង្ករ លួចអីអីចឹង នៅកន្លែងកងចល័តអីចឹង ដល់ពេលយើងអប់រំ គេថាកន្លែងហ្នឹងអាក្រក់ យើងមិនយកទៅណាទេ គឺថាកន្លែងអប់រំមានអ្នកផ្សេងអប់រំទៀត មិនយកទៅណាទេ។ ដូចថា ខ្ញុំអប់រំ ដូចថា ឥឡូវ ពូអ៊្នា ឥឡូវជួយ ពូឯងជួយអប់រំខ្ញុំផង ពីព្រោះវាៗមិនកែ ខ្ញុំចង់និយាយ វាកែ អាហ្នឹងអីចឹង។ អត់មានយកទៅណាទេ។

**ស៖** ហើយអ្នកស្រីក៏បានឆ្លើយនៅដំណាក់កាលស៊ើបសួរនេះថា ចំពោះដែលមានឯកសារលេខ D234/16 លោកស្រីបានឆ្លើយថា ចំពោះការសម្លាប់ គឺយើងមិនសម្លាប់ពួកគេភ្លាមទេ គឺបញ្ជូនទៅថ្នាក់លើ ដើម្បីអប់រំបន្ត។ តើអប់រំបន្តនេះ គឺបញ្ជូនទៅខាងណាដែរ? ហើយធ្វើយ៉ាងម៉េចខ្លះទៅ?

[១៤:០៣:១៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញៗ លោកមេធាវី នួន ជា!

**លោក ម៉ែខល ផេសមិន៖**

ខ្ញុំសូមធ្វើការជំទាស់ដូចគ្នានេះដែរ ខ្ញុំមិនដឹងថា តើអង្គហេតុ ឬក៏ហេតុការណ៍ណាមួយដែលសហព្រះរាជអាជ្ញាកំពុងចង្អុលយោងនៅក្នុងអំឡុងរយៈកាលណាដែរ? ខ្ញុំមិនអាចមើលសំណួរ២២ ដែលគាត់ថា នៅក្នុងសំណួរ២២ នោះ ខ្ញុំមិនដឹងនៅកន្លែងណានោះទេ។ ដូច្នេះ គាត់គួរតែបញ្ជាក់ឲ្យច្បាស់ជាងនោះ ថាតើគាត់យោងត្រង់ចំណុចមួយណា? ប៉ុន្តែចំណុចដែលសំខាន់នោះ ខ្ញុំចង់ដឹងថា តើសហព្រះរាជអាជ្ញាកំពុងតែចង្អុលយោងនៅក្នុងរយៈកាលណាមួយ ក្រោយឆ្នាំ៧៥ ឬក៏យ៉ាងម៉េច? ប្រសិនបើចំណុចអត់ពាក់ព័ន្ធទេ គឺវាមិនពាក់ព័ន្ធទៅនឹងអ្វីដែលយើងពិភាក្សា ជាពិសេសការពិភាក្សារបស់យើងគឺទៅលើសវនាការដំណាក់កាលដំបូង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តី អៀង សារី!

[១៤:០៤:២៨]

**លោក ម៉ែខល កាណាវាស៖**

អរុណសួស្តី សូមគោរពលោកប្រធាន លោក លោកស្រី និងអស់លោក លោកស្រី។ ខ្ញុំសូមជំទាស់នូវរបៀបសួរសំណួរដែលលោកសហព្រះរាជអាជ្ញា គាត់ប្រើប្រាស់ចម្លើយដើម្បីទាញយកចម្លើយពីសាក្សី។ ដូច្នេះ សហព្រះរាជអាជ្ញាកំពុងតែដឹកមុខសាក្សីទៅតាមចម្លើយដែលមាននៅក្នុងកំណត់ហេតុនោះ ហើយព្យាយាមឲ្យសាក្សីបញ្ជាក់ថា តើគាត់មានន័យយ៉ាងម៉េច?

យើងខ្ញុំគិតថាចំណុចដែលវាសមស្របសម្រាប់សួរទៅសាក្សីនោះ គឺគួរតែសួរសាក្សីក្នុងលក្ខណៈចំហជាទូទៅ ហើយសួរឲ្យគាត់បញ្ជាក់ថា តើគាត់ចាំដែរឬទេ ឬក៏មិនចាំ? ហើយបន្ទាប់មក នៅពេលដែលឆ្លើយហើយ យើងចូលទៅដល់កំណត់ហេតុនៃចម្លើយនោះតែម្តង។ យើងខ្ញុំសូមជំទាស់នូវទម្រង់ដែលការប្រើប្រាស់ចម្លើយនៅក្នុងកំណត់ហេតុយកមកសួរបញ្ជាក់ដូច្នេះតែម្តង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ ការជំទាស់របស់មេធាវីទាំងពីរមានប្រសិទ្ធភាព។ ដូច្នេះ តំណាងសហព្រះរាជអាជ្ញា

ជាតិ សូមរៀបចំកែសម្រួលនូវសំណួររបស់ខ្លួនឲ្យបានត្រឹមត្រូវ ហើយបញ្ហាសំខាន់គឺពិនិត្យលើត្រឹមត្រូវតាមនីតិវិធីនៃការបង្ហាញភស្តុតាងចំពោះមុខអង្គជំនុំជម្រះ ហើយនិងអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការនៅដំណាក់កាលដំបូង ដែលអង្គជំនុំជម្រះបានបំបែករួចហើយ។ ហើយក្នុងករណីពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត ក៏សូមបង្ហាញឲ្យច្បាស់លាស់អំពីកាលបរិច្ឆេទនៃហេតុការណ៍ ព្រឹត្តិ-ការណ៍ដែលកើតឡើងពាក់ព័ន្ធទៅនឹងសំណួរផងដែរ។

[១៤:០៦:២០]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបន្តសំណួរតទៅទៀត។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** តើមាននៅពេលណាមួយដែលត្រូវគេតែងតាំងលោកស្រីឲ្យក្លាយជាសមាជិកនៃតំបន់៣៥ ដែរទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំបានធ្វើសមាជិកនៅកំពត នៅឆ្នាំ៧៣ ឬខ្ញុំមិនបានចាំដែរ។ ខ្ញុំបានធ្វើសមាជិកនៅខេត្តកំពត។ សមាជិកទីបួន។ តែខ្ញុំអត់ចាំថ្ងៃខែដែលបានចូលធ្វើនោះ មិនដឹងឆ្នាំចិតសិបប៉ុន្មាន ៧៣ ឬក៏ ៧៤។ ខ្ញុំអត់ចាំ។

**ស៖** បាទសូមអរគុណ។ តើតំបន់៣៥ នេះស្ថិតនៅក្នុងភូមិភាគអ្វីដែរ? ហើយភូមិភាគនេះដឹកនាំដោយនរណា?

**ឆ៖** តំបន់៣៥ ស្ថិតនៅក្នុងភូមិភាគនិរតី។

**ស៖** ភូមិភាគនិរតីនោះ ដឹកនាំដោយអ្នកណាដែរ?

**ឆ៖** តាម៉ុក។

**ស៖** តើលោកស្រីនៅចាំទេ ថាភូមភាគនិរតីនេះមានសមាជិកប៉ុន្មាននាក់?

**ឆ៖** អត់ដឹង ខ្ញុំអត់ដឹងដែរ។ មិនដឹងគាត់មានប៉ុន្មាននាក់។

**ស៖** តើលោកនៅចាំទេថា លេខាតំបន់៣៥ ដែលលោកស្រីជាសមាជិកនោះ ឈ្មោះអ្វីដែរ?

**ឆ៖** មិនដឹងឈ្មោះអីដែរកាលហ្នឹង គាត់-- ខ្ញុំអត់ចាំ។ ចាំ សមាជិកៗ តែប្រធានកាលហ្នឹងមិនដឹងគាត់យកមកពីណា ខ្ញុំបានស្គាល់ឈ្មោះទៀត។ ប៉ុន្តែសមាជិកដូចស្លាប់អស់ហើយ ដូច តាផន,

ដូច តាសៀន, ដូច តាទី, តាកត់ អីស្លាប់អស់ហើយ។ នៅសល់តែខ្ញុំមួយតើ។ ក្រៅពីនោះស្លាប់អស់ហើយ។

[១៤:០៨:២២]

**ស៖** បាទសូមអរគុណ។ ខ្ញុំចង់សំដៅទៅលើលេខាៗតំបន់៣៤ តើលោកស្រីនៅចាំទេ?

**ឆ៖** លេខាតំបន់ គឺ តាចាប។ កង ចាប។

**ស៖** កង ចាប។

**ឆ៖** ចំា, តែស្លាប់បាត់ហើយហ្នឹង។

**ស៖** ចុះលោកស្រីនៅចាំដែរទេ ថាតំបន់៣៥ នេះមានសមាជិកប៉ុន្មាននាក់ដែរ ហើយនរណាគេខ្លះទៅ?

**ឆ៖** តំបន់៣៥ ដូចខ្ញុំរាយការណ៍ដូចខាងលើអំមិញហ្នឹង។

**ស៖** មានផ្សេងទៀតទេ?

**ឆ៖** អត់ទេ។ ប៉ុនស្លាប់អស់ហើយ។

**ស៖** លោកស្រីមានដឹងទេថា សមាជិកតំបន់នីមួយៗហ្នឹង តើគាត់មានតួនាទីធ្វើអ្វីខ្លះទៅ?

**ឆ៖** តួនាទីគឺមានតើ។ ដូចខ្ញុំហ្នឹង ជួយអមនៅស្រុកកំពតអីចឹងណ៎ា។ ដូចថា លេខានៅស្រុកកំពត គាត់ដូចសួរ ដូចគាត់ថា គាត់នោះមិនសូវវប្បធម៌អីចឹង ខ្ញុំក៏ជួយអមដំណើរគាត់ ឬក៏ជួយតម្រង់គាត់ មិនទៅធ្វើជាប្រធានគាត់ទេ។ គាត់ធ្វើប្រធាន តែខ្ញុំហ្នឹងជួយគាត់ ហើយ តាផន ហ្នឹងនៅស្រុកទូកមាស។ ហើយ តាសៀន នៅស្រុកកំពង់ត្រាច។ ហើយ តាទី នៅស្រុកឈូក។ អីចឹងណ៎ា ចែកគ្នា តែឥឡូវគាត់ស្លាប់អស់ហើយ។ អត់មានសល់ទេ។

[១៤:០៩:៤៥]

**ស៖** សូមអរគុណ។ អីចឹងមានន័យថាសមាជិកតំបន់មួយៗហ្នឹង គឺទទួលបន្ទុកទៅស្រុកមួយៗ អីចឹងមែនទេ?

**ឆ៖** ចំា។

**ស៖** តើលោកស្រីនៅចាំទេថា កន្លែងធ្វើការតំបន់៣៥ នោះត្រង់ណាដែរ?

**ឆ៖** អាហ្នឹងអត់កំណត់។

**ស៖** តើលោកស្រីនៅចាំទេថា កន្លែងធ្វើការតំបន់៣៥ហ្នឹងនៅត្រង់ណាដែរ?

**ឆ៖** អាហ្នឹងអត់កំណត់ កន្លែងណាកាលនុ៎ង យើងឧទាហរណ៍ថា កង ចាប គាត់ត្រូវប្រជុំនៅស្រុកឈូក ឬក៏ស្រុកទូកមាស ឬស្រុកកំពង់ត្រាចអ៊ីចឹងទៅណ៎ា។ កន្លែងណាដែលស្រួលប្រជុំ គាត់ប្រជុំហ្នឹងគាត់អត់កំណត់ទេ តា កង ចាប ហ្នឹងណ៎ា។

**ស៖** អ៊ីចឹងបានន័យថា មិនមានការិយាល័យណាមួយជាកំណត់ច្បាស់លាស់ទេ?

**ឆ៖** ដូចថាគាត់ចង់ធ្វើកន្លែងណា គាត់ប្រាប់យើងថាធ្វើកន្លែងហ្នឹងទៅ។

[១៤:១០:៣៣]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាជាតិ តំណាងសហព្រះរាជអាជ្ញាជាតិ សូមរបៀបនិយាយសូមដកឃ្លាបន្តិច ពីព្រោះបញ្ហាបកប្រែ បកប្រែមិនទាន់។ អ៊ីចឹងនាំឲ្យកិច្ចពិភាក្សាហ្នឹងអាចមានបញ្ហា ដោយសារភាគីពាក់ព័ន្ធផ្សេងទៀតហ្នឹងត្រូវប្រើប្រាស់ភាសា ទាំងភាសាអង់គ្លេស និងបារាំងផង។ ខ្ញុំរំឭកហ្នឹងបញ្ហានេះពីរដងហើយ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** តើការងារលោកស្រីដែលទទួលបន្ទុកស្រុកកំពតហ្នឹង មានអ្វីផ្សេងក្រៅពីការបញ្ជាក់អម្បាញ់មិញនេះទេ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** អត់មានផង។

**ស៖** តើមានការអប់រំខាងនយោបាយដល់ប្រជាជនអ្វីទេ?

**ឆ៖** ខ្ញុំ ជួនកាលប្រធាននៅលេខាស្រុកហ្នឹង គាត់ដាក់ឲ្យខ្ញុំជួយធ្វើ ខ្ញុំចេះតែជួយ ប៉ុន្តែឲ្យខ្ញុំទៅនៅលើចាត់ចែងលើស្រុកគាត់ ខ្ញុំម៉េចបាន ព្រោះខ្ញុំជំនួយការគាត់ហ្នឹង។

**ស៖** បាទសូមអរគុណ។ នៅ តើលោកដឹងទេ ថានៅក្នុងស្រុកនីមួយៗរបស់តំបន់៣៥ហ្នឹង តើមានកន្លែងអប់រំកែប្រែអីទេ?

**ឆ៖** ខ្ញុំមិនសូវដឹងទេ ព្រោះគាត់ធ្វើតាមស្រុកនីមួយៗ ម្ចាស់ការរៀងខ្លួន។ ខ្ញុំនៅស្រុកណានៅស្រុកហ្នឹ ខ្ញុំមិនដែលដើរមើលតាមស្រុកគេផង គេធ្វើម៉េច ខ្ញុំមិនបានដឹងដែរ។ ចែកគ្នាដាច់ៗ។

[១៤:១២:០៧]

**ស៖** ចុះនៅស្រុកលោកស្រី តើមានទេ? មានកន្លែងអប់រំកែប្រែហ្នឹងដែរទេ?

**ឆ៖** ហ្នឹងមានកន្លែងអប់រំកែប្រែ តែតាប្រធានគាត់ទទួលខុសត្រូវ។ ខ្ញុំមិនបានចូលរួមជាមួយគាត់ទេ។

**ស៖** លោកស្រីនៅចាំទេថា កន្លែងអប់រំកែប្រែហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** អត់ដឹងនៅកន្លែងណា របស់ស្រុក។

**ស៖** លោកស្រីដឹងទេថា កន្លែងអប់រំកែប្រែនោះគឺសម្រាប់ធ្វើអ្វីទៅ?

**ឆ៖** តាមខ្ញុំដឹង ការអប់រំមនុស្សឱ្យកែប្រែ ដូចថា មនុស្សខូចមនុស្សអីអ៊ីចឹង ឱ្យកែប្រែកុំឱ្យវាអាក្រក់អីថែមទៀតទៅណ៎ា។ មានតែប៉ុណ្ណឹងទេ មានអីអស់ មានអីធំដុំទេ។ ដូចមានដើរលួចមាន់លួចទាតាមកន្លែង កង តាមភូមិអ៊ីចឹងណ៎ា។ យើងអប់រំទៅ។

**ស៖** បាទ សូមអរគុណ។ ចុះនៅតំបន់ លោកស្រីដឹងទេ-- នៅក្នុងតំបន់នុំងមានមន្ទីរអប់រំកែប្រែដែរទេ? មុននឹងខ្ញុំសួរអំពីស្រុក ឥឡូវនៅតំបន់ តើមានទេ?

**ឆ៖** នៅតំបន់កាលហ្នឹងតា កង ចាប គាត់ទទួលខុសត្រូវ មិនដឹងជា-- ខ្ញុំមិនបាននៅជួបជុំគាត់ទេ ត្បិតតែខ្ញុំនៅតំបន់ហ្នឹង សមាជិកទីប្រាំមួយមែន តែខ្ញុំក៏មិនបាននៅជួបជុំគាត់ដែរ មិនដឹងថានៅក្នុងតំបន់ហ្នឹងគាត់រៀបរយមន្ទីរកែប្រែអប់រំនៅត្រង់ណា ក៏ខ្ញុំមិនបានសាកសួរគាត់ដែរ ព្រោះខ្ញុំនៅជាមួយតាណយ នេះ។ ខ្ញុំសូម ខ្ញុំមិនបានជួបជុំគ្នា មិនដឹងគាត់ដាក់កន្លែងណា អីកន្លែងណា ខ្ញុំមិនសូវដឹងដែរអង្គាល់ហ្នឹង។

[១៤:១៤:១១]

**ស៖** បាទ សូមអរគុណ។ តើលោកស្រីមានការយល់ដឹងទាក់ទងទៅនឹងខាងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាខ្លះដែលទេនៅពេលនុំង?

**ឆ៖** ខ្ញុំកាលនោះនៅពេលនោះ ខ្ញុំមិនសូវយល់ដឹងអីដែរ។ ប៉ុនតាមការអប់រំរបស់តំបន់អី ផ្សព្វផ្សាយអីឱ្យខ្ញុំរៀនសូត្រអី ខ្ញុំចេះតែរៀនតាមគាត់ហើយ។ ប៉ុន្តែឱ្យខ្ញុំហ្នឹងយល់អំពីអី ខ្ញុំមិនសូវយល់ដែរ។

ស៖ អ៊ីចឹង បាទ សូមអរគុណ។ អ៊ីចឹងនៅពេលនោះ តើខាងថ្នាក់លើហ្នឹង គេបានប្រគល់ឯកសារ ឬក៏សៀវភៅអ្វីរបស់បក្សដល់លោកស្រីខ្លះដែរទេ?

[១៤:១៥:០០]

**ផ៖** អត់ ខ្ញុំអត់ដែលបានទទួលឯកសារអីផង គ្រាន់តែយកមកដូចថា ឲ្យខ្ញុំហ្នឹង ដូចថាខ្ញុំហ្នឹងនៅក្នុងឃុំ ឬស្រុកហ្នឹង គ្រាន់តែ តាណយ គាត់ហៅមក ប្រាប់ខ្ញុំអ៊ីចេះៗ ខ្ញុំធ្វើតាមជាក់ស្ដែងហ្នឹង។ ខ្ញុំមិនសូវបានរៀនសូត្រ ព្រោះខ្ញុំមិនសូវចេះអក្សរដែរ។

**ស៖** តើនៅពេលនោះលោកស្រី ដឹងថាមានលក្ខន្តិកៈរបស់បក្សកុម្មុយនីស្ដកម្ពុជាដែរទេ?

**ផ៖** អត់ដឹងដែរ។

**ស៖** ទាក់ទងទៅនឹងការងាររបស់លោកស្រី តើលោកស្រីមានបានរាយការណ៍ទៅថ្នាក់លើអីទៀតទេ?

**ផ៖** រាយការណ៍អំពីអី?

**ស៖** រាយការណ៍ពីអ្វីដែលជាភារកិច្ចរបស់លោកស្រីនៅក្នុងតំបន់លោកស្រីធ្វើការនុ៎ង?

**ផ៖** មានរាយការណ៍ដែរ ដូចថា យើងធ្វើផែនការអីមួយក្នុងស្រុកហ្នឹង ឧទាហរណ៍ថា យើងដាក់ផែនការលើកទំនប់ ឬក៏ធ្វើស្រែអីអ៊ីចឹងណ៎ា។ អ៊ីចឹងយើងថា ធ្វើបាន យើងនិយាយជាមួយគាត់ហ្នឹងពិភាក្សាជាមួយប្រធានហ្នឹងទៅ ហើយគាត់ប្រធាន ក៏គាត់រាយការណ៍ទៅលើទៅ យើងមិនបានរាយផ្ទាល់ទេ។ ខ្ញុំមិនបានរាយផ្ទាល់ទេ។ ប្រធាន ដូចថា តាណយ គាត់អ្នករាយទៅ។ យើងគ្រាន់តែពិភាក្សាជាមួយគាត់។

[១៤:១៦:២១]

**ស៖** អ៊ីចឹងលោកស្រីដឹងទេថា តាណយ ដែលរាយការណ៍ទៅថ្នាក់លើហ្នឹង គាត់ធ្វើជាលាយលក្ខណ៍អក្សរ ឬក៏ធ្វើយ៉ាងម៉េច?

**ផ៖** អត់ដឹងដែរ ភារកិច្ចគាត់។

**ស៖** អម្បាញ់មិញលោកស្រីឆ្លើយថា រាយការណ៍ទៅថ្នាក់លើ។ តើថ្នាក់លើនោះជានរណាដែរលោកស្រីដឹងទេ ថ្នាក់លើនោះ?

**ផ៖** កង ចាប ប្រធានតំបន់។

**ស៖** ហើយក្នុងឋានៈលោកស្រីដែលជាសមាជិកតំបន់នោះ តើលោកស្រីមានដឹងទេថា សមាជិកតំបន់ទាំងអស់នុ៎ងបានទទួលនូវសេចក្ដីរាយការណ៍ហ្នឹងពីឃុំហ្នឹង ពីស្រុកហ្នឹងដែរទេ?

[១៤:១៧:០៥]

**ផ៖** តាមស្រុកមួយៗគេរាយការណ៍តើ!

**ស៖** តើលោកស្រីចង់បញ្ជាក់ថា សមាជិកមួយៗរបស់តំបន់ តើបានទទួលការរាយការណ៍ហ្នឹងដែរទេ បានដឹងទេអំពីការរាយការណ៍ពីថ្នាក់ក្រោមមកហ្នឹង?

**ឆ៖** ពីថ្នាក់ក្រោមរាយឲ្យថ្នាក់លើ? បានទទួលខ្លះ អត់ខ្លះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអធ្យាស្រ័យ ប្រហែលជាខ្ញុំយល់ច្រឡំ។ តាមដែលខ្ញុំដឹងគឺសាក្សីរូបនេះមិនមែនជាលេខាតំបន់ទេ។ គាត់គ្រាន់តែនិយាយថា គាត់ជាសមាជិកតំបន់តែប៉ុណ្ណោះ។

[១៤:១៨:០០]

**ប្រធានអង្គជំនុំ៖**

ជាការត្រឹមត្រូវហើយ សាក្សីមិនមានពាក្យណាមួយគាត់និយាយថា ខ្លួនគាត់ជាលេខាតំបន់ទេរហូតដល់ពេលនេះ។ គាត់ជាសមាជិកទីប្រាំមួយ នៃតំបន់ ៣៥។ ប្រហែលជាអាចភ័ន្តច្រឡំដោយសារការបកប្រែភាសា។

លោកអាចបន្តសំណួរ ឬក៏សួរបញ្ជាក់បន្ថែមទៀតសំណួរអម្បាញ់មិញនេះ ដើម្បីឲ្យគាត់សាក្សីបានឆ្លើយ យល់សំណួរ ហើយនិងអាចឆ្លើយតបនឹងសំណួរ ដែលលោកបានសួរ។

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ដើម្បីបញ្ជាក់ សូមលោកស្រីបញ្ជាក់ថា តើលោកស្រីជាសមាជិតំបន់ ៣៥ ឬក៏យ៉ាងណា?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** សមាជិកតំបន់ ៣៥។

**ស៖** បាទសូមអរគុណ។ នៅក្នុងតំបន់៣៥ ដែលលោកស្រីជាសមាជិកហ្នឹង តើធ្លាប់មានលេខាស្រុកដែលទៅប្រជុំ ដើម្បីរាយការណ៍ពីការងាររបស់ខ្លួនទៅឲ្យសមាជិកនៃតំបន់៣៥ ក៏ដូចជាលេខាតំបន់៣៥ហ្នឹង បានដឹងពីការងាររបស់ខ្លួនដែរទេ? ធ្លាប់មានទេ?

[១៤:១៩:១៩]

**ធ៖** ពេលសមាជិកតំបន់ទាំងអស់នៅតាមស្រុកហ្នឹង គាត់រាយការណ៍គ្រប់ស្រុកតើ! ឱ្យលេខាតំបន់តើ។ ខ្ញុំ តាណយ ហ្នឹងក៏គាត់រាយការណ៍គ្រប់-- និយាយរួមគ្រប់ស្រុកទាំងអស់រាយការណ៍ឱ្យតំបន់ទាំងអស់។ តែគាត់រាយពីអីៗខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំនៅស្រុកផ្សេង គាត់នៅស្រុកផ្សេង មិនដឹងគាត់រាយពីអីខ្លះទេណា! ខ្ញុំអត់ដឹងដែរអាហ្នឹង ចែកគ្នា។

**ស៖** អ៊ីចេះ ជាធម្មតា តំបន់គឺនៅពីលើស្រុក។ អ៊ីចឹងតើតំបន់ពេលដែលប្រជុំតំបន់ម្តងៗ គឺមានប្រធានលេខាតំបន់ ហើយនិងសមាជិកតំបន់ចូលរួមប្រជុំ។ តើនៅពេលដែលប្រជុំនោះ តើមានដូចជាលេខាស្រុកមួយហ្នឹងធ្លាប់ដែលមករាយការណ៍ដល់លេខាតំបន់ និងសមាជិកតំបន់ក្នុងអង្គប្រជុំដែរឬទេ?

**ធ៖** មានដូចថា លេខាស្រុកទាំងអស់ ឡើងទៅរាយការណ៍ឱ្យតំបន់ មានតើ។

**ស៖** ហើយជាទូទៅ ការឡើងរាយការណ៍ឱ្យតំបន់ហ្នឹងធ្វើឡើងញឹកញាប់ដែរទេ?

**ធ៖** អាហ្នឹងតាមសភាពជាក់ស្តែង ដូចជាថ្ងៃណាយើងត្រូវចាំបាច់ យើងប្រជុំទៅ ពេលណាមិនចាំបាច់ យើងពីរខែអី បីខែយើងប្រជុំម្តងទៅ។ មិនមែនប្រជុំទៀងទាត់ទេណា។

**ស៖** បាទ សូមអរគុណ។ តើលោកស្រីនៅចាំទេថា ការប្រជុំនោះគេលើកពីអ្វីខ្លះទៅ?

**ធ៖** មិនដឹងលើកពីអី បើភ្លេចអស់ហើយ។ ខ្ញុំមិនបានចាំទាំងអស់ទេ សូមអត់ទោសទៅ ខ្ញុំភ្លេចខ្លះហើយ។

[១៤:២១:១៧]

**ស៖** តើនៅពេលនោះ គេមានបានលើកពីករណី ដូចជាថាការប្រព្រឹត្តខុសសីលធម៌ ឬក៏អីរបស់ប្រជាជន ឬកម្មាភិបាលអីដែរទេ ពេលនុ៎ង?

**ធ៖** លើកខ្លះដែរ ពេលខ្លះលើក ពេលខ្លះអត់។ ប៉ុន្តែធម្មតាតែប្រជុំហើយ លើកពីការខុសត្រូវហើយ។ ដូចថាប្រជាជនមានកំហុសអី យើងជួយកែប្រែគ្នាអ៊ីចឹងទៅណា។ ហើយតំបន់ហ្នឹងជួយយកវិធានការអប់រំអីអ៊ីចឹង ឬស្រុកហ្នឹងអប់រំគ្នាទៅ កុំឱ្យខូចកាចអីអ៊ីចឹងទៅណា មានតើ! មានដែលបញ្ហាហ្នឹង ជួយមតិគ្នា។

**ស៖** បាទ សូមអរគុណ។ ចុះដែលមានទេ អ្នកដែល អ្នកដែលអប់រំហើយ នៅតែមិនអាចកែប្រែបាន តើគេធ្វើយ៉ាងម៉េចទៀត?

**ធ៖** ហ្នឹងស្រេចតាមស្រុក បើអប់រំមិនបាន អាហ្នឹងស្រុកយកទៅកែប្រែខ្លួនឯងទៅ អត់មានយកទៅណាផង ស្រុកមួយៗអប់រំខ្លួនឯង។

[១៤:២២:២៥]

**ស៖** ស្រុក នៅពេលដែលក្នុងករណីដែលស្រុកហ្នឹង គាត់អប់រំមិនបាន តើស្រុកបញ្ជូនទៅណាទៀត ឬក៏យ៉ាងម៉េចដែរ?

**ផ៖** អត់ដឹងដែរ។ ព្រោះតាមស្រុកនីមួយៗ មិនដឹងគេអប់រំហើយ យកទៅណា។ យកទៅឯតំបន់ទៀត ឬក៏នៅតាមស្រុក ខ្ញុំក៏វាមិនបានដឹងដែរ។ ខ្ញុំអត់ដឹងអាហ្នឹង។

**ស៖** ខ្ញុំចង់បញ្ជាក់លោកស្រីម្តងទៀតថា នៅការប្រជុំអម្បាញ់មិញមានទាក់ទងទៅនឹងការលើកឡើងពីប្រព្រឹត្តខុសសីលធម៌ដែរឬទេ?

**ផ៖** ក្នុងការប្រជុំវាមានហើយ លើកក្នុងការប្រព្រឹត្តសីលធម៌អីហ្នឹង យើងបានអប់រំហើយណា យើងបានលើកក្នុងប្រជុំដែរ។

**ស៖** តើលោកស្រីអាចជម្រាបជូនអង្គសវនាការបានទេ ថាការប្រព្រឹត្តខុសសីលធម៌ហ្នឹងមានន័យយ៉ាងម៉េចទៅ?

**ផ៖** ខ្ញុំមិនសូមចេះនិយាយ! ខុសសីលធម៌ ដឹង ខូចស្រី ខូចអីហ្នឹង។

[១៤:២៣:០០]

**ស៖** បាទ សូមអរគុណ។ តើនៅពេលដែលដឹងថាមានខុសសីលធម៌អីចឹងហើយ ខាងស្រុកចាត់ការយ៉ាងម៉េចទៅទាក់ទងនឹងការប្រព្រឹត្តសីលធម៌ហ្នឹង?

**ផ៖** អប់រំ។

**ស៖** លោកស្រីអាចបញ្ជាក់បានទេថា នៅក្នុងកិច្ចប្រជុំរបស់គណៈតំបន់មានប៉ុន្មានប្រភេទ ប្រជុំពីអីខ្លះ លើកឡើងពីបញ្ហាអីខ្លះ?

**ផ៖** អាហ្នឹងប្រជុំលើកបញ្ហាកសាង ដូចជាយើងកសាងទំនប់ កសាងអីហ្នឹង អត់មានធ្វើអីទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ថា ការប្រជុំហ្នឹងដូចជា ការប្រជុំសាមញ្ញធម្មតា មិនធម្មតាអី តើមានទេ?

**ផ៖** សាមញ្ញធម្មតា ប្រជុំពីរឿងធ្វើទំនប់ ធ្វើប្រឡាយអី តែប៉ុណ្ណឹង មានប្រជុំអីផង។

**ស៖** ហើយការប្រជុំហ្នឹង ធ្វើឡើងញឹកញាប់ដែរទេ?

**ផ៖** វាមិនសូវញឹកទេ មានការចាំបាច់ចេះតែប្រជុំទៅ បើមិនសូវបាច់ក៏មិនសូវបានប្រជុំដែរ។

**សៈ** ខ្ញុំចង់បញ្ជាក់អំពីនៅការប្រជុំនៅគណៈតំបន់ តើការប្រជុំនៅគណៈតំបន់ធ្វើឡើងញឹកញាប់ដែរទេ?

**ផៈ** ពេលខ្លះក៏មិនសូវបានញឹកញាប់ដែរ រវល់ធ្វើការងារអី មិនសូវ បើថាបីខែអីយើងប្រជុំពិនិត្យពីការងារដែលយើងដាក់ចុះទៅអីចឹង។ យើងមិនបានញឹកញាប់រាល់ពេលរាល់វេលាទេ។

**សៈ** តើលោកស្រីដឹងទេថា គណៈតំបន់ដែលលោកស្រីធ្វើការហ្នឹងមានបញ្ជូនរបាយការណ៍អ្វីទៅខាងថ្នាក់លើដូចជាភូមិភាគអីដែរទេ?

**ផៈ** ខ្ញុំអត់ដឹងដែរ ព្រោះអាហ្នឹងការងារគាត់។

**សៈ** បាទ សូមអរគុណ។ ចុះលោកស្រីដែលធ្លាប់ចូលរួមប្រជុំនៅក្នុងគណៈភូមិភាគដែរទេ?

**ផៈ** គណៈភូមិភាគជាមួយតាម៉ុកហ្នឹង?

**សៈ** បាទ នៅខាងនិរតី។

[១៤:២៦:០៧]

**ផៈ** ប្រជុំម្តង គាត់ហៅ។ ជួនកាលខ្ញុំសមាជិកទីប្រាំមួយអីចឹង ជួនកាលគេសូវហៅយើងប្រជុំដែរ។ គេច្រើនចូលគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយខ្ញុំនឹងមិនសូវបានចុះឡើងទៅប្រជុំនៅថ្នាក់ គណៈភូមិភាគទេ។ បើប្រជុំច្រើន-- បើប្រជុំៗជាមួយ កង ចាប នៅតំបន់គាត់ហៅប្រជុំ។ បើថាគណៈភូមិភាគ គណៈកម្មាធិការគាត់ គាត់ឡើងទៅប្រជុំនៅភូមិភាគ តែចំពោះខ្ញុំមិនសូវបានឡើងទៅប្រជុំព្រោះខ្ញុំសមាជិកទីប្រាំមួយនោះ។

**សៈ** ចុះមានដែលធ្លាប់ខាងភូមិភាគគាត់បានណែនាំឬក៏ធ្វើរបាយការណ៍មកខាងតំបន់ឲ្យ-- អំពីលទ្ធផលនៃកិច្ចប្រជុំហ្នឹងបានយ៉ាងម៉េចៗខ្លះ ហើយត្រូវធ្វើអ្វីខ្លះបន្តទៀតដែរឬទេ?

[១៤:២៧:០២]

**ផៈ** អាហ្នឹងបើគាត់ធ្វើកម្មវិធីណែនាំមក គាត់ណែនាំតំបន់ដែរ។ ណែនាំមក កង ចាប។ កង ចាប គាត់យកមកជួនកាលគាត់ប្រជុំ ជួនកាលគាត់ប្រជុំនៅស្រុកអីចឹង យកផ្សព្វផ្សាយឲ្យស្រុក។

**សៈ** បាទ សូមអរគុណ។ ឥឡូវចំណុចមួយទៀត ទាក់ទងទៅនឹងតួនាទីដែលជាខាងកិច្ចការនារី តើលោកស្រី នៅពេលណាមួយត្រូវបានតែងតាំងជាប្រធានកិច្ចនារីនៅតំបន់៣៥ នេះដែរឬទេ?

**ផៈ** នៅឆ្នាំ៧០ ក្នុងហ្នឹងអត់មានផង? ខ្ញុំវាអត់ចាំ មិនឆ្នាំចិតប៉ុន្មាន? ៧៣ ឬក៏ចិតប៉ុន្មានខ្ញុំភ្លេច។

**ស៖** អ៊ីចឹងមាន?

**ឆ៖** ចាំ។

**ស៖** តើតួនាទីដែលជាប្រធានកិច្ចការនារីនោះ តើគេឲ្យលោកស្រីធ្វើអ្វីខ្លះទៅ?

**ឆ៖** ខ្ញុំអង្គាល់ហ្នឹងតួនាទីកិច្ចការនារី អត់មានធ្វើអីគេឲ្យអប់រំ ដូចថាយើងចុះផ្សព្វផ្សាយខាងនារី ខាងអីហ្នឹង អត់មានធ្វើអីផងហ្នឹង។ ឲ្យជួយអប់រំកុមារ នៅតាមភូមិអ៊ីចឹងទៅ ខាងវប្បធម៌ដូចខាងគ្រូបង្រៀនគ្រូអីហ្នឹង ខ្ញុំអត់មានបានធ្វើអីដែរ។ ខាងកិច្ចការនារី ខាងអប់រំ ជួយអប់រំនារីហ្នឹង ខាងធ្វើគ្រូបង្រៀនគ្រូអីហ្នឹង ខ្ញុំបានអប់រំ។ តែឲ្យទៅធ្វើអីធំដុំអត់មានទេ។

**ស៖** ចុះតើអ្នកស្រីបំពេញការងារនៅខេត្តកំពតហ្នឹង នៅស្រុកកំពតហ្នឹងរហូតដល់ពេលណាដែរ?

**ឆ៖** ខ្ញុំបំពេញស្រុកកំពតឆ្នាំ៧០ បីឆ្នាំ។ បីឆ្នាំអី-- ខ្ញុំមិនបានចាំឆ្នាំ។ ក្នុងហ្នឹងមានទេលោក? ខ្ញុំវាមិនចាំថ្ងៃខែដែលយើងបានចូល ហើយក្នុងឆ្នាំហ្នឹងខ្ញុំមិនបានគិតមិនដឹងថាឆ្នាំណា ប្រហែលជាបីបួនឆ្នាំ ៧៣ហ្នឹងខ្ញុំថានេះ មិនច្បាស់លាស់ដែរ។ ខ្ញុំអត់ចាំ។

[១៤:២៩:៣២]

**ស៖** បន្ទាប់ពីការបំពេញការងាររបស់លោកស្រីនៅស្រុកកំពតហើយ តើលោកស្រីផ្លាស់ទៅខាងណាទៀតទៅ?

**ឆ៖** ខ្ញុំបំពេញការងារនៅស្រុកកំពតហើយ ខ្ញុំផ្លាស់ទៅ-- លោកតា កង ចាប ហៅខ្ញុំអប់រំ ឲ្យខ្ញុំហ្នឹងទៅនៅកំពង់ចាម ហើយខ្ញុំអត់ដឹងសោះ។ គាត់ឲ្យខ្ញុំទៅនៅកំពង់ចាម។ កង ចាប គាត់ប្រាប់ខ្ញុំថា ខ្ញុំត្រូវផ្លាស់ឲ្យទៅនៅកំពង់ចាម។

[១៤:៣០:០៥]

**ស៖** នៅកំពង់ចាមនោះ នៅស្រុកអីដែរ?

**ឆ៖** កំពង់សៀម។

**ស៖** ស្រុកកំពង់សៀមនេះស្ថិតនៅតំបន់ប៉ុន្មាន? ហើយភូមិភាគអីទៅ?

**ឆ៖** មិនដឹងតំបន់ប៉ុន្មានទេ កាលហ្នឹងខ្ញុំទៅ។ តំបន់៤១ ឬតំបន់៤២ ទេនេះ ខ្ញុំវាមិនបានចាំ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

ជាថ្មីម្តងទៀត ដើម្បីរកឲ្យឃើញថាសំណួរទាំងនេះពាក់ព័ន្ធទៅនឹងសវនាការដំណាក់កាលដំបូងនេះ ខ្ញុំនៅតែចង់ដឹងថា តើកំពុងតែយោងទៅលើ-- ទៅមុន ឬក៏ក្រោយឆ្នាំ១៩៧៥? បើសិនណាក្រោយឆ្នាំ១៩៧៥ ខ្ញុំគិតថាវាមិនពាក់ព័ន្ធទៅសវនាការដំណាក់កាលដំបូងនេះទេ។

[១៤:៣១:៣៥]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការកត់សម្គាល់របស់លោកមេធាវី ប៉ុន្តែនៅក្នុងឧបសម្ព័ន្ធ កថាខណ្ឌ ផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងទៅនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង00២ មិនមានខ្លឹមសារកំណត់កាលវេលា កាលបរិច្ឆេទដូចអ្វីដែលមេធាវីបានលើកឡើងទេ។ បញ្ហាដែលការសួរដេញដោលសាក្សីគឺភាគីដែលពាក់ព័ន្ធត្រូវធ្វើការ អាចធ្វើការនៅក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលអង្គជំនុំជម្រះបានរៀបចំជូនភាគីរួចហើយ ឯកសារ E124/7.2។ ប៉ុន្តែភាគីត្រូវតែពាក់ព័ន្ធ ត្រូវតែរៀបចំនូវការតាំងសំណួររបស់ខ្លួនដោយរៀបចំភាពពាក់ព័ន្ធទៅនឹងកថាខណ្ឌដែលបានចោទប្រកាន់តាមលំដាប់លេខរៀងពីលេខតូចទៅលេខធំនូវបញ្ហាណាដែលខ្លួនយល់ឃើញថា សាក្សីរូបនោះបានដឹង បានឮ បានឃើញពាក់ព័ន្ធនឹងអង្គហេតុនានាដែលមានការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានបំបែក យកមកធ្វើសវនាការនៅដំណាក់កាលដំបូងក្នុងសំណុំរឿងលេខ០០២/១។

[១៤:៣៣:១៧]

ការដែលចាប់ផ្តើមដំណើរការដំបូង គប្បីតែប្រព្រឹត្តទៅតាមអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការសម្រាប់វគ្គមួយគឺ "ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា"។ បន្ទាប់មកទៀត គឺអង្គភាគីអាចសួរដេញដោលតាមលំដាប់លេខរៀងពីតូចទៅធំជាបន្តបន្ទាប់នៅក្នុងក្របខ័ណ្ឌឯកសារ E124/7.2។

ដូច្នេះការជំទាស់របស់មេធាវី នួន ជា ត្រង់ចំណុចនេះគឺមិនត្រឹមត្រូវទេ។ ប៉ុន្តែខាងភាគីសហព្រះរាជអាជ្ញាក៏គប្បីពិនិត្យលើអង្គហេតុដែលខ្លួនកំពុងដេញដោលនេះនៅក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលអង្គជំនុំជម្រះបានសម្រេចចង់ជាកន្សោមមកធ្វើសវនាការនៅដំណាក់កាលដំបូងដូចបានរៀបរាប់ជម្រាបជូនរួចហើយ។ ហើយដើម្បីឲ្យងាយយល់គឺគប្បីប្រឹងប្រែងរៀបចំ និងសំណួរតាមលំដាប់អង្គហេតុពីលេខលេខរៀងតូចទៅលេខរៀងធំ។

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តសំណួរទៀត ហើយគ្រាន់តែបញ្ជាក់ថានេះ ការសួរនេះ វាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យផងដែរ។

[១៤:៣៥:០៦]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** ហើយនៅពេលដែលលោកស្រីធ្វើការនៅស្រុកកំពង់សៀមនោះ តើលោកស្រីមានតួនាទីជាអ្វីដែរ?

**លោកស្រី ប្រាក់ យុត៖**

**ឆ៖** ខ្ញុំតួនាទីលេខាស្រុក។

**ស៖** តើលោកស្រីដឹងទេថា មូលហេតុអីបានជាគេផ្លាស់លោកស្រីឱ្យទៅធ្វើការនៅស្រុកកំពង់សៀមនោះវិញ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះ កង ចាប ហៅខ្ញុំទៅជួប គាត់ថាឱ្យខ្ញុំនៅកំពង់ចាម ខ្ញុំក៏អត់បានយល់ បានដឹងដែរ ខ្ញុំទៅតាមគាត់តើ។

**ស៖** តើនៅពេលនោះ លោកស្រីមានធ្វើខុសអីទេ បានជាគេដក?

**ឆ៖** ខ្ញុំអត់ដឹងខុស មិនខុស ខ្ញុំអត់ដឹង ព្រោះគាត់ហៅខ្ញុំទៅជួប គាត់ថាន:លេខាហើយ យើងមិនស្ដាប់គាត់យ៉ាងម៉េច។

**ស៖** បាទ សូមអរគុណ។ ហើយអ៊ីចឹងនៅពេលនោះ លោកស្រីមានការបារម្ភអីទេ ពេលគេផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ?

**ឆ៖** ខ្ញុំអត់មានបារម្ភអីផង ពីព្រោះលេខាប្រាប់ហើយ ខ្ញុំអត់មានបារម្ភទេ។

[១៤:៣៦:១៨]

**ស៖** នៅពេលដែលលោកស្រីធ្វើដំណើរពី-- ធ្វើដំណើរទៅកាន់ស្រុកកំពង់សៀម ដែលជាតួនាទីថ្មីរបស់លោកស្រីហ្នឹង តើលោកស្រីបានធ្វើដំណើរមកកាត់ទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** ខ្ញុំកាត់ៗក្រុងភ្នំពេញ តែមានចូល-- គាត់ឱ្យខ្ញុំជិះឡានទៅចាំគាត់នៅកំពង់ចាម។

**ស៖** នៅពេលដែលលោកស្រីមកភ្នំពេញហ្នឹង តើលោកស្រីបានជួបអ្នកណាខ្លះនៅ--?

**ឆ៖** អត់មានបានជួបទេ។

**ស៖** សូមលោកស្រីជួយរៀបរាប់ជូនអង្គសវនាការ ថាតើការងារថ្មីរបស់លោកស្រីដែលនៅស្រុកកំពង់សៀម នៃតំបន់៤១ នេះ តើមានអ្វីដែលទៅ ហើយដូចគ្នានឹងនៅកន្លែងចាស់ដែរទេ?

**ឆ៖** ធម្មតាទេ ចាំ ខ្ញុំសូមរាយការណ៍ជូនលោកប្រធានទាំងអស់ថា ការផ្លាស់ចេញពីកន្លែងមួយទៅកន្លែងមួយ វាមិនដែលស្រួលទេ មានការលំបាកហើយ តែទោះបីការលំបាកយ៉ាងណាក៏ដោយ វាមិនមែនលំបាកធ្ងន់ធ្ងរទេ ព្រោះថាយើងចេញទៅ វាអារម្មណ៍យើងក៏វាអត់នឹងនរដែរ ទីមួយ។ តែទីពីរទៀតក៏មានការចាប់អារម្មណ៍ថា មានអី មានខុសអី យើងអត់ដឹងទេ ចេះតែទៅហើយអាហ្នឹង ប៉ុនទៅដល់នោះ ក៏មានការលំបាកដែរ ដូចថាយើងថ្មីអ៊ីចឹង ហើយប្រជាជនយើងក៏មិនស្គាល់យើងទៀត អ៊ីចឹងទៅ បានខ្ញុំទៅបានប្រហែលកន្លះអី ខ្ញុំចេះនៅយូរៗ គាត់ ដូចថាវាស៊ីសាច់ស៊ីឈាមគ្នា ដូចថាមានការកក់ក្ដៅ ចេះតែនៅទេ ប៉ុនថាឲ្យទៅនៅថ្មី វាមិនដែលស្រួល។

[១៤:៣៨:១៣]

**ស៖** អ៊ីចេះ ខ្ញុំចង់ដឹងថា តើតួនាទីនិងភារកិច្ចរបស់លោកស្រីនៅពេលដែលនៅស្រុកកំពង់សៀមនេះ តើលោកស្រីធ្វើអ្វីខ្លះដែរទៅ?

**ឆ៖** ខ្ញុំអត់មានធ្វើអី កាលហ្នឹង ចេញទៅ ខ្ញុំលេខា ប៉ុន្តែទទួលខុសត្រូវនៅក្នុងមន្ទីរស្រុកហ្នឹង គឺមានឃុំប៉ុន្មាន បួន ឬប្រាំទេ។ ក្នុងហ្នឹង គ្រាន់ថាយើងហៅមេឃុំមេអីមក យើងអប់រំជួយដើម្បីកសាងទំនប់ទឹក ធ្វើទំនប់ទឹកធ្វើអី ប៉ុន្តែមិនទាន់បានមានគម្រោងធ្វើទេ ក៏វាមានរឿងចៃដន្យទៅ ចាំខ្ញុំរាយការណ៍តាមក្រោយទៀត។ ប៉ុណ្ណឹងចប់ហើយ។

**ស៖** បាទ សូមអរគុណ។ លោកស្រីនៅចាំទេថា នៅគណៈស្រុករបស់លោកស្រីដែលលោកស្រីជាលេខាគណៈស្រុកហ្នឹង តើមានសមាជិកប៉ុន្មានដែរ? ហើយលោកស្រីនៅចាំឈ្មោះទេ អ្នកណាខ្លះ?

[១៤:៣៩:១៤]

**ឆ៖** នៅក្នុងសមាជិកខ្ញុំអ្នែស? សមាជិកឃុំបីបួននាក់ដែរ ប៉ុនឥឡូវ ខ្ញុំមក-- ស្លាប់អស់ខ្លះហើយហ្នឹង នៅសល់ម្នាក់អីមិនដឹងទេ។ កាលរត់យួននេះ ស្លាប់អស់ហើយ។

**ស៖** សមាជិកនៅពេលដែលលោកស្រីកាន់តំណែងលេខាស្រុកហ្នឹង មានប៉ុន្មាននាក់សរុបទាំងអស់?

**ឆ៖** មានបួននាក់ទេ ប្រាំនាក់។

**ស៖** លោកស្រីដឹងទេ ពីការតែងតាំងសមាជិកឃុំហ្នឹង តើគេធ្វើយ៉ាងម៉េច អីយ៉ាងម៉េចទៅ?

[១៤:៣៩:៥៣]

**ឆ៖** មាន ខ្ញុំមិនដឹងដែរ ឲ្យនៅផ្ទះ ប្រាំនាក់ហ្នឹងយើងចាត់តាំងឲ្យនៅតាមឃុំ ម្នាក់ឃុំ ដូចថាឃុំ “ក”, ឃុំ “ខ”, ឃុំ “គ”។ យើងរៀបចំឲ្យធ្វើប្រធានឃុំហ្នឹង។ មិនមែនធ្វើអី តែងតាំងអីធំដុំទេ គ្រាន់ថាអាឡូវឈ្មោះ “ក” ហ្នឹង អូនឯងនៅឃុំហ្នឹង ឃុំ “ក”, ឃុំ “ខ” អ៊ីចឹងទៅណា។ យើងរៀបរយឲ្យគាត់នៅតាមឃុំហ្នឹងទៅ។

**ស៖** អ៊ីចឹងមានន័យថា ការតែងតាំងនេះ គឺលោកស្រីជាអ្នកធ្វើដោយខ្លួនឯង ឬក៏មានថ្នាក់លើណាមកតែងតាំង?

**ឆ៖** ឧទាហរណ៍ថ្នាក់ស្រុកហ្នឹង ថ្នាក់តំបន់ហ្នឹងមកប្រាប់ខ្ញុំណា ថាចាត់តាំងមិនមែន ដូចថាមានប្រាំឃុំអ៊ីចឹង យើងរៀបចំគណៈឃុំឲ្យមានប្រាំឃុំហ្នឹងទៅ។

**ស៖** ចុះនៅគណៈស្រុករបស់លោកស្រី តើមានកម្មាភិបាលប្រភេទណាខ្លះដែរទៅ? ឧទាហរណ៍ដូចជា កម្លាំងសន្តិសុខ ឬក៏កម្លាំងយោធាដែរប្រចាំការនៅកន្លែងលោកស្រី តើមានអ៊ីចឹងដែរទេ?

**ឆ៖** ខ្ញុំអត់ទាន់បានរៀបរយផងអង្កាល់ហ្នឹង។ ទើបតែទៅបានប៉ុន្មានខែហ្នឹង។

**ស៖** ចុះនៅកន្លែងលោកស្រីធ្វើការថ្មីហ្នឹងមានមន្ទីរអប់រំ កន្លែងអប់រំកែប្រែអីដែរទេ?

**ឆ៖** អត់ទេ។

**ស៖** នៅពេលនោះតើលោកស្រីស្គាល់ថា មន្ទីរសន្តិសុខភ្នំប្រុសភ្នំស្រី ដែរទេ នៅកន្លែងហ្នឹង?

**ឆ៖** ខ្ញុំអត់ដឹងដែរ ព្រោះអាហ្នឹងខាងភូមិភាគ របស់ភូមិភាគ។ ខ្ញុំមិនដែលបានដឹងថាមន្ទីរសន្តិសុខនៅភ្នំស្រីភ្នំប្រុស ក៏ខ្ញុំអត់ដែរដឹង។ ហើយខ្ញុំមិនសូវបានទាក់ទងគ្នាដែរ ព្រោះខ្ញុំនៅស្រុកខ្ញុំ។

[១៤:៤១:៥០]

**ស៖** នៅពេលដែលលោកស្រីកាន់តួនាទីថ្មី ដែលជាលេខាស្រុកកំពង់សៀមនេះ តើលោកស្រីដែលចូលរួមប្រជុំជាមួយនឹងគណៈភូមិភាគអីដែរទេ?

**ឆ៖** ខ្ញុំចូលរួមតើជាមួយ តាពក ហ្នឹង។

**ស៖** ប្រធានគណៈភូមិភាគហ្នឹងឈ្មោះអី ពក ទៅ?

**ឆ៖** ឈ្មោះ កែ ពក តែស្លាប់ហើយអី។

**ស៖** ចុះលោកស្រីដឹងដែរទេថារចនាសម្ព័ន្ធចាត់តាំងរបស់ភូមិភាគកណ្តាលហ្នឹង វាមាន វាដូចគ្នាជាមួយនឹងរចនាសម្ព័ន្ធរបស់ភូមិភាគនិរតីដែរទេ?

**ឆ៖** ដឹងដូចគ្នាអត់។ ភូមិភាគកណ្ដាលហ្នឹង ហើយគណៈភូមិភាគអ្អែះ? ហើយម៉េច? ខ្ញុំមិនសូវក្ដាប់បានទេ។

**ស៖** ទាក់ទងទៅនឹងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ភូមិភាគមួយៗ គឺមានដូចគ្នាទេ ពីភូមិភាគនិរតី និងភូមិភាគកណ្ដាល។ ដូចជាមានតំបន់ មានចែកជាស្រុក ដូចគ្នាដែរទេ?

**ឆ៖** មានដូចគ្នា។

[១៤:៤៣:១៩]

**ស៖** តើនៅកន្លែងស្រុកកំពង់សៀមដែលលោកស្រីធ្វើការហ្នឹង មានដែលរាយការណ៍ទៅថ្នាក់លើដូចនៅតំបន់៣៥ ដែរទេ?

**ឆ៖** ចា៎ មានរាយការណ៍ឲ្យ តាពក ដែរតើ។

**ស៖** លោកស្រីមានដែលដឹងទេថា លេខាភូមិភាគ ហើយនិងសមាជិកលេខាភូមិភាគហ្នឹង គាត់មានដែលទៅប្រជុំជាមួយនឹងគណៈមជ្ឈិមអីទេ កាលហ្នឹង?

**ឆ៖** កាលហ្នឹងខ្ញុំសមាជិកទីបួន ខ្ញុំសូមជម្រាប។ សមាជិកទីបួនក្នុងគណៈតំបន់៤១ តែពេលគាត់ទៅប្រជុំនៅភូមិប្រជុំអី ព្រោះខ្ញុំមិនដែលបានទៅទេ។ ដឹងគាត់ប្រជុំអីខ្លះ ខ្ញុំមិនដឹងដែរ។ ព្រោះខ្ញុំសមាជិកទីបួនណោះ។

**ស៖** បាទ សូមអរគុណ។ តើលោកស្រីដែលទទួលការណែនាំពីភូមិភាគមកដល់ ឬក៏ពីតំបន់មកគណៈស្រុកលោកស្រីឲ្យធ្វើការងារអ្វីជាប្រចាំដែរទេ?

[១៤:៤៤:៣៥]

**ឆ៖** បាទទទួលខ្លះ។ ឧទាហរណ៍ គណៈតំបន់ គាត់ឲ្យខ្ញុំធ្វើប្រឡាយ ធ្វើទំនប់អីហ្នឹងណា៎ បានទទួល។ តែក្រៅពីហ្នឹង ខ្ញុំមិនបានទទួលទេ គាត់ឲ្យខ្ញុំធ្វើទំនប់ធ្វើប្រឡាយ នៅនឹងស្រុក ឲ្យ--

**ស៖** នៅពេលដែលលោកស្រីធ្វើការនៅគណៈលេខាគណៈស្រុកកំពង់សៀមហ្នឹង មានធ្វើទំនប់អីដែរទេ នៅពេលនុ៎ង?

**ឆ៖** ខ្ញុំអត់បានធ្វើផង។ តំបន់គាត់ធ្វើទំនប់មួយ តែខ្ញុំអត់បានចូលរួមជាមួយគាត់ទេណា៎។ ស្រុកអត់មានធ្វើទេ។ វាអត់ដីធ្វើ កាលនុ៎ងដីវាចង្អៀត ស្រុកកំពង់សៀមវាអត់មានដីធ្វើ។ អ៊ីចឹងតំបន់គាត់ធ្វើនៅបច្ចាឯណាទេ ខ្ញុំមិនសូវស្គាល់ដែរ ដូចនៅស្រុកព្រៃឈរហ្នឹង។ តែធ្វើនៅកន្លែងណា គាត់ធ្វើទំនប់មួយ តែចំពោះខ្ញុំ កាលហ្នឹងខ្ញុំលើកគម្រោងដែរ តែវាអត់បានធ្វើដោយសារអត់ដី។ ហើយវាអត់មានដីដែល

ជាប់ទឹក។

[១៤:៤៥:៤៨]

**ស៖** តើលោកស្រីដឹងទេថា ការធ្វើទំនប់មួយៗហ្នឹង គេធ្វើគ្រឿងចក្រ ឬក៏ប្រើកម្លាំងមនុស្ស?

**ផ៖** កាលហ្នឹងធ្វើទំនប់មិនគ្រឿងចក្រអី ប្រើមនុស្ស។ ប្រើមនុស្ស។

**ស៖** កាលដែលប្រើមនុស្សហ្នឹង គឺមានបញ្ជាពីថ្នាក់លើណាឲ្យមកឲ្យជ្រើសរើសមនុស្សមកធ្វើការក្នុងទំនប់ហ្នឹង ឬក៏លោកស្រីជាអ្នកជ្រើសរើសឲ្យទៅធ្វើតែម្តង?

**ផ៖** តំបន់គាត់ធ្វើ។ ឧទាហរណ៍ថា ទំនប់ហ្នឹងគាត់ធ្វើខ្លួនឯងហ៎ ហើយដូចថាឥឡូវគាត់ថា សុំកម្លាំងអីពីខ្ញុំអ៊ីចឹង ខ្ញុំជួយគាត់បានប្អូនដប់ម្ភៃនាក់អ៊ីចឹងទៅ ឲ្យវាជួយធ្វើទំនប់ហ្នឹងឆាប់។ មួយខែពីរខែគាត់សុំប្អូនដប់នាក់ យើងឲ្យគាត់ទៅ។ តែចំពោះខ្ញុំៗមិនបានធ្វើទេទំនប់ តែតំបន់គាត់ធ្វើ។

[១៤:៤៦:៤៤]

**ស៖** លោកស្រីមានដឹងទេថា រាល់ការធ្វើទំនប់នុ៎ងមានបណ្តាលឲ្យមនុស្សឈឺខ្លាំង ឬក៏មានស្លាប់អីដែរទេ?

**ផ៖** កាលហ្នឹងទំនប់ហ្នឹង ខ្ញុំអត់បានគ្រប់គ្រង ខ្ញុំមិនដឹងដែរ។ ខ្ញុំអត់បានទៅជិតគាត់ គាត់អ្នកធ្វើ ហើយខ្ញុំអត់បានធ្វើទេ។ ខ្ញុំនៅ ដូចថានៅភូមិ ឃុំក្រោមនេះ ខាងស្រែ ខាងភ្លឺ ខាងប្រឡាយអ៊ីចឹងទៅណ៎ា។ ខ្ញុំមិនបានទៅជិតទំនប់ទេ។

**ស៖** ចុះនៅពេលដែលលោកស្រីធ្វើទំនប់នៅក្នុងខេត្តកំពត ដែលតំបន់៣៥ តើមានប្រជាជន--មានកម្លាំងដែលធ្វើទំនប់ហ្នឹងត្រូវឈឺធ្ងន់ ឬក៏បណ្តាលឲ្យមានស្លាប់អីដែរទេពេលនុ៎ង?

**ផ៖** ទំនប់កោះស្លាហ្នឹងហ៎? កាលហ្នឹងខ្ញុំសូមជម្រាបថា ទំនប់កោះស្លាជាទំនប់របស់តំបន់ហេតុនេះខ្ញុំអត់មានបានចាប់អារម្មណ៍ទេ ខ្ញុំនិយាយដោយការពិត គឺខ្ញុំអត់បានចាប់អារម្មណ៍ទេ ក្នុងហ្នឹងគឺគាត់ជ្រើសរើសកម្លាំងនៅក្នុងស្រុក។ ឧទាហរណ៍ថា យកមួយស្រុក៥០នាក់ អ៊ីចឹងយើងបញ្ជូន តែខ្ញុំមិនបានទៅពិនិត្យទំនប់កោះស្លា មិនដឹងថាបែរមុខទៅណា អីត្រង់ណា ខ្ញុំមិនបានឃើញទេ។ ព្រោះខ្ញុំអត់បានទៅធ្វើផង ខាងតំបន់គាត់ធ្វើ។ និយាយរួមចែកមុខងារគ្នាច្បាស់លាស់ដែរ ដល់អ៊ីចឹងខ្ញុំអត់ទទួលឃើញទំនប់ហ្នឹងគាត់ធ្វើយ៉ាងម៉េច ក៏ខ្ញុំមិនបានទៅជិតដែរ។ គាត់យកកម្លាំង យើចេះតែបញ្ជូនឲ្យគាត់ទៅណ៎ា។ ហើយមិនដឹងថា ការប្រើប្រាស់កម្លាំងហ្នឹងវាយ៉ាងម៉េច ក៏ខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំមិនបានទៅជិតដែរ។ នៅកោះស្លាវាធំជាងគេនៅស្រុកកំពត-- ខេត្តកំពត។

[១៤:៤៨:៣៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាជាតិ។ អរគុណសាក្សី។ ហើយឥឡូវនេះដល់ពេលវេលាសមល្មមនឹងសម្រាកហើយៗ សម្រាប់រសៀលដោយអង្គជំនុំជម្រះបានជម្រាបហើយដោយសារអង្គជំនុំជម្រះមានការកិច្ចចាំបាច់ ដើម្បីពិភាក្សាផ្ទៃក្នុងនៅលើបញ្ហាសំខាន់ៗមួយចំនួន។ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺសម្រេចផ្អាកត្រឹមនេះ ហើយសវនាការលើកបន្តទៅធ្វើនៅថ្ងៃស្អែកចាប់វេលាម៉ោងប្រាំបួនព្រឹក។

ហេតុដូច្នេះសូមភាគី និងសាធារណជនជ្រាប។ ហើយសូមជម្រាបសាក្សីផងដែរ អង្គជំនុំជម្រះអញ្ជើញសាក្សីមកចូលរួមផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែក។ សូមអញ្ជើញមកដល់ទីនេះមុនម៉ោងប្រាំបួនព្រឹក ហើយមន្ត្រីតុលាការសូមសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីសម្របសម្រួលក្នុងការធ្វើដំណើរ និងការស្នាក់នៅរបស់សាក្សីរូបនេះឲ្យត្រឹមត្រូវ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សូមសម្រាកចុះ៕

*(ចៅក្រមចាកចេញពីបន្ទប់សវនាការ)*

*(សវនាការផ្អាកនៅម៉ោង ១៤:៥០ នាទី)*